សាកលវិទ្យាល័យភូមិន្ទនីតិសាស្ត្រ
និងវិទ្យាសាស្ត្រសេដ្ឋកិច្ច

## សារណាបញ្ចប់ការសិក្សា

# ការអភិវឌ្ឍសហគមន៍

ស្រាវជ្រាវ ពីថ្ងៃទី១៦ ខែមីនា ដល់ថ្ងៃទី១៥ ខែឧសភា ឆ្នាំ២០២០


ស្រាវជ្រាវដោយ
និស្សិតឈ្មោះ **មឿន ចាន់សុផាន់ម៉ៃ**
**ច្រឹង វ៉ាន់ឆ្លើម**

សាស្ត្រាចារ្យណែនាំ
បណ្ឌិត **ឌុយ ចាន់ឌីណា**


ថ្នាក់បរិញ្ញាបត្រសេដ្ឋកិច្ចអភិវឌ្ឍន៍
ជំនាន់ទី០៤

ឆ្នាំចូលសិក្សា ២០១៦
ឆ្នាំសរសេរសារណា ២០២០

# អារម្ភកថា

បន្ទាប់ពីបានសិក្សានៅសាកលវិទ្យាល័យភូមិន្ទនីតិសាស្ត្រ និងវិទ្យាសាស្ត្រសេដ្ឋកិច្ច លើមុខជំនាញសេដ្ឋកិច្ចអភិវឌ្ឍន៍រយៈពេល ៤ឆ្នាំកន្លងមក ចំពោះសារណាបញ្ចប់ការសិក្សានេះជាការស្រាវជ្រាវកម្រិតបឋមក្នុងរយៈពេលកំណត់មួយ ហើយក៏ជាលទ្ធផលចុងក្រោយ និងជាចំណេះដឹងដែលបានសិក្សាអស់រយៈពេល ៤ឆ្នាំនៃថ្នាក់បរិញ្ញាបត្រជំនាញសេដ្ឋកិច្ចអភិវឌ្ឍន៍។ នៅក្នុងឆមាសទី២នៃឆ្នាំទី៤ យើងខ្ញុំទាំងពីរនាក់បានសម្រេចចិត្តចាប់ដៃគូគ្នាក្នុងការសិក្សាស្រាវជ្រាវ ដើម្បីចងក្រងជាសារណាបញ្ចប់ការសិក្សាដែលមានប្រធានបទ "**ការអភិវឌ្ឍសហគមន៍**"។

ការជ្រើសរើសយកប្រធានបទនេះមកធ្វើការសិក្សាស្រាវជ្រាវយើងខ្ញុំពិតជាបានជួបប្រទះនូវបញ្ហាមួយចំនួនផងដែរ ដោយសារតែក្រុមរបស់យើងខ្ញុំពុំសូវមានបទពិសោធន៍ទៅលើប្រធានបទមួយនេះនៅឡើយ ដែលទាមទារឱ្យក្រុមរបស់យើងខ្ញុំមានការស្នើសុំឯកសារមួយចំនួនពីខាងក្រសួងអភិវឌ្ឍន៍ជនបទ ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ ការស្រាវជ្រាវពីប្រព័ន្ធអ៊ីនធឺណែត ការចុះទៅដល់សហគមន៍ផ្ទាល់ រួមនឹងការតម្រែតម្រង់ទិសពីសំណាក់លោកសាស្ត្រាចារ្យបណ្ឌិត **ឌុយ ចាន់ឌីណា** ដែលបានផ្តល់នូវគំនិតសម្ខាន់ៗដែលជាគន្លឹះនៃការស្រាវជ្រាវ។ ទន្ទឹមនឹងនេះផងដែរ យើងខ្ញុំទាំងពីរនាក់សង្ឃឹមថាសារណាបញ្ចប់ការសិក្សាមួយនេះនឹងអាចជួយដល់ប្អូនៗ សិស្ស និស្សិតជំនាន់ក្រោយឱ្យមានការយល់ដឹងបន្ថែមទៀតទាក់ទងទៅនឹងកត្តាជាច្រើនដែលជម្រុញឱ្យមានការអភិវឌ្ឍសហគមន៍ ព្រមទាំងយល់ឱ្យកាន់តែច្បាស់អំពីបញ្ហាប្រឈម និងដំណោះស្រាយល្អៗដែលកើតមានឡើងនៅក្នុងការអភិវឌ្ឍ។

ជាចុងក្រោយនេះ ដោយការយល់ដឹងនៅមានកម្រិត និងពេលវេលាខ្លីនៅក្នុងការចងក្រងជាសារណានេះ យើងខ្ញុំទាំងពីរនាក់ប្រាកដជាមានកំហុសឆ្គង និងចំណុចខ្វះខាតជាក់ជាមិនខាន។ អាស្រ័យដូចនេះហើយ យើងខ្ញុំទាំងពីរនាក់រីករាយស្វាគមន៍ទទួលយករាល់មតិរិះគន់ទាំងឡាយពីសំណាក់សាស្ត្រាចារ្យលោកគ្រូអ្នកគ្រូ សិស្ស និស្សិត និងមិត្តៗអ្នកអានទាំងអស់ដើម្បីស្ថាបនាសារណានេះឱ្យកាន់តែល្អប្រសើរ។

# សេចក្តីថ្លែងអំណរគុណ

យើងខ្ញុំឈ្មោះ មឿន ចាន់សុផាន់ម៉ៃ និងច្រឹង រ៉ាន់ឆ្លើម ជានិស្សិតបរិញ្ញាបត្រសេដ្ឋកិច្ចអភិវឌ្ឍន៍ ជំនាន់ទី៤ នៃសាកលវិទ្យាល័យភូមិន្ទនីតិសាស្ត្រ និងវិទ្យាសាស្ត្រសេដ្ឋកិច្ច។ ក្នុងការសរសេរសារណាបញ្ចប់ការសិក្សាលើប្រធានបទ "**ការអភិវឌ្ឍសហគមន៍**" យើងខ្ញុំទាំងពីររូបសូមលំឱនកាយ វាចាចិត្ត ក្រាបប្រណិប័តន៍ និងសូមសម្តែងនូវសេចក្តីគោរពដ៏ខ្ពង់ខ្ពស់ ព្រមទាំងការដឹងគុណយ៉ាងជ្រាវជ្រៅជូនចំពោះ៖

- លោកឪពុក អ្នកម្តាយ ដែលបានផ្តល់កំណើត ចិញ្ចឹមបីបាច់ថែរក្សា និងផ្តល់ជាកម្លាំងកាយ ចិត្ត ស្មារតី ធនធាន សម្ភារៈ ដល់រូបយើងខ្ញុំ ព្រមទាំងឧបត្ថម្ភសព្វគ្រប់បែបយ៉ាងទាំងអស់ ដោយមិនគិតពីសេចក្តីនឿយហត់ ក្នុងការអប់រំ ណែនាំ ប្រៀនប្រដៅ ទូន្មាន រៀបចំ តម្រង់ទិស ទំនុកបម្រុងការសិក្សាតាំងពីថ្នាក់បឋមសិក្សា រហូតដល់ថ្នាក់បរិញ្ញាបត្រនេះ។
- ឯកឧត្តមសាកលវិទ្យាធិការនៃសាកលវិទ្យាល័យភូមិន្ទនីតិសាស្ត្រ និងវិទ្យាសាស្ត្រសេដ្ឋកិច្ច ព្រមទាំងលោកសាស្ត្រាចារ្យទាំងអស់ដែលបានយកចិត្តទុកដាក់បង្ហាត់បង្រៀន និងផ្តល់បទពិសោធន៍ល្អៗយ៉ាងច្រើនដល់យើងខ្ញុំទាំងពីររូប។
- លោកគ្រូ សាស្ត្រាចារ្យបណ្ឌិត **ឌុយ ចាន់ឌីណា** ដែលបានជួយជ្រោមជ្រែង ដឹកនាំ ដាស់តឿន ហើយបានកែតម្រូវនូវកំហុសខុសឆ្គងដែលមាននៅក្នុងការសរសេរសារណាបញ្ចប់ការសិក្សានេះ ចាប់តាំងពីចំណុចចាប់ផ្តើមរហូតទទួលបានជោគជ័យទោះបីជាមានឧបសគ្គ ឬពេលវេលាតិចតួចស្តួចស្តើងយ៉ាងណាក៏ដោយ។
- លោក **ឆេង ចុង** ប្រធានសហគមន៍កសិកម្មសំបូរមានជ័យ ដែលបានផ្តល់នូវការស្វាគមន៍ចំពោះការចុះស្រាវជ្រាវឯកសារ និងបានផ្តល់ឯកសារជាច្រើនដែលទាក់ទងនឹងការអភិវឌ្ឍសហគមន៍កសិកម្មផ្ទាល់។

ជាចុងក្រោយយើងខ្ញុំទាំងពីរនាក់ សូមលើកហត្ថប្រណម្យដល់អស់ទេវតា និងវត្ថុស័ក្តិសិទ្ធក្នុងលោកសូមជួយថែរក្សាដល់លោកអ្នកមានគុណ រួមទាំងសាស្ត្រាចារ្យទាំងអស់ឱ្យជួបតែប្រសិទ្ធពរជ័យ សិរីមង្គលវិបុលសុខ ព្រមទាំងពុទ្ធពរ ទាំងបួនប្រការគឺ អាយុ វណ្ណៈ សុខៈ ពលៈ កុំបីឃ្លៀងឃ្លាតឡើយ។

# មាតិកា

១.បញ្ជីអក្សរកាត់ ........ v

២.បញ្ជីតារាង ........ vi

៣.បញ្ជីក្រាហ្វិក ........ vii

៤.បញ្ជីរូបភាព ........ viii

## សេចក្តីផ្តើម

១. លំនាំបញ្ហា ........ ១

២. ចំណោទបញ្ហា ........ ២

៣. គោលបំណងនៃការស្រាវជ្រាវ ........ ២

៤. ទំហំ និងដែនកំណត់នៃការសិក្សាស្រាវជ្រាវនេះ ........ ៣

៥. វិធីសាស្រ្តនៃការស្រាវជ្រាវ ........ ៣

៦. សារៈសម្ខាន់នៃការស្រាវជ្រាវ ........ ៣

៧. រចនាសម្ព័ន្ធនៃការស្រាវជ្រាវ ........ ៤

## ជំពូកទី១

## ការសិក្សាលើទ្រឹស្តី និងទស្សនទានដែលពាក់ព័ន្ធ

១.១ និយមន័យ ........ ៥

១.១.១ និយមន័យនៃការអភិវឌ្ឍ ........ ៥

១.១.២ និយមន័យនៃសហគមន៍ ........ ៥

១.១.២.១ លក្ខណៈនៃសហគមន៍ ........ ៦

១.១.៣ និយមន័យនៃការអភិវឌ្ឍសហគមន៍ ........ ៦

១.២ ទស្សនរបស់អ្នកប្រាជ្ញ ........ ៧

១.២.១ ទ្រឹស្តីនៃការអភិវឌ្ឍ ........ ៧

១.២.១.១ ទ្រឹស្តីលោក Micheal P.Todaro ........ ៧

១.២.១.២ ទ្រឹស្តីលោក Walt Withman Rostow ........ ៨

១.២.២ ទ្រឹស្តីនៃការអភិវឌ្ឍសហគមន៍ ........ ៨

១.២.២.១ ទ្រឹស្តីលោក Julian Rappaport ........ ៩

១.២.២.២ ទ្រឹស្តីលោក Urie Bronfenbrenner ........................................ ៩
១.២.២.៣ ទ្រឹស្តីលោក Auguste Comte ........................................ ៩
១.២.២.៤ ទ្រឹស្តីលោក Rober T.Craig ........................................ ១០
១.២.២.៥ ទ្រឹស្តីលោក Mabud Vi-Haq ........................................ ១០
១.២.២.៦ ទ្រឹស្តីលោក Michael Jacoby Brown ........................................ ១០
១.៣ ទស្សនវិស័យនៃការអភិវឌ្ឍសហគមន៍ ........................................ ១០
១.៣.១ គោលបំណងនៃការអភិវឌ្ឍសហគមន៍ ........................................ ១១
១.៣.២ គោលការណ៍នៃការអភិវឌ្ឍសហគមន៍ ........................................ ១២
១.៣.៣ មូលហេតុនៃការអភិវឌ្ឍសហគមន៍ ........................................ ១៣
១.៣.៤ វដ្តនៃការអភិវឌ្ឍសហគមន៍ ........................................ ១៣
១.៤ គោលនយោបាយរបស់រដ្ឋាភិបាលក្នុងការអភិវឌ្ឍសហគមន៍ ........................................ ១៤
១.៤.១ លក្ខណៈទូទៅ ........................................ ១៤
១.៤.២ គោលនយោបាយ និងតួនាទីរបស់រដ្ឋាភិបាលថ្នាក់ក្រោមជាតិ ........................................ ១៥
១.៤.៣ ទិសដៅក្នុងការអភិវឌ្ឍសហគមន៍ ........................................ ១៥
១.៤.៣.១ ទិសដៅបញ្ចប់ភាពខ្វះខាត ........................................ ១៦
១.៤.៣.២ ទិសដៅលើកកម្ពស់កម្រិតជីវភាពរស់នៅ និងសុខុមាលភាព ........................................ ១៦
១.៤.៣.៣ ទិសដៅលើកកម្ពស់ការអប់រំ ........................................ ១៧
១.៥ ចំណុចសម្ខាន់ៗក្នុងការអភិវឌ្ឍសហគមន៍ ........................................ ១៧
១.៥.១ ការអភិវឌ្ឍសង្គមកិច្ចក្នុងសហគមន៍ ........................................ ១៧
១.៥.១.១ ការអភិវឌ្ឍធនធានមនុស្ស ........................................ ១៧
១.៥.១.២ ការអភិវឌ្ឍវិស័យអប់រំ ........................................ ១៨
១.៥.១.៣ ការអភិវឌ្ឍវិស័យសុខាភិបាល ........................................ ១៩
១.៥.១.៤ ការអភិវឌ្ឍវិស័យរដ្ឋបាល ........................................ ១៩
១.៥.២ ការអភិវឌ្ឍសេដ្ឋកិច្ចសហគមន៍ ........................................ ២០
១.៥.២.១ ការអភិវឌ្ឍវិស័យកសិកម្ម ........................................ ២០
១.៥.២.២ ការអភិវឌ្ឍវិស័យទំនាក់ទំនង ........................................ ២១

១.៦ កត្តាដែលជម្រុញឱ្យមានការអភិវឌ្ឍសហគមន៍ ....................................................................២១
១.៦.១ កត្តាធនធានមនុស្ស ....................................................................២១
១.៦.១.១ ការចូលរួមរបស់ប្រជាពលរដ្ឋក្នុងការអភិវឌ្ឍសហគមន៍ ....................................................................២២
១.៦.១.២ ចំណង់ចំណូលចិត្តក្នុងការចូលរួមអភិវឌ្ឍសហគមន៍....................................................................២២
១.៦.១.៣ ភាពជាអ្នកដឹកនាំក្នុងសហគមន៍ ....................................................................២២
១.៦.១.៤ ឥរិយាបថក្នុងការអភិវឌ្ឍសហគមន៍....................................................................២២
១.៦.២ កត្តាសង្គម....................................................................២២
១.៦.៣ កត្តាធនធានធម្មជាតិ .................................................................... ២៣
១.៦.៤ កត្តាមូលធន.................................................................... ២៣
១.៦.៥ កត្តាសេវាកម្មរដ្ឋបាល និងសន្តិសុខ .................................................................... ២៣
១.៧ កត្តាដែលជាផលវិបាកក្នុងការអភិវឌ្ឍសហគមន៍ ....................................................................២៤
១.៧.១ បញ្ហាបច្ចេកវិទ្យា ....................................................................២៤
១.៧.២ បញ្ហាអក្ខរកម្ម ....................................................................២៥
១.៧.៣ បញ្ហានិកម្មភាព និងការធ្វើចំណាកស្រុក....................................................................២៥
១.៧.៣.១ បញ្ហានិកម្មភាព ....................................................................២៥
១.៧.៣.២ បញ្ហាចំណាកស្រុក....................................................................២៦
១.៧.៤ គម្លាតរវាងអ្នកមាន និងអ្នកក្រ ....................................................................២៦
១.៧.៥ កំណើនប្រជាជន....................................................................២៦

## ជំពូកទី២

## លក្ខណៈទូទៅ និងស្ថានភាពជុំវិញការអភិវឌ្ឍសហគមន៍កសិកម្មសំបូរមានជ័យ នៅក្នុងភូមិសំបូរ ឃុំសូតាស ស្រុកស្ទឹងត្រង់ ខេត្តកំពង់ចាម

២.១ លក្ខណៈទូទៅ....................................................................២៨
២.១.១ ប្រវត្តិនៃការអភិវឌ្ឍសហគមន៍កសិកម្មនៅក្នុងប្រទេសកម្ពុជា....................................................................២៨
២.១.២ ការអភិវឌ្ឍសហគមន៍កសិកម្ម....................................................................២៨
២.១.៣ គោលបំណងនៃការអភិវឌ្ឍសហគមន៍កសិកម្ម ....................................................................២៩
២ ១.៣.១.លក្ខន្តិកៈរបស់សហគមន៍កសិកម្ម....................................................................៣០

២.១.៣.២ លក្ខណៈវិនិច្ឆ័យនៃការជ្រើសរើសទីតាំងគម្រោង....................................................៣០
២.១.៣.៣ នីតិវិធីស្នើសុំ និងការជ្រើសរើសគម្រោង........................................................៣១
២.១.៣.៤ ចំណាត់ថ្នាក់នៃប្រភេទគម្រោង ..........................................................................៣៣
២.១.៣.៥ ផែនការថវិកា....................................................................................................៣៣
២.១.៣.៦ គណៈកម្មការវាយតម្លៃគម្រោង ..........................................................................៣៤
២.១.៣.៧ ការផ្តល់ជំនួយ....................................................................................................៣៤
២.១.៣.៨ សមិទ្ធផលនៃការអភិវឌ្ឍសហគមន៍កសិកម្ម ........................................................៣៥
២.២ ស្ថានភាពនៃការអភិវឌ្ឍសហគមន៍កសិកម្មសំបូរមានជ័យនៅក្នុងភូមិសំបូរ ឃុំសូភាស ស្រុកស្ទឹងត្រង់ខេត្តកំពង់ចាម .....................................................................................................៣៥
២.២.១ ប្រវត្តិនៃការបង្កើតសហគមន៍កសិកម្មសំបូរមានជ័យ.....................................................៣៥
២.២.២ ទីតាំងភូមិសាស្ត្រសហគមន៍កសិកម្មសំបូរមានជ័យ.....................................................៣៦
២.២.៣ ស្ថានភាពបច្ចុប្បន្នរបស់សហគមន៍កសិកម្មសំបូរមានជ័យ .............................................៣៦
២.២.៤ មុខរបររបស់សហគមន៍កសិកម្មសំបូរមានជ័យ .........................................................៣៧
២.២.៥ ការអភិវឌ្ឍសហគមន៍កសិកម្មសំបូរមានជ័យ..............................................................៣៨
២.២.៥.១ រចនាសម្ព័ន្ធសហគមន៍កសិកម្មសំបូរមានជ័យ ......................................................៣៨
២.២.៥.២ ការបែងចែកភារកិច្ច និងតួនាទីរបស់ថ្នាក់ដឹកនាំសហគមន៍...................................៣៩
២.២.៥.៣ ផែនការអភិវឌ្ឍសហគមន៍ឆ្នាំទី១ ....................................................................... ៤០
២.២.៥.៤ ផែនការអភិវឌ្ឍសហគមន៍ឆ្នាំទី២ ....................................................................... ៤០
២.២.៥.៥ លក្ខន្តិកៈសម្រាប់គម្រោងនីមួយៗ ..................................................................... ៤១
២.២.៥.៦ ការអនុវត្តផែនការសហគមន៍ ..............................................................................៤២
២.២.៥.៧ ការត្រួតពិនិត្យ ..................................................................................................៤៣
២.៣ ទិសដៅក្នុងការអភិវឌ្ឍសហគមន៍កសិកម្មសំបូរមានជ័យ.........................................................៤៣
២.៣.១ ចក្ខុវិស័យអភិវឌ្ឍសហគមន៍ ..................................................................................... ៤៤
២.៣.២ គោលបំណងអភិវឌ្ឍសហគមន៍ ................................................................................. ៤៤
២.៣.២.១ គោលបំណងផ្នែកសេដ្ឋកិច្ច .............................................................................. ៤៤
២.៣.២.២ គោលបំណងផ្នែកសង្គមកិច្ច................................................................................. ៤៤

២.៣.២.៣ គោលបំណងផ្នែករដ្ឋបាល ............ ៤៥
២.៣.២.៤ គោលបំណងផ្នែកយេនឌ័រ ............ ៤៥
២.៣.៣ គោលដៅអភិវឌ្ឍសហគមន៍ ............ ៤៥
២.៤ សកម្មភាពរបស់ថ្នាក់ដឹកនាំ និងប្រជាជនក្នុងការអភិវឌ្ឍសហគមន៍កសិកម្មសំបូរមានជ័យ ............ ៤៥
២.៤.១ ការចូលរួមអនុវត្តន៍ផ្ទាល់របស់មន្ត្រីថ្នាក់ខេត្ត និងមន្ត្រីថ្នាក់ឃុំ ............ ៤៦
២.៤.២ ការចូលរួមអនុវត្តន៍របស់ប្រជាពលរដ្ឋ ............ ៤៦
២.៥ សកម្មភាពសម្ខាន់ៗរបស់សហគមន៍កសិកម្មសំបូរមានជ័យ ............ ៤៦
២.៥.១ ការប្រជុំក្រុមប្រឹក្សាភិបាល និងគណៈកម្មាធិការប្រតិបត្តិ ............ ៤៦
២.៥.២ ការប្រជុំផ្សព្វផ្សាយជាមួយសមាជិក ............ ៤៦
២.៥.៣ ការចុះឈ្មោះសមាជិក និងការរៀបចំរបាយការណ៍ត្រួតពិនិត្យកសិកម្ម ............ ៤៧
២.៥.៤ ការត្រួតពិនិត្យមើលលើដំណាំកសិកម្ម ............ ៤៧
២.៥.៥ ការបណ្តុះបណ្តាលអ្នកត្រួតពិនិត្យផ្ទៃខាងក្នុង ............ ៤៧
២.៥.៦ ការផ្សព្វផ្សាយពីកសិកម្មក្នុងសហគមន៍កសិកម្មសំបូរមានជ័យ ............ ៤៨

## ជំពូកទី៣

## ការសិក្សាលើលទ្ធផលស្រាវជ្រាវ និងការវិភាគទិន្នន័យ

៣.១ ការសិក្សាលើលទ្ធផលស្រាវជ្រាវ ............ ៤៩
៣.១.១ ស្ថានភាពអភិវឌ្ឍសហគមន៍កសិកម្មសំបូរមានជ័យពីឆ្នាំ២០១៥ ដល់ ឆ្នាំ២០១៩ ............ ៤៩
៣.១.២ បង្ហាញពីស្ថានភាពដើមទុនសម្រាប់ប្រកបរបរកសិកម្មរបស់សមាជិកសហគមន៍កសិកម្មសំបូរមានជ័យពីឆ្នាំ២០១៥ ដល់ ឆ្នាំ២០១៩ ............ ៥៣
៣.២ ការវិភាគទិន្នន័យ ............ ៥៥
៣.២.១ ស្ថានភាពដើមទុនខ្វះខាតជាមធ្យមរបស់សមាជិកសហគមន៍កសិកម្មសំបូរមានជ័យក្នុងការប្រកបរបរកសិកម្មពីឆ្នាំ២០១៥ ដល់ ឆ្នាំ២០១៩ ............ ៥៥
៣.២.២ ស្ថានភាពដើមទុនគ្រប់គ្រាន់ជាមធ្យមរបស់សមាជិកសហគមន៍កសិកម្មសំបូរមានជ័យក្នុងការប្រកបរបរកសិកម្មពីឆ្នាំ២០១៥ ដល់ ឆ្នាំ២០១៩ ............ ៥៨
៣.៣ ភាពប្រែប្រួលនៅក្នុងសហគមន៍ ............ ៦១
៣.៣.១ ចំណុចខ្លាំងនៅក្នុងសហគមន៍ ............ ៦១

៣.៣.២ ចំណុចខ្សោយនៅក្នុងសហគមន៍......................................................................៦៣
៣.៤ លទ្ធផលស្រាវជ្រាវ .......................................................................................៦៣

## សេចក្ដីសន្និដ្ឋាន និងការផ្ដល់អនុសាសន៍

១. សេចក្ដីសន្និដ្ឋាន ...........................................................................................៦៥
២. ការផ្ដល់អនុសាសន៍ .......................................................................................៦៦

**ឯកសារយោង**

**ឧបសម្ព័ន្ធ**

# បញ្ជីអក្សរកាត់

- ✓ គ.អ.ភ ៖ គណៈកម្មាធិការអភិវឌ្ឍន៍ភូមិ
- ✓ NGO ៖ Non-Government Organization (អង្គការមិនមែនរដ្ឋាភិបាល
- ✓ TSSD ៖ Timpanogos Special Service District (សេវាកម្មពិសេសធីមផានហ្គូស)
- ✓ CARDI ៖ Cambodian Agricultural Research and Development Institute
- ✓ ERECON ៖ Institute Of Environmental Rehabilitation and Conversation
- ✓ GAP ៖ Good Agricultural Practices (ការអនុវត្តល្អក្នុងវិស័យកសិកម្ម)
- ✓ ESNF ៖ Environmental and social Management Framework
- ✓ DGRV ៖ Deutscher Genossenschafts-und Raiffeisenverband
- ✓ % ៖ ភាគរយ

# បញ្ជីតារាង

តារាងទី១ ៖ បង្ហាញពីប្រភេទ និងលក្ខណៈវិនិច្ឆ័យនៃការជ្រើសរើសទីតាំងគម្រោង ..............................៣១
តារាងទី២ ៖ បង្ហាញពីកំណើនសមាជិកក្នុងប្រភេទមុខរបរកសិកម្ម ចិញ្ចឹមសត្វ និងមុខរបរដាំដុះផ្សេងៗទៀតពីឆ្នាំ២០១៥ ដល់ ឆ្នាំ២០១៩ .......................................................................... ៥០
តារាងទី៣ ៖ បង្ហាញពីប្រភេទឧបករណ៍ដែលសមាជិកក្នុងសហគមន៍ប្រើប្រាស់ក្នុងការប្រកបមុខរបរកសិកម្មពីឆ្នាំ២០១៥ ដល់ ឆ្នាំ២០១៩ ............................................................................. ៥១
តារាងទី៤ ៖ បង្ហាញពីប្រភពទឹកដែលសមាជិកក្នុងសហគមន៍ប្រើប្រាស់ក្នុងការស្រោចស្រពដំណាំកសិកម្មពីឆ្នាំ២០១៥ ដល់ ឆ្នាំ២០១៩ .............................................................................៥២
តារាងទី៥ ៖ បង្ហាញពីស្ថានភាពដើមទុនរបស់សមាជិកសហគមន៍ក្នុងការប្រកបរបរកសិកម្មពីឆ្នាំ២០១៥ ដល់ឆ្នាំ២០១៩ ................................................................................................ ៥៤
តារាងទី៦៖ បង្ហាញពីស្ថានភាពដើមទុនខ្វះខាតរបស់សមាជិកសហគមន៍ក្នុងការប្រកបរបរកសិកម្មពីឆ្នាំ២០១៥ ដល់ ឆ្នាំ២០១៩ ............................................................................................ ៥៥
តារាងទី៧ ៖ បង្ហាញពីភាគរយនៃដើមទុនខ្វះខាតរបស់សមាជិកសហគមន៍ក្នុងការប្រកបរបរកសិកម្មពីឆ្នាំ២០១៥ ដល់ ឆ្នាំ២០១៩ ............................................................................................ ៥៦
តារាងទី៨ ៖ បង្ហាញពីស្ថានភាពដើមទុនគ្រប់គ្រងរបស់សមាជិកសហគមន៍ក្នុងការប្រកបរបរកសិកម្មពីឆ្នាំ២០១៥ ដល់ ឆ្នាំ២០១៩ ............................................................................................ ៥៨
តារាងទី៩ ៖ បង្ហាញពីភាគរយនៃដើមទុនគ្រប់គ្រាន់របស់សមាជិកសហគមន៍ក្នុងការប្រកបរបរកសិកម្មពីឆ្នាំ២០១៥ ដល់ ឆ្នាំ២០១៩ ........................................................................................... ៥៩
តារាងទី១០ ៖ បង្ហាញពីអចលនទ្រព្យក្នុងសហគមន៍.....................................................................៦២

# បញ្ជីក្រាហ្វិក

ក្រាហ្វិកទី១ ៖ បង្ហាញពីកំណើនសមាជិកពីឆ្នាំ២០១៥ ដល់ ឆ្នាំ២០១៩ .......................................... ៤៩

# បញ្ជីរូបភាព


រូបភាពទី១ ៖ បង្ហាញពីវដ្តនៃការអភិវឌ្ឍសហគមន៍ ........................................................................១៣

រូបភាពទី២ ៖ បង្ហាញពីនីតិវិធីស្នើសុំ និងការជ្រើសរើសគម្រោង ...................................................... ៣២

រូបភាពទី៣ ៖ បង្ហាញអំពីផែនទីស្រុកស្ទឹងត្រង់ ខេត្តកំពង់ចាម .......................................................៣៦

រូបភាពទី៤ ៖ បង្ហាញពីមុខរបររបស់សហគមន៍កសិកម្មសំបូរមានជ័យ ............................................ ៣៧

រូបភាពទី៥ ៖ បង្ហាញពីរចនាសម្ព័ន្ធរបស់សហគមន៍កសិកម្មសំបូរមានជ័យ .......................................៣៨

# បញ្ជីឧបសម្ព័ន្ធ

- ✓ ឧបសម្ព័ន្ធទី១ ៖ រចនាសម្ព័ន្ធនៃការគ្រប់គ្រងសហគមន៍កសិកម្មរបស់ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ
- ✓ ឧបសម្ព័ន្ធទី២ ៖ រចនាសម្ព័ន្ធនៃការគ្រប់គ្រងរបស់សហគមន៍កសិកម្មសំបូរមានជ័យ
- ✓ ឧបសម្ព័ន្ធទី៣ ៖ កម្រងសំណួរ
- ✓ ឧបសម្ព័ន្ធទី៤ ៖ លក្ខន្តិកៈរបស់សហគមន៍កសិកម្ម
- ✓ ឧបសម្ព័ន្ធទី៥ ៖ ទិដ្ឋភាពទូទៅជុំវិញសហគមន៍កសិកម្មសំបូរមានជ័យ

# សេចក្ដីផ្ដើម

## ១. លំនាំបញ្ហា

តាំងពីអតីតកាលមកស្ទើរតែរាល់សកម្មភាពនៃគម្រោងអភិវឌ្ឍន៍ទាំងអស់ត្រូវបានគេផាត់ចោល និងមានចំណែកតិចតួចបំផុតនៅក្នុងតំបន់ដែលអនុវត្តន៍គម្រោងនោះផ្ទាល់។ ដោយសារតែផ្នត់គំនិតរបស់ប្រជាជននាសម័យនោះមានការយកចិត្តទុកដាក់ខ្ពស់ទៅលើផលអវិជ្ជមាន ជាជាងភាពរីកចម្រើនដែលបានមកពីការអភិវឌ្ឍ។

ផ្ទុយមកវិញចាប់តាំងពីចុងឆ្នាំ ២០០០មក នៅទូទាំងប្រទេសកម្ពុជាមានក្រុមប្រជាពលរដ្ឋជាច្រើនបានសម្ដែងនូវការចាប់អារម្មណ៍ និងឆន្ទៈយ៉ាងមោះមុតក្នុងការចូលរួមរៀបចំជាសហគមន៍ដើម្បីធ្វើការទំនាក់ទំនងគ្នាទៅវិញទៅមក និងចែករំលែកនូវភាពខ្វះខាតមួយចំនួនដើម្បីបំពេញតម្រូវការជាទូទៅនៅក្នុងភូមិ ឬឃុំរបស់ខ្លួន។

ជាក់ស្ដែងប្រទេសកម្ពុជានាពេលកន្លងមកបានធ្វើការរិះរកនូវគ្រប់មធ្យោបាយក្នុងការអភិវឌ្ឍលើគ្រប់វិស័យទាំងអស់ក្នុងទីជនបទ និងតាមបណ្ដាលសហគមន៍នានាឱ្យមានការរីកចម្រើនដើម្បីជួយជម្រុញដល់កម្រិតជីវភាពរស់នៅ និងបង្កើននូវអត្រាប្រាក់ចំណូលរបស់ប្រជាពលរដ្ឋឱ្យខ្ពស់ផុតពីបន្ទាត់នៃភាពក្រីក្រ។ ជាពិសេសក្នុងតំបន់ណាមួយដែលកំពុងប្រឈមមុខនឹងភាពក្រីក្រ និងមានអត្រាប្រាក់ចំណូលរបស់ប្រជាជនក្នុងតំបន់នោះទទួលបានក្នុងកម្រិតទាប គឺជាការទាមទារឱ្យមានការបង្កើនមនសិការ និងភាពជាអ្នកដឹកនាំក្នុងការអភិវឌ្ឍសហគមន៍អោយជឿនលឿនតាមដែលអាចធ្វើទៅបាន។ តែការអភិវឌ្ឍនេះត្រូវរៀបចំទិសដៅឱ្យបានច្បាស់លាស់ទើបធ្វើឱ្យកំណើនសេដ្ឋកិច្ចមានការកើនឡើងដូចដែលយើងធ្លាប់បានរំពឹងទុកកាលពីឆ្នាំ២០១៨ ថាសេដ្ឋកិច្ចកម្ពុជាត្រូវប៉ាន់ស្មានរក្សាកំណើនបានក្នុងរង្វង់ ៧.០% ដែលរួមមានវិស័យធំៗចំនួនបីគឺ វិស័យកសិកម្ម វិស័យឧស្សាហកម្ម និងវិស័យសេវាកម្ម ដែលក្នុងនោះ វិស័យកសិកម្មមានកំណើនក្នុងអត្រា ២.០% វិស័យឧស្សាហកម្មមានកំណើនក្នុងអត្រា ១០.២% និងវិស័យសេវាកម្មមានកំណើនក្នុងអត្រា៦.៥%។ ម្យ៉ាងទៀតប្រទេសកម្ពុជា ជាប្រទេសមួយដែលមានធនធានធម្មជាតិដ៏សំបូរបែប និងជាប្រទេសដែលមានអាកាសធាតុអំណោយផលទៅដល់ការប្រកបរបរកសិកម្មផង ទើបជាហេតុនាំឱ្យរាជរដ្ឋាភិបាលយកចិត្តទុកដាក់លើវិស័យកសិកម្មជាខ្លាំង។ ក្នុងគំនិតនេះ បើយើងធ្វើការសិក្សាលម្អិតដោយក្រឡេកមើលសេដ្ឋកិច្ចជនបទ (ថ្នាក់ឃុំ ឬភូមិ) វិស័យទាំងបីនេះពិតជាជួយជម្រុញដល់កំណើនសេដ្ឋកិច្ចសហគមន៍ពិតប្រាកដមែន។ ដូចនេះការអភិវឌ្ឍសហគមន៍ គឺត្រូវតែមានការចូលរួមពីប្រជាជនសាមញ្ញឡើងទៅ និងអង្គការក្រៅរដ្ឋាភិបាលមួយចំនួនក្នុងការជំនះរាល់ឧបសគ្គទាំងឡាយដែលរួមមាន ការកសាងហេដ្ឋារចនាសម្ព័ន្ធ ប្រព័ន្ធធារាសាស្ត្រ វិស័យទំនាក់ទំនងផ្សេងៗដើម្បីធ្វើឱ្យមានកំណើនជីវភាពរស់នៅ

របស់ប្រជាជន។ ទន្ទឹមនឹងនេះការចូលរួមពីប្រជាពលរដ្ឋពិតជាជាប់ទាក់ទងជាមួយនឹងគោលដៅអភិវឌ្ឍន៍របស់រដ្ឋាភិបាលក្នុងការសម្រេចចិត្តនូវរាល់សកម្មភាពក្នុងការកំណត់អាទិភាព ការផ្តួចផ្តើមគំនិត អនុវត្តន៍សកម្មភាពជាដៃគូរ និងសកម្មភាពអភិវឌ្ឍន៍ផ្សេងៗ ក៏ដូចជាការរិះរកគ្រប់មធ្យោបាយដើម្បីដោះស្រាយរាល់បញ្ហាប្រឈមក្នុងការអភិវឌ្ឍសហគមន៍។ ហេតុនេះហើយ ក្នុងនាមយើងខ្ញុំជាអ្នកសិក្សាសេដ្ឋកិច្ចពិតជាចង់បាននូវការអភិវឌ្ឍប្រកបដោយចីរភាពដែលធ្វើឱ្យមានការកាត់បន្ថយនូវភាពក្រីក្ររបស់ប្រជាជន និងមិនផ្តល់ផលវិបាកក្នុងការរស់នៅនាពេលអនាគត។ ដូច្នេះយើងខ្ញុំបានសម្រេចជ្រើសយកនូវប្រធានបទ **ការអភិវឌ្ឍសហគមន៍** មកធ្វើការសិក្សា។

## ២. ចំណោទបញ្ហា

ក្នុងពេលបច្ចុប្បន្ននេះ រាជរដ្ឋាភិបាលកម្ពុជាបានខិតខំប្រឹងប្រែងយកចិត្តទុកដាក់ក្នុងការអភិវឌ្ឍ ក៏ដូចជាបង្កើតឱកាសឱ្យមានការចូលរួមជាសកម្មភាព ដើម្បីរិះរកគ្រប់មធ្យោបាយក្នុងការដោះស្រាយរាល់បញ្ហាដែលកើតមានឡើង និងធ្វើយ៉ាងណាឱ្យសុខុមាលភាពសហគមន៍ (សេដ្ឋកិច្ច សង្គម បរិស្ថាន និងវប្បធម៌) វិវត្តន៍ចេញពីសកម្មភាពរួមដែលត្រូវបានអនុវត្តនៅកម្រិតមូលដ្ឋានស្របជាមួយគំនិតផ្តួចផ្តើមតូចៗនៅក្នុងក្រុមរហូតដល់គំនិតផ្តួចផ្តើមធំៗដែលពាក់ព័ន្ធនឹងសហគមន៍ផ្ទាល់។

ដោយសារតែឃើញពីភាពរីកចម្រើនរបស់ប្រទេសកម្ពុជានាពេលកន្លងមក ក៏ដូចជាភាពយកចិត្តទុកដាក់របស់ប្រមុខដឹកនាំប្រទេសកម្ពុជាផង ដូច្នេះហើយនាំឱ្យសាធារណៈជន ព្រមទាំងរូបយើងខ្ញុំទាំងពីរនាក់បានចោទសួរជាសំណួរដូចតទៅ៖

- តើប្រជាជនក្នុងសហគមន៍នោះប្រកបមុខរបរអ្វី?
- តើរដ្ឋាភិបាលកម្ពុជាមានវិធីសាស្ត្របែបណា ក្នុងការជម្រុញឱ្យមានការអភិវឌ្ឍសហគមន៍?
- តើបញ្ហាអ្វីខ្លះដែលជាបញ្ហាចម្បងក្នុងការអភិវឌ្ឍសហគមន៍?
- តើគម្រោង ឬផែនការ និងការអនុវត្តក្នុងសហគមន៍មានដំណើរការយ៉ាងដូចម្តេច?
- តើការអភិវឌ្ឍនេះផ្តល់ឱកាសដល់ប្រជាជនដែលចូលរួមក្នុងការសម្រេចចិត្ត ថាតើត្រូវធ្វើអ្វីខ្លះ?
- តើធ្វើដូចម្តេចដើម្បីរកដំណោះស្រាយដ៏មានប្រសិទ្ធភាព និងស្របតាមលទ្ធិភាពដែលសហគមន៍អាចធ្វើទៅបាន?

## ៣. គោលបំណងនៃការស្រាវជ្រាវ

ការសិក្សាស្រាវជ្រាវលើប្រធានបទ "**ការអភិវឌ្ឍសហគមន៍**" គឺដោយសារចង់ស្វែងរកនូវបទពិសោធន៍ថ្មីៗដែលមានប្រសិទ្ធភាពក្នុងការដោះស្រាយរាល់បញ្ហានានាដែលកើតមាននៅក្នុងសង្គមជាពិសេសនៅក្នុងសហគមន៍ផ្ទាល់តែម្តង។ ដើម្បីសម្រេចបាននូវការស្រាវជ្រាវនេះ គឺត្រូវធ្វើឡើងក្នុងគោលបំណងដូចជា៖

- សិក្សាអំពីស្ថានភាពទូទៅនៃការអភិវឌ្ឍសហគមន៍
- សិក្សាអំពីតួនាទី និងរចនាសម្ព័ន្ធរបស់ថ្នាក់ដឹកនាំក្នុងសហគមន៍
- សិក្សាអំពីគម្រោងអភិវឌ្ឍន៍សហគមន៍ និងជំនួយពីស្ថាប័ននានា
- សិក្សាអំពីបញ្ហាប្រឈម ដំណោះស្រាយនានានៅក្នុងសហគមន៍ និងផ្តល់អនុសាសន៍ចំពោះការស្រាវជ្រាវ

## ៤. ទំហំ និងដែនកំណត់នៃការសិក្សាស្រាវជ្រាវនេះ

នៅក្នុងការសិក្សានេះយើងខ្ញុំបានធ្វើការជ្រើសរើសយកនូវសហគមន៍មួយដែលមានឈ្មោះថា សហគមន៍កសិកម្មសំបូរមានជ័យ ស្ថិតនៅភូមិសំបូរ ឃុំសូភាស ស្រុកស្ទឹងត្រង់ ខេត្តកំពង់ចាម ដោយផ្តោតទៅលើដើមទុនសរុបជាមធ្យមដែលសមាជិកក្នុងសហគមន៍ធ្វើការប្រកបរបរកសិកម្មចាប់ពីឆ្នាំ២០១៥ ដល់ ឆ្នាំ ២០១៩។

## ៥. វិធីសាស្ត្រនៃការស្រាវជ្រាវ

ដើម្បីសម្រេចលទ្ធផលនៃការសិក្សាស្រាវជ្រាវនេះយើងខ្ញុំបានប្រើប្រាស់វិធីសាស្ត្រស្រាវជ្រាវចំនួនពីរគឺ៖

- ការស្រាវជ្រាវគោល គឺជាការស្រាវជ្រាវដោយផ្ទាល់ដោយចុះជួបសម្ភាសន៍ និងប្រជុំដោយផ្ទាល់ជាមួយលោក **ឆេង ថុង** ដែលជាប្រធានសហគមន៍ និងលោក **ហ៊ាង ជ្រឹន** ជាអនុប្រធានគណៈកម្មការត្រួតពិនិត្យទូទៅ ព្រមទាំងជួបជាមួយសមាជិកនៅក្នុងសហគមន៍កសិកម្មសំបូរមានជ័យ។ មួយវិញទៀតធ្វើការសម្ភាសន៍ទៅដល់បងប្អូនប្រជាពលរដ្ឋដែលរស់នៅក្នុងសហគមន៍ផ្ទាល់ទាក់ទងទៅនឹងការប្រកបមុខរបរប្រចាំថ្ងៃ ស្ថានភាពដើមទុនជាមធ្យមដែលសមាជិកសហគមន៍ធ្វើការប្រកបរបរកសិកម្ម ព្រមទាំងសាកសួរអំពីជីវភាពរស់នៅរបស់បងប្អូនប្រជាពលរដ្ឋផ្ទាល់ និងបានបង្កើតជាកម្រងសំណួរមួយចំនួនដើម្បីធ្វើការប្រមូលទិន្នន័យដែលពាក់ព័ន្ធ។
- ការស្រាវជ្រាវបន្ថែម គឺជាការស្រាវជ្រាវដោយប្រយោលតាមរយៈការផ្តល់ឯកសារពីសំណាក់ប្រធានសហគមន៍ និងមួយផ្នែកប្រមូលពីសៀវភៅ ឯកសារ របាយការណ៍ដែលពាក់ព័ន្ធរួមមាន ឯកសារដែលបានចងក្រងកន្លងមករបស់សិស្សច្បង ឯកសារបោះពុម្ពទាក់ទងនឹងជំនាញសេដ្ឋកិច្ចអភិវឌ្ឍន៍ ឯកសារក្នុងបណ្ណាល័យនៃសាកលវិទ្យាល័យភូមិន្ទនីតិសាស្ត្រ និងវិទ្យាសាស្ត្រសេដ្ឋកិច្ច ឯកសាររបស់ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ ឯកសាររបស់ក្រសួងអភិវឌ្ឍន៍ជនបទ ឯកសារដែលធ្លាប់បានរៀនកន្លងមក និងឯកសារដែលដកស្រង់ចេញពីគេហទំព័រអ៊ីនធឺណែតមួយចំនួន។

## ៦. សារៈសម្ខាន់នៃការស្រាវជ្រាវ

សារៈសម្ខាន់នៃការស្រាវជ្រាវចំពោះប្រធានបទខាងលើមានដូចតទៅ៖

- យល់ដឹងពីទ្រឹស្តីនៃការអភិវឌ្ឍ ទ្រឹស្តីនៃសហគមន៍ និងទ្រឹស្តីមួយចំនួនទៀតដែលផ្សារភ្ជាប់ទៅនឹងការអភិវឌ្ឍសហគមន៍
- យល់ដឹងពីភាពខុសគ្នារវាងទ្រឹស្តី និងការអនុវត្តជាក់ស្តែង
- យល់ដឹងពីតួនាទីរបស់សហគមន៍
- យល់ដឹងអំពីសារៈសម្ខាន់នៃការអភិវឌ្ឍសហគមន៍
- កំណត់រកចំណុចខ្សោយ និងរកវិធានការដំណោះស្រាយ
- ផ្តល់ជាឯកសារសម្រាប់អ្នកសិក្សាស្រាវជ្រាវជំនាន់ក្រោយ

## ៧. រចនាសម្ព័ន្ធនៃការស្រាវជ្រាវ

នៅក្នុងការសិក្សាស្រាវជ្រាវបែបសារណានេះក្រុមយើងខ្ញុំបានបែងចែកជាបីជំពូកដែលមិនរាប់បញ្ចូលសេចក្តីផ្តើម សេចក្តីសន្និដ្ឋាន និងការផ្តល់អនុសាសន៍ឡើយ។ ចំណងជើងជំពូកទាំងបីរួមមាន៖

- ជំពូកទី១ ៖ ការសិក្សាលើទ្រឹស្តី និងទស្សនៈទានដែលពាក់ព័ន្ធ
- ជំពូកទី២ ៖ លក្ខណៈទូទៅ និងស្ថានភាពជុំវិញការអភិវឌ្ឍសហគមន៍កសិកម្មសំបូរមានជ័យក្នុង ភូមិសំបូរ ឃុំសូភាស ស្រុកស្ទឹងត្រង់ ខេត្តកំពង់ចាម
- ជំពូកទី៣ ៖ ការសិក្សាលើលទ្ធផលស្រាវជ្រាវ និងការវិភាគទិន្នន័យ

# ជំពូកទី១

# ការសិក្សាលើទ្រឹស្តី និងឯកសារដែលពាក់ព័ន្ធ

## ១.១ និយមន័យ

### ១.១.១ និយមន័យនៃការអភិវឌ្ឍ

ការអភិវឌ្ឍ ត្រូវបានគេឱ្យនិយមន័យខុសៗគ្នាដែលអាស្រ័យទៅតាមសម័យកាលនីមួយៗក្នុងការសិក្សាស្រាវជ្រាវរបស់អ្នកប្រាជ្ញ។ ប៉ុន្តែទោះជាយ៉ាងនេះក្តី ក៏អត្ថន័យរបស់វាត្រូវបានគេប្រើយ៉ាងទូលំទូលាយក្នុងការពិនិត្យមើលលើស្ថានភាពជាក់លាក់នៃការរីកចម្រើន និងដើម្បីពិពណ៌នាអំពីគំនិត ភាពជឿនលឿន ឬព្រឹត្តិការណ៍ដែលបង្ករឱ្យមានការផ្លាស់ប្តូរ ប៉ុន្តែនៅតែរក្សាបាននូវទិសដៅតែមួយដោយផ្តោតសម្ខាន់ទៅលើចំណុចបញ្ចប់នៃគម្រោងអភិវឌ្ឍន៍។ ពាក្យ អភិវឌ្ឍន៍ ត្រូវបានអ្នកស្រាវជ្រាវប្រើក្នុងន័យដូចជា៖

– **ការអភិវឌ្ឍ** គឺជាការកើនឡើងនូវកម្រិតរស់នៅ និងគុណភាពជីវិតរបស់ប្រជាជនក្នុងការបង្កើត ឬពង្រីកនូវចំណូលក្នុងតំបន់ព្រមទាំងឱកាសការងារដោយមិនធ្វើឱ្យខូចខាតដល់ធនធានធម្មជាតិ និងមិនប៉ះពាល់ដល់មនុស្សជំនាន់ក្រោយ។

– **ការអភិវឌ្ឍ** គឺជាដំណើរការមួយដែលបង្កើតឱ្យមានកំណើនវឌ្ឍនភាព ការផ្លាស់ប្តូរជាវិជ្ជមាន ឬការបន្ថែមផ្នែករូបវន្តសេដ្ឋកិច្ច បរិស្ថាន សង្គម និងវប្បធម៌។

– **ការអភិវឌ្ឍ** គឺជាការផ្សារភ្ជាប់ទៅនឹងការកើនឡើងនៃផលិតភាពពលកម្ម កម្រិតចំណេះដឹងរបស់ប្រជាជនការផ្លាស់ប្តូរបទពិសោធន៍ បច្ចេកទេសក្នុងការផ្តល់សេវាសុខភាពសាធារណៈ និងការអប់រំសម្រាប់ប្រជាជនទូទៅ។

### ១.១.២ និយមន័យនៃសហគមន៍

ពាក្យថា **សហគមន៍** ត្រូវបានគេផ្តល់និយមន័យជាច្រើនដោយយោងទៅតាមលក្ខខណ្ឌនានានៃកម្មវត្ថុជាសាវន្តែរបស់អ្នកប្រាជ្ញ និងស្ថាប័ននានា។ នៅក្នុងអក្សរសាស្ត្រខ្មែរចំពោះអត្ថន័យនៃពាក្យ **សហគមន៍** មានន័យថា ការទៅជាមួយ ដំណើរជាមួយគ្នា ប្រជុំគ្នា ឬអ្នកស្រុកធ្វើការប្រកបរបរចូលគ្នា។

– **សហគមន៍** គឺជាអង្គភាពដែលមានលក្ខណៈទូទៅជាបទដ្ឋានសាសនា គុណធម៌ ទំនៀមទំលាប់ ឬអត្តសញ្ញាណ។

– **សហគមន៍** គឺជាការចូលរួមជាក្រុមក្នុងការចែករំលែកភាសា ទំនៀមទំលាប់ គំនិត ជំនាញ និងសេវាកម្ម។

– **សហគមន៍** គឺជាបណ្តុំនៃប្រជាជនដែលរស់នៅក្នុងតំបន់ជាក់លាក់មួយធ្វើការជាមួយគ្នាយ៉ាងសកម្ម ដើម្បីសម្រេចបានគោលដៅរួមតែមួយ។

**១.១.២.១ លក្ខណៈនៃសហគមន៍**

អត្ថន័យនៃពាក្យ **សហគមន៍** អាចត្រូវបានយល់កាន់តែច្បាស់ ប្រសិនបើយើងវិភាគលើលក្ខណៈ ឬធាតុផ្សំរបស់វា។ ទោះជាយ៉ាងណា **សហគមន៍** មានធាតុផ្សំដូចជា៖

– ក្រុមមនុស្ស ៖ គឺជាធាតុផ្សំដែលមានសារៈសម្ខាន់បំផុតនៃសហគមន៍។ ក្រុមនេះអាចមានសមាជិកតិច ឬច្រើន ដោយធ្វើការប្រាស្រ័យទាក់ទងគ្នាទៅវិញទៅមក និងមានស្មារតីរួបរួមគ្នាតែមួយ។

– មូលដ្ឋានច្បាស់លាស់ ៖ គឺជាធាតុផ្សំបន្ទាប់ ពីព្រោះសហគមន៍ចាំបាច់ត្រូវតែជាតំបន់ (ទឹកដី) ច្បាស់លាស់ និងមិនមានការផ្លាស់ប្តូរ។

– មនោសញ្ចេតនាក្នុងសហគមន៍ ៖ គឺជាធាតុផ្សំសម្ខាន់មួយទៀតរបស់សហគមន៍។ ពីព្រោះបើគ្មានមនោសញ្ចេតនាទេ សហគមន៍មិនអាចបង្កើតបានជាក្រុមមួយដែលមានមូលដ្ឋានច្បាស់លាស់បានឡើយ។ មនោសញ្ចេតនាសហគមន៍សំដៅលើអារម្មណ៍ដែលគួរឱ្យស្ញប់ស្ញែងចំពោះសមាជិកដែលមានការរួបរួមគ្នាក្នុងការរស់នៅជាធម្មតាក្នុងមូលដ្ឋានរបស់ពួកគេ។

– ធម្មជាតិ ៖ គឺជាការរៀបចំឡើងតាមបែបធម្មជាតិ។ វាមិនមែនជាលទ្ធផលនៃឆន្ទៈរបស់មនុស្សទេ ហើយក៏មិនមែនជាការបង្កើតឡើងដោយសកម្មភាពរបស់រាជរដ្ឋាភិបាលដែរ ប៉ុន្តែវាលូតលាស់ដោយឯកឯង គឺបានក្លាយជាសមាជិកដោយកំណើត។

– អចិន្ត្រៃយ៍ ៖ គឺសំដៅទៅលើការរស់នៅជារៀងរហូតរបស់បុគ្គលម្នាក់ៗនៅលើទឹកដីរបស់ខ្លួន។

– ភាពស្រដៀងគ្នា ៖ គឺសំដៅដល់សមាជិកនៃសហគមន៍មានភាពស្រដៀងគ្នាតាមវិធីណាមួយ។ នៅពេលពួកគេរស់នៅក្នុងតំបន់ដែលមានការកំណត់ច្បាស់លាស់ និងមានដំណើរជីវិតរួម នោះពួកគេនឹងមានការចែករំលែកនូវរឿងរ៉ាវជាទូទៅមួយចំនួនអោយគ្នាទៅវិញទៅមក។ ភាពស្រដៀងគ្នារួមមាន ភាសា ទំនៀមទំលាប់ ប្រពៃណី និងរឿងជាច្រើនទៀត។

**១.១.៣ និយមន័យនៃការអភិវឌ្ឍសហគមន៍**

ការអភិវឌ្ឍសហគមន៍ គឺជាដំណើរការរួមមួយដែលមានសមាជិកសហគមន៍ជាអ្នកទទួលបានការគាំទ្រដោយទីភ្នាក់ងារដើម្បីកំណត់ និងចាត់វិធានការសមូហភាពលើបញ្ហាដែលមានសារៈសម្ខាន់សំរាប់ពួកគេ។ ការអភិវឌ្ឍសហគមន៍គឺជាវិជ្ជាជីវៈដោយផ្អែកលើការអនុវត្ត និងវិន័យអប់រំដែលជម្រុញលទ្ធិប្រជាធិបតេយ្យក្នុងការចូលរួមអភិវឌ្ឍន៍ប្រកបដោយនិរន្តរភាព សមធម៌ និងយុត្តិធម៌តាមរយៈការកាត់បន្ថយភាពក្រីក្រ

ក្នុងការធ្វើយ៉ាងណាអោយគម្លាតរវាងអ្នកមាន និងអ្នកក្រសមល្មមដែលអាចទទួលយកបាន ព្រមទាំងលើកកម្ពស់ស្ត្រីក្នុងការធានាបាននូវសមភាពយេនឌ័រក្នុងសង្គមតាមរយៈការរៀបចំ ការអប់រំ ការផ្តល់សិទ្ធអំណាចដល់ប្រជាជន រួមទាំងបង្កើតទំនាក់ទំនងនៅក្នុងសហគមន៍ឱ្យកាន់តែរឹងមាំ ព្រមទាំងរួមបញ្ចូលនូវដំណោះស្រាយ និងសកម្មភាពទាំងឡាយណាដែលមានគោលបំណងធ្វើឱ្យប្រសើរឡើងនូវសុខុមាលភាព និងជីវភាពរស់នៅរបស់ប្រជាជនតាមទីជនបទ ក៏ដូចជានៅតាមទីដាច់ស្រយាល ដើម្បីនាំមកនូវការរីកចម្រើនជឿនលឿនកែប្រែឱ្យមានភាពប្រសើរឡើងជាលំដាប់។

## ១.២ ទស្សនរបស់អ្នកប្រាជ្ញ

### ១.២.១ ទ្រឹស្តីនៃការអភិវឌ្ឍ

ទ្រឹស្តីជាច្រើនត្រូវបានបង្កើតឡើងដោយអ្នកប្រាជ្ញសេដ្ឋកិច្ច ដើម្បីពន្យល់បកស្រាយអំពីដំណើរការនៃការអភិវឌ្ឍ និងវិសមភាពដែលកើតមានឡើងក្នុងប្រទេសកំពុងអភិវឌ្ឍន៍ដើម្បីធ្វើឱ្យមានភាពប្រសើរឡើង និងសម្រេចបាននូវការអភិវឌ្ឍ។

#### ១.២.១.១ ទ្រឹស្តីលោក Micheal P.Todaro

បើតាមលោក Micheal P.Todaro បានយល់ឃើញថាការអភិវឌ្ឍអាចកើតមានឡើង និងប្រកបដោយចីរភាពត្រូវចាប់ផ្តើមឡើងពីសហគមន៍ក្នុងតំបន់ជនបទ ជាពិសេសក្នុងវិស័យកសិកម្ម ហើយប្រទេសមួយអាចឈានទៅរកការអភិវឌ្ឍ និងជឿនលឿនទៅបានយ៉ាងហោចណាស់ត្រូវតែមានប្រាំចំណុចដូចខាងក្រោម៖

- បង្កើននូវតម្រូវការក្នុងស្រុកសម្រាប់ផលិតផលកសិកម្មដែលមានប្រភពច្បាស់លាស់មកពីយុទ្ធសាស្ត្រអភិវឌ្ឍន៍ការងារក្នុងតំបន់សហគមន៍។
- ពន្លឿនការនាំចេញ (Out Put ) តាមរយៈការធ្វើកំណែទម្រង់ស្ថាប័ន និងបច្ចេកវិទ្យាដែលត្រូវបានរៀបចំឡើងដើម្បីបង្កើនផលិតភាពសំរាប់កសិករតូចតាច។
- សកម្មភាពអភិវឌ្ឍសហគមន៍ដើម្បីពង្រីកកម្លាំងពលកម្ម និងវិស័យផ្សេងៗទៀតដែលគាំទ្រដោយផ្ទាល់ ឬដោយប្រយោលពីស្ថាប័នពាក់ព័ន្ធនានា។
- បង្កើនភាពដែលអាចរកបាន និងពង្រីកការចែកចាយ បែងចែកទំនិញដែលទ្រទ្រង់ដល់ជីវិតដូចជាអាហារ កន្លែងស្នាក់នៅ និងសុខភាព។
- ជម្រុញតម្លៃសេដ្ឋកិច្ច ក្នុងការជ្រើសរើសរបស់សង្គមដែលអាចទទួលយកបានជាលក្ខណៈបុគ្គល និងជាលក្ខណៈជាតិដោយធ្វើឱ្យពួកគេរួចផុតពីភាពអវិជ្ជា និងទុគិតភាពក្នុងការទាក់ទងទៅកាន់មនុស្សដទៃព្រមទាំងជម្រុញអោយពួកគេរួចផុតពីអនិស្សរភាព និងសេវគតិភាពទៀតផង។

**១.២.១.២ ទ្រឹស្តីលោក** Walt Withman Rostow

លោក Walt Withman Rostow បានវែកញែកដំណាក់កាលសម្ខាន់ៗ ក្នុងការអភិវឌ្ឍជាបួនដំណាក់កាលដោយលោកអះអាងថាគ្រប់ប្រជាជាតិទាំងអស់អាចឈានទៅដល់ចំណុចអភិវឌ្ឍបានរួមមានៈ

**ក.ដំណាក់កាលបែបប្រពៃណី** ៖ គឺជាសង្គមដែលគ្មានកំណើនទាល់តែសោះដោយប្រជាជនប្រកបរបរកសិកម្មជាលក្ខណៈគ្រួសារ ប្រមាញ់សត្វចិញ្ចឹមជីវិត និងការរស់នៅបែបប្រមូលផ្តុំហើយធ្វើការផលិតឡើងតាមបែបរៀងៗខ្លួន ដោយពួកគេមិនមានគំនិតក្នុងផ្លាស់ប្តូរអ្វីៗទាំងអស់ គឺបណ្តោយទៅតាមយថាកម្ម។

**ខ.ដំណាក់កាលដែលធ្វើអោយមានការអភិវឌ្ឍ** ៖ គឺជាការដែលធ្វើឱ្យមានផលចំណេញដល់សង្គមការផ្លាស់ប្តូររចនាសម្ព័ន្ធសេដ្ឋកិច្ច កែលម្អ ពង្រីកប្រព័ន្ធហេដ្ឋារចនាសម្ព័ន្ធ ប្រព័ន្ធថាមពលប្រព័ន្ធផ្គត់ផ្គង់ទឹក ការពង្រីកវិស័យកសិកម្ម ការធ្វើឱ្យប្រសើរឡើងផ្នែកបច្ចេកវិទ្យា និងការធ្វើឱ្យប្រជាជនមានភាពជាម្ចាស់កម្មសិទ្ធិលើអចលនវត្ថុ ព្រមទាំងធ្វើឱ្យមានការកើនឡើងនៃអត្រាសន្សំ វិនិយោគមកលើប្រទេសដែលស្ថិតនៅអន្តរការនៃការអភិវឌ្ឍ។

**គ.ដំណាក់កាលនៃការកើនឡើងការអភិវឌ្ឍ** ៖ គឺជាការកើនឡើងនូវភាពខ្លាំងនៃអត្រាវិនិយោគអាទិភាពនយោបាយ ស្ថាប័នដែលនាំអោយមានកំណើន។ ប្រទេសដែលអាចចាត់ទុកបានថាជាប្រទេសដែលមានឧស្សាហកម្មថ្មីត្រូវមានពីរចំណុចដូចជាៈ

- វិស័យអាទិភាពនៃសេដ្ឋកិច្ចមានការកើនឡើង និងរីកធំធាត់ជាលំដាប់
- កំណើនសេដ្ឋកិច្ចបានក្លាយទៅជាបញ្ហាសាមញ្ញ និងអាចរក្សាបានដោយស្វ័យប្រវត្តិនូវស្ថេរភាពសេដ្ឋកិច្ច។

**ឃ.ដំណាក់កាលបម្រើបម្រាស់** ៖ គឺជាការផលិតទំនិញ និងសេវាកម្មក្នុងគោលបំណងប្រើប្រាស់ចុងក្រោយ។ ដំណាក់កាលនេះបានធ្វើឱ្យអំណាចសេដ្ឋកិច្ចត្រូវបានពង្រីកក្នុងពេលដែលមានការអភិវឌ្ឍលើវិស័យសុខមាលភាពសង្គម និងមានសេចក្តីត្រូវការជាមូលដ្ឋានដែលត្រូវដោះស្រាយបានជាស្ថាពរ។

**១.២.២ ទ្រឹស្តីនៃការអភិវឌ្ឍសហគមន៍**

លោក Allison Tan យល់ឃើញថា **ការអភិវឌ្ឍសហគមន៍** គឺជាក្របខណ្ឌដែលប្រជាជនក្នុងសហគមន៍បានរៀបចំឡើងសម្រាប់ការធ្វើផែនការក្នុងការដោះស្រាយនូវបញ្ហារបស់ពួកគេ ដោយពឹងផ្អែកទៅលើធនធានសហគមន៍ ឬទទួលការផ្តល់ជំនួយពីខាងរដ្ឋាភិបាល និងទីភ្នាក់ងារក្រៅរដ្ឋាភិបាល ដើម្បីជម្រុញឱ្យមានផលចំណេញទាំងខាងសេដ្ឋកិច្ច និងសង្គម។ លោកបន្ថែមទៀតថា ការអភិវឌ្ឍសហគមន៍ ត្រូវបានផ្អែកលើសារៈសម្ខាន់ និងសមត្ថភាពរបស់ប្រជាជនក្នុងការធ្វើសកម្មភាពរួមគ្នាដើម្បីមានសិទ្ធគ្រប់គ្រាន់ក្នុងការគ្រប់គ្រងលើបញ្ហាសង្គម សេដ្ឋកិច្ច នយោបាយដែលជះឥទ្ធិពលទៅដល់ពួកគេ។ ក្នុងន័យនេះ Allison

Tan បានបញ្ជាក់ផងដែរថា ការអភិវឌ្ឍសហគមន៍ ផ្តោតលើទំនាក់ទំនងរវាងប្រជាជន និងអ្នកធ្វើសេចក្តីសម្រេចចិត្ត(សាធារណៈជន និងឯកជន) ។

**១.២.២.១ ទ្រឹស្តីលោក** Julian Rappaport

លោក Julian Rappaport បានលើកឡើងពីទ្រឹស្តីពង្រឹងអំណាចក្នុងការអភិវឌ្ឍសហគមន៍ដោយលោកសំដៅទៅលើបទពិសោធន៍នៃការរីកចម្រើនផ្ទាល់ខ្លួន និងការកែលម្អខ្លួនឯងដែលធ្វើឱ្យកើតចេញជាលទ្ធផលនៃការអភិវឌ្ឍសមត្ថភាព និងជំនាញក្នុងការផ្តល់សិទ្ធអំណាច ការផ្តួចផ្តើមគំនិត និងការរួមបញ្ចូលគ្នាដើម្បីឈានទៅរកការផ្លាស់ប្តូរ។ ទ្រឹស្តីនេះអាចត្រូវបានអនុវត្តចំពោះការអភិវឌ្ឍសហគមន៍ ដោយផ្តល់អំណាចដល់ប្រជាជនមានសិទ្ធធ្វើការអភិវឌ្ឍសហគមន៍របស់ពួកគេដោយផ្ទាល់បាន។

**១.២.២.២ ទ្រឹស្តីលោក** Urie Bronfenbrenner

លោក Urie Bronfenbrenner បានលើកឡើងពីទ្រឹស្តីប្រព័ន្ធអេកូឡូស៊ី ដោយលោកបានលើកយកនូវទម្រង់ជាប្រព័ន្ធទូទៅដែលមានភាពស៊ីសង្វាក់គ្នាជាមួយទំនាក់ទំនងក្នុងចំណោម "អង្គភាពរស់នៅ" និង "អង្គភាពផ្សេងទៀតនៃបរិស្ថានរបស់ពួកគេ"។ ទ្រឹស្តីនេះអាចត្រូវបានអនុវត្តចំពោះការអភិវឌ្ឍសហគមន៍ដោយឆ្លងកាត់បរិស្ថាន ពីព្រោះអ្នកដែលធ្វើការអភិវឌ្ឍត្រូវពិនិត្យមើលបរិស្ថានជុំវិញជាមុនសិនដើម្បីសាងសង់ទៅបានប្រកបដោយជោគជ័យ និងប្រសិទ្ធភាព។

**១.២.២.៣ ទ្រឹស្តីលោក** Auguste Comte

លោក Auguste Comte បានលើកឡើងនូវទ្រឹស្តីវិជ្ជមានដែលជាមូលដ្ឋានគ្រឹះនៃការអះអាងរបស់សង្គមវិទ្យាទៅនឹងគំរូវិទ្យាសាស្ត្រដោយវាស់ស្ទង់ទៅលើឥរិយាបថរបស់មនុស្សជាញឹកញាប់មានការវិវត្ត និងមានការព្រួយបារម្ភតិចតួចចំពោះទិដ្ឋភាពអារម្មណ៍អរូបិយ។ ទ្រឹស្តីនេះមានមូលដ្ឋានគ្រឹះក្នុងការគិតបែបឌីកូតូម៉ុល។ Dichotomous ក៏ដូចជាទស្សនៈវិជ្ជា ប៊ួហ្គូស (Bourgeouis) ដែលមើលជាក់ស្តែងលើវិទ្យាសាស្ត្រពិត ដើម្បីក្លាយជាប្រភពចំណេះដឹងពិត ហើយអនុវត្តន៍នូវការរៀបចំសហគមន៍មួយដែលមិនមែនសម្រាប់តែបុគ្គលម្នាក់ទេ ប៉ុន្តែជាកម្មវត្ថុដែលត្រូវដោះស្រាយរាល់បញ្ហាដែលបានកើតឡើង។ ប្រសិនបើសមាជិកសហគមន៍មិនមានគំនិតក្នុងការដោះស្រាយបញ្ហាដែលកើតមានឡើងចំពោះមុខទេ នោះពួកគេនឹងទទួលរងនូវផលប៉ះពាល់ដោយធ្វើឱ្យមានការផ្លាស់ប្តូរសក្តានុពល។ ប៉ុន្តែប្រសិនបើបញ្ហានោះកើតឡើងក្នុងកម្រិតខ្ពស់ អ្នកគ្រប់គ្រងត្រូវមើលទៅលើបុគ្គលម្នាក់នោះផ្ទាល់ ហើយសម្រេចចិត្តថា តើបុគ្គលនោះមានសមត្ថភាពអាចដោះស្រាយបញ្ហាបាន ឬអត់ ដោយមិនចាំបាច់ផ្តល់ការពិភាក្សាជាមួយពួកគេ។

**១.២.២.៤ ទ្រឹស្តីលោក** Rober T. Craig

លោក Rober T.Craig បានលើកឡើងនូវទ្រឹស្តីទំនាក់ទំនងក្នុងការពិនិត្យមើលទៅលើមនុស្សណាដែលមានទំនួលខុសត្រូវលើខ្លួនឯង និងចេះសម្របទៅតាមបរិស្ថានជុំវិញក្នុងពេលដែលមានការផ្លាស់ប្តូរអ្វីថ្មីមួយដោយពួកគេអាចធ្វើការដោះស្រាយបានទៅតាមកាលៈទេសៈ។ ទ្រឹស្តីនេះអាចអនុវត្តជាក់ស្តែងបានចំពោះការអភិវឌ្ឍសហគមន៍ដោយអ្នកអភិវឌ្ឍន៍ផ្ទាល់ត្រូវតែមានទំនាក់ទំនងជាមួយមនុស្សនៅក្នុងសហគមន៍ដើម្បីបានដឹងអំពីអ្វីដែលពួកគេចង់បាន ឬអ្វីដែលពួកគេចង់ធ្វើការផ្លាស់ប្តូរ។

**១.២.២.៥ ទ្រឹស្តីលោក** Mabud Vi-Haq

លោក Mabud Vi-Haq បានលើកឡើងថា ការដែលបង្រៀនឱ្យយល់ដឹងពាក់ព័ន្ធនឹងផលិតផលជាតិសរុប គឺជាដំណោះស្រាយក្នុងការកាត់បន្ថយនូវភាពក្រីក្រ។ ការអភិវឌ្ឍនឹងក្លាយជាគ្មានគុណតម្លៃ ប្រសិនបើវាគ្រាន់តែសម្រេចបាននូវការកើនឡើងផលិតផលសរុបរបស់ប្រទេសមួយ។ យើងត្រូវប្រឈមមុខនឹងការពិតថាការអភិវឌ្ឍមានន័យ ប្រសិនបើវាអាចដោះស្រាយនូវតម្រូវការសង្គម និងធ្វើឱ្យប្រសើរឡើងនូវគុណភាពជីវិតរបស់ប្រជាជន ការកើនឡើងនូវផលិតកម្ម ឬការរីកចម្រើនសេដ្ឋកិច្ច ដើម្បីសម្រេចបាននូវគោលដៅអភិវឌ្ឍន៍នៃប្រជាជន។ ការអភិវឌ្ឍត្រូវធ្វើឡើងដោយព្រមគ្នាទាំងបីផ្នែក គឺសេដ្ឋកិច្ច បុគ្គល និងសង្គមៈ

**ក.សេដ្ឋកិច្ច** ៖ សំដៅលើការបង្កើនប្រាក់ចំណូលដើម្បីទ្រទ្រង់ជីវភាពគ្រួសារ។

**ខ.បុគ្គល** ៖ សំដៅលើការអភិវឌ្ឍស្មារតីរបស់បុគ្គលម្នាក់ឱ្យគាត់បានយល់នូវអ្វីដែលជាប្រយោជន៍រួមសម្រាប់សហគមន៍ដែលពួកគាត់រស់នៅ។

**គ.សង្គម** ៖ សំដៅទៅលើការបង្កើនការយល់ដឹងជាសមូហភាពសម្រាប់សមាជិកសហគមន៍ទាំងអស់។

**១.២.២.៦ ទ្រឹស្តីលោក** Michael Jacoby Brown

លោក Michael Jacoby Brown បានលើកឡើងនូវទ្រឹស្តី ការអភិវឌ្ឍសហគមន៍ប្រកបដោយថាមពលដោយធ្វើការកំណត់លើបញ្ហាដែលកើតឡើងនៅក្នុងសហគមន៍ ដោយសារតែឥទ្ធិពលនៃអំណាច គឺអាចនិយាយបានថាជាមនុស្សដែលមានអំណាចក្នុងការគ្រប់គ្រងជីវិតអ្នកដទៃ គ្រប់គ្រងលើជីវិតការងាររបស់អ្នកដទៃសាលារៀន និងបរិស្ថាននៅជុំវិញរបស់ពួកគេ។ អំណាចនេះរួមបញ្ចូលទាំងការគ្រប់គ្រងនូវអ្វីដែលមនុស្សភាគច្រើនត្រូវតែចំណាយសម្រាប់ភាពចាំបាច់នៃជីវិតដូចជា ៖ ការថែទាំសុខភាព ការដឹកជញ្ជូន លំនៅដ្ឋានសមរម្យ ការអប់រំ អគ្គិសនី និងស្បៀងអាហារ។

## ១.៣ ទស្សនវិស័យនៃការអភិវឌ្ឍសហគមន៍

ទស្សនវិស័យនៃការអភិវឌ្ឍសហគមន៍ គឺចង់ធ្វើការកែប្រែសហគមន៍មួយដែលមានសមាជិកខ្វះខាតដើមទុនសម្រាប់ការប្រកបរបរកសិកម្មឱ្យក្លាយទៅជាមានដើមទុនគ្រប់គ្រាន់ក្នុងការប្រកបរបរកសិកម្មវិញ។

### ១.៣.១ គោលបំណងនៃការអភិវឌ្ឍសហគមន៍

គោលបំណងនៃការអភិវឌ្ឍសហគមន៍ គឺដើម្បីដោះស្រាយរាល់បញ្ហាដែលទាក់ទងទៅនឹងភាពក្រីក្រ ភាពមិនចេះអក្សរ ភាពមានជម្ងឺ ភាពអសកម្ម ការបែងចែកធនធានមិនបានត្រឹមត្រូវ មិនមានកំណើនសេដ្ឋកិច្ច ដែលប្រកបទៅដោយសមធម៌ និរន្តភាព និងការរើសអើងជាតិសាសន៍រវាងប្រជាពលរដ្ឋដែលរស់នៅក្នុងសហគមន៍ ព្រមទាំងជម្រុញការអភិវឌ្ឍភូមិសាស្ត្រសហគមន៍ឱ្យមានការរីកចម្រើនទៅលើសុខភាពសាធារណៈ ការដឹកជញ្ជូន អគ្គីសនីប្រើប្រាស់ អ៊ីនធឺណែត លំនៅស្ថានល្អប្រសើរជាងមុន សង្រ្គាម ឬឧក្រិដ្ឋកម្មតិចជាងមុន កាត់បន្ថយគ្រឿងញៀន ឱកាសការងារមានកាន់តែច្រើន មានមធ្យោបាយទំនាក់ទំនងឆាប់រហ័សជាងមុនដើម្បីបង្ហាញពីការគោរព និងភាពចេះជួយគ្នាទៅវិញទៅមក។ ដូច្នេះហើយទើបរាជរដ្ឋាភិបាលមានការបង្កើនការយកចិត្តទុកដាក់ជាខ្លាំងដើម្បីឱ្យមានការអភិវឌ្ឍដែលប្រកបដោយចីរភាព។ សកម្មភាពទាំងអស់នេះបានឆ្លុះបញ្ចាំងពីគោលបំណងនៃការអភិវឌ្ឍសហគមន៍ដូចទៅៈ

– ទី១ ៖ ជម្រុញការចូលរួម និងធ្វើជាតំណាងឱ្យប្រជាពលរដ្ឋមានឥទ្ធិពលលើការសម្រេចចិត្តរាល់បញ្ហាដែលធ្វើអោយប៉ះពាល់ដល់ពួកគេ។

– ទី២ ៖ ចូលរួមជាមួយសមាជិកសហគមន៍ក្នុងការវិនិច្ឆ័យលើបញ្ហាដែលកើតមានដើម្បីឱ្យបុគ្គលដែលរងនូវផលប៉ះពាល់បានយស់ច្បាស់អំពីស្ថានភាពដែលកើតឡើង។

– ទី៣ ៖ ចូលរួមពន្យល់ណែនាំដល់សមាជិកសហគមន៍ឱ្យយល់ពីផលប៉ះពាល់សេដ្ឋកិច្ច សង្គមនយោបាយ និងបរិស្ថាន។

– ទី៤ ៖ ចូលរួមជួយដល់សមាជិកសហគមន៍ក្នុងការអនុវត្តផែនការដើម្បីដោះស្រាយបញ្ហាដែលបានព្រមព្រៀងគ្នាដោយសង្កត់ធ្ងន់ទៅលើការដឹកនាំរួមគ្នា និងចូលរួមជាសកម្មពីសំណាក់ប្រជាពលរដ្ឋក្នុងសហគមន៍។

– ទី៥ ៖ ស្វែងរកចំណុចណាមួយដែលទំនងជាជះឥទ្ធិពលអាក្រក់ដល់ផ្នែកទន់ខ្សោយក្នុងសហគមន៍។

– ទី៦ ៖ ធ្វើការយ៉ាងសកម្មដើម្បីបង្កើនសមត្ថភាព ភាពជាអ្នកដឹកនាំ ភាពជឿជាក់ និងសេចក្តីត្រូវការក្នុងដំណើរការអភិវឌ្ឍសហគមន៍។

– ទី៧ ៖ បង្កើនប្រព័ន្ធគមនាគមន៍ ដើម្បីអោយផលិតផលមានចរន្តចេញចូល។

– ទី៨ ៖ បង្កើតការងារធ្វើដល់ប្រជាជន ដើម្បីកុំអោយពួកគេធ្វើការចំណាកស្រុក។

– ទី៩ ៖ ផ្តល់ឱកាសឱ្យប្រជាពលរដ្ឋ ក្នុងការប្រើប្រាស់សិទ្ធិរបស់ខ្លួននៅក្នុងសហគមន៍

សរុបមកគោលបំណងនៃការអភិវឌ្ឍសហគមន៍ គឺចង់ឱ្យប្រជាពលរដ្ឋទទួលបាននូវជីវភាពល្អប្រសើរមានសុខភាព និងអនាម័យត្រឹមត្រូវ ព្រមទាំងមានឱកាសយល់ដឹងកាន់តែច្បាស់អំពីចំណេះដឹងមួយចំនួន

ផ្សេងទៀត និងសារៈសម្ខាន់នៃការថែរក្សា អភិរក្ស ការពារធម្មជាតិទាំងឡាយណាដែលមាននៅក្នុងសហគមន៍ ដើម្បីជម្រុញឱ្យសេដ្ឋកិច្ចប្រទេសជាតិមានការរីកចម្រើន។

### ១.៣.២ គោលការណ៍នៃការអភិវឌ្ឍសហគមន៍

គោលការណ៍នៃការអភិវឌ្ឍសហគមន៍នេះចែកចេញជាប្រាំពីរចំណុចដែលក្នុងនោះរួមមាន ការផ្តល់អំណាច ការរៀនពីជីវិត ការកំណត់បញ្ហា ការកំណត់អត្តសញ្ញាណអ្នកពាក់ព័ន្ធ ការកំណត់វិធីសាស្រ្ត ការកំណត់ធនធាន និងការអនុវត្ត។

**ក.ការផ្តល់អំណាច** ៖ ជាដំណើរការមួយដែលមានការគោរព មានគុណតម្លៃ និងពង្រឹងនូវសមត្ថភាពរបស់មនុស្សដើម្បីបំពេញនូវតម្រូវការរបស់ពួកគេ និងស្មារតីនៅក្នុងការយល់ឃើញដោយខ្លួនឯង ហើយក៏បង្ហាញពីវិធីសាស្រ្តដែលធ្វើឱ្យមានគុណប្រយោជន៍នៃជំនាញ បទពិសោធន៍ និងសក្តានុពល។

**ខ.ការរៀនពីជីវិត** ៖ ជាការបញ្ចូលគ្នានូវគ្រប់រូបភាពទាំងអស់នៃសកម្មភាពកណ្តាលដូចជា ការបង្កើននូវចំណេះដឹង ការគាំទ្រនូវជំនាញ និងសមត្ថភាពដែលមិនចេះចុះញមរបស់មនុស្ស។ ពួកគេបានពង្រឹងនូវសុខភាព ការទំនាក់ទំនងគ្នាតាមរយៈវិធីសាស្រ្តជាផ្លូវការ និងមិនផ្លូវការនៅក្នុងការសិក្សាអប់រំ ការស្វែងយល់ បទពិសោធន៍និងការអភិវឌ្ឍខ្លួនឯង។

**គ.ការកំណត់បញ្ហា** ៖ ជាវិធីសាស្រ្តផ្លូវការ និងមិនផ្លូវការដែលត្រូវបានប្រើដើម្បីកំណត់បញ្ហាដែលកើតមានឡើងក្នុងសហគមន៍។

**ឃ.ការកំណត់អត្តសញ្ញាណអ្នកពាក់ព័ន្ធ** ៖ ជាការចូលរួមជាមួយសហគមន៍ ឬអង្គការដែលពាក់ព័ន្ធនានាដើម្បីជួយដល់ប្រជាពលរដ្ឋដែលជួបប្រទះបញ្ហា។

**ង.ការកំណត់វិធីសាស្រ្ត** ៖ ជាការចូលរួមសហគមន៍ ដើម្បីពិភាក្សាអំពីបញ្ហានានា ក្នុងការស្រាវជ្រាវលើបញ្ហាដែលពាក់ព័ន្ធ និងធ្វើការដោះស្រាយតាមរយៈការកំណត់នូវគោលដៅរួមតែមួយ។

**ច.ការកំណត់ធនធាន** ៖ ជាការកំណត់អត្តសញ្ញាណធនធានមូលដ្ឋាន និងសាច់ប្រាក់ក្នុងតំបន់ក្នុងការភ្ជាប់ជាមួយនឹងធនធានដទៃទៀត ដើម្បីអនុវត្តន៍វិធីសាស្រ្តជាក់លាក់របស់សហគមន៍។

**ឆ.ការអនុវត្ត** ៖ ជាកិច្ចសហប្រតិបត្តិការជាមួយសហគមន៍ដើម្បីអនុវត្តន៍វិធីសាស្រ្ត ដោយសង្កត់ធ្ងន់ទៅលើការដឹកនាំ និងការសហការរួម។

សរុបមក គោលការណ៍នៃការអភិវឌ្ឍសហគមន៍ គឺចង់ឱ្យប្រជាពលរដ្ឋដែលរស់នៅក្នុងសហគមន៍ទាំងមូលទទួលបាននូវផលប្រយោជន៍ជាច្រើន និងទទួលបានសិទ្ធក្នុងការសម្រេចចិត្តលើបញ្ហាដែលជះឥទ្ធិពលដល់ស្ថានភាពរស់នៅរបស់ពួកគេ ក៏ដូចជាធ្វើយ៉ាងណាឱ្យប្រជាពលរដ្ឋអាចអភិវឌ្ឍន៍ខ្លួនឯង និងក្រុមគ្រួសារបានផងដែរ។

### ១.៣.៣ មូលហេតុនៃការអភិវឌ្ឍសហគមន៍

ការយល់ដឹងរបស់ប្រជាជននៅតាមទីជនបទ ឬតំបន់ដាច់ស្រាយាលនៅមានកម្រិតនៅឡើយ។ ចំណែកកម្រិតនៃនិកម្មភាពខ្ពស់ និងភាពគ្មានការងារធ្វើគ្រប់គ្រាន់ (ដោយសារតែការងារនោះមិនបានប្រើប្រាស់ជំនាញរបស់កម្មករឱ្យអស់ពីលទ្ធភាព ឬប្រើប្រាស់កម្មករឱ្យធ្វើការងារដែលផ្ទុយពីជំនាញរបស់ពួកគេ) និងគ្មានឱកាសក្នុងការស្វែងរកការងារធ្វើដើម្បីបង្កើតប្រាក់ចំណូល ឬគ្មានឱកាសក្នុងការចូលរួមនយោបាយ និងការអប់រំជាដើម។ ហេតុដូចនេះហើយទើបរាជរដ្ឋាភិបាល ក៏ដូចជាអង្គការក្រៅរដ្ឋាភិបាលមួយចំនួនជម្រុញឱ្យមានការអភិវឌ្ឍសហគមន៍ ដើម្បីបង្កើនឱ្យមានការកើនឡើងនូវជីវភាពរបស់ប្រជាជនក្នុងតំបន់។

### ១.៣.៤ វដ្តនៃការអភិវឌ្ឍសហគមន៍

វដ្តនៃការអភិវឌ្ឍសហគមន៍ គឺជាវិធីនៃការអភិវឌ្ឍលើវិស័យណាមួយ នៅទីកន្លែងណាមួយពិតប្រាកដ។

រូបភាពទី ១ ៖ បង្ហាញពីវដ្តនៃការអភិវឌ្ឍសហគមន៍



## ១.៤ គោលនយោបាយរបស់រដ្ឋាភិបាលក្នុងការអភិវឌ្ឍសហគមន៍

### ១.៤.១ លក្ខណៈទូទៅ

គោលនយោបាយអភិវឌ្ឍសហគមន៍ គឺជាយន្តការមួយដែលបញ្ចេញសកម្មភាពដោយផ្ទាល់ជាមួយសហគមន៍មូលដ្ឋានដែលសំដៅដល់ការធ្វើឱ្យមានការផ្លាស់ប្តូរអាកប្បកិរិយា ឥរិយាបទ និងផ្នត់គំនិតរបស់ប្រជាសហគមន៍នៅតាមទីជនបទដើម្បីធ្វើការអភិវឌ្ឍមួយឆ្ពោះទៅរកភាពរីកចម្រើននិងប្រកបដោយនិរន្តភាព។ សកម្មភាពអភិវឌ្ឍសហគមន៍បានចូលរួមយ៉ាងសម្ខាន់ក្នុងការអនុវត្តគោលនយោបាយវិមជ្ឈការ វិសហមជ្ឈការ និងការអភិវឌ្ឍតាមបែបប្រជាធិបតេយ្យថ្នាក់ក្រោមជាតិរបស់រាជរដ្ឋាភិបាលកម្ពុជា។ សម្រាប់នីតិកាលទី៤ នៃរដ្ឋសភានៅតែចាត់ទុកថាការកាត់បន្ថយភាពក្រីក្រតាមរបៀបមួយដ៏ឆាប់តាមដែលអាចធ្វើបាន គឺជាអាទិភាពដ៏ចម្បងមួយ។ ការអភិវឌ្ឍសហគមន៍ គឺមានសារៈសម្ខាន់បំផុតសម្រាប់ការកាត់បន្ថយភាពក្រីក្រ ដោយហេតុថា ៨៥ ភាគរយ នៃប្រជាជនក្រីក្ររស់នៅតាមទីជនបទ។ រាជរដ្ឋាភិបាល និងបន្តជម្រុញការអនុវត្តកម្មវិធីអភិវឌ្ឍន៍សហគមន៍ចម្រុះដែលផ្តោតលើការយកចិត្តទុកដាក់ជាសម្ខាន់ចំពោះកត្តាដែលមានផលប៉ះពាល់ជាវិជ្ជមានទៅលើប្រជាពលរដ្ឋក្រីក្រនៅតាមតំបន់ដាច់ស្រយាល ដូចជាការពង្រឹងសមត្ថភាពស្ថាប័ន និងការអភិវឌ្ឍធនធានមនុស្ស ការអនុវត្តផែនការមូលដ្ឋានចម្រុះ ការកសាងផ្លូវសហគមន៍ ការផ្គត់ផ្គង់ទឹក ការថែទាំសុខភាពបឋម ការងារអនាម័យក្នុងសហគមន៍ និងការអភិវឌ្ឍសេដ្ឋកិច្ចជនបទ ដើម្បីលើកកម្ពស់កម្រិតជីវភាពរបស់ប្រជាជនកម្ពុជាឱ្យប្រសើរជាងមុន ជាពិសេសប្រជាជនក្នុងសហគមន៍ផ្ទាល់។ នៅក្នុងទិសដៅបង្កើនកម្រិតជីវភាពប្រជាជន និងកាត់បន្ថយភាពក្រីក្រនៅតាមទីជនបទផងដែរនោះនាយកដ្ឋានអភិវឌ្ឍន៍សហគមន៍បានចាប់បដិសន្ធិនៅក្រោមដំបូលរបស់ក្រសួងអភិវឌ្ឍន៍ជនបទ ដែលជានាយកដ្ឋានជំនាញទទួលបន្ទុកការងារអភិវឌ្ឍសហគមន៍ទូទាំងប្រទេសដើម្បីធ្វើឱ្យមានការប្រែប្រួលដល់សង្គមជនបទទាំងមូល។ នាយកដ្ឋាននេះមានការិយាល័យចំនួនប្រាំ គឺការិយាល័យទូទៅ ការិយាល័យសន្តិសុខស្បៀង ការិយាល័យអប់រំក្រៅប្រព័ន្ធ ការិយាល័យអភិវឌ្ឍន៍មូលដ្ឋាន និងការិយាល័យមជ្ឈមណ្ឌលអភិវឌ្ឍន៍ដែលមានបំណងក្នុងការផ្លាស់ប្តូរផ្នត់គំនិត និងការរីកចម្រើនគ្រប់បែបយ៉ាងរបស់ប្រជាជនដោយរាប់បញ្ចូលទាំងបំណងប្រាថ្នាថ្មីៗជាច្រើននូវជំនាញ និងជំនឿទុកចិត្តថ្មីៗដែលពួកគេមានពីមុនមក និងជាប្រភពធនធានដ៏មានសារៈសម្ខាន់បំផុតដែលត្រូវយកមកប្រើប្រាស់ក្នុងដំណើរការអភិវឌ្ឍន៍សេដ្ឋកិច្ច និងសង្គមនៅក្នុងពេលបច្ចុប្បន្ននេះ។

### ១.៤.២ គោលនយោបាយ និងតួនាទីរបស់រដ្ឋាភិបាលថ្នាក់ក្រោមជាតិ

ទាក់ទងទៅនឹងគោលនយោបាយរដ្ឋាភិបាលថ្នាក់ក្រោមជាតិ វាពិតជាមានសារៈសម្ខាន់ណាស់ក្នុងការស្វែងយល់ពីរចនាសម្ព័ន្ធ និងការទទួលខុសត្រូវនៃរដ្ឋបាលថ្នាក់ក្រោមជាតិនេះដោយផ្អែកលើការគ្រប់គ្រងរដ្ឋបាលឃុំ/សង្កាត់ ឆ្នាំ២០០៨។ រដ្ឋបាលថ្នាក់ក្រោមជាតិមានបីថ្នាក់គឺ ទី១ រដ្ឋបាលថ្នាក់ខេត្ត ទី២ រដ្ឋបាលថ្នាក់ស្រុក/ខណ្ឌ និងទី៣ រដ្ឋបាលថ្នាក់ឃុំ/សង្កាត់។ តួអង្គសម្ខាន់ទាំងបីនេះ ត្រូវបានរំពឹងថានឹងអនុវត្តន៍ការអភិវឌ្ឍសេដ្ឋកិច្ច និងការផ្តល់សេវាកម្ម រួមទាំងអនុវត្តន៍ការធ្វើផែនការអភិវឌ្ឍថ្នាក់មូលដ្ឋានរបស់ឃុំ/សង្កាត់ និងការធ្វើផែនការវិនិយោគសម្រាប់សិក្ខាសាលាសមាហរណកម្មថ្នាក់ស្រុក ដើម្បីប្រមូលមូលនិធិពីខាងរដ្ឋាភិបាល និងពីក្រសួងមហាផ្ទៃក្នុងការអភិវឌ្ឍសហគមន៍។

តួនាទីសម្ខាន់របស់រដ្ឋាភិបាលថ្នាក់ក្រោមជាតិ គឺការអនុវត្តគោលនយោបាយភូមិ/ឃុំ មានសុវត្ថិភាពដែលធានានូវសណ្តាប់ធ្នាប់សង្គម និងសុវត្ថិភាពសម្រាប់ការអភិវឌ្ឍសេដ្ឋកិច្ចមូលដ្ឋាន។ ភាពជោគជ័យនៃគោលនយោបាយនេះ គឺពឹងផ្អែកលើសហប្រតិបត្តិការល្អរវាងប៉ូលីស និងក្រុមប្រឹក្សា។ តួនាទីសម្ខាន់ផ្សេងទៀតរបស់រដ្ឋបាលថ្នាក់ក្រោមជាតិ គឺលើកកម្ពស់ការអភិវឌ្ឍសេដ្ឋកិច្ចប្រកបដោយចីរភាពនៅក្នុងដែនដីរដ្ឋបាលរបស់ពួកគេ។ លើសពីនេះទៅទៀតផែនការអភិវឌ្ឍថ្នាក់ក្រោមជាតិ គួរយកចិត្តទុកដាក់លើថាមពលដែលបង្កើតឡើងដោយមានការប្រែប្រួលសេដ្ឋកិច្ច និងឆ្លើយតបទៅនឹងតម្រូវការទីផ្សារអន្តរជាតិ។ ទោះជាយ៉ាងណាក៏ដោយពុំទាន់មានការយកចិត្តទុកដាក់បែបនេះនៅក្នុងផែនការអភិវឌ្ឍឃុំ និងផែនការវិនិយោគឃុំនាពេលបច្ចុប្បន្ន ហើយសមត្ថភាពរបស់រដ្ឋបាលថ្នាក់ក្រោមជាតិនៅមានកម្រិត។ ការពង្រឹងរដ្ឋបាលថ្នាក់ក្រោមជាតិ ដើម្បីគាំទ្រដល់ការអភិវឌ្ឍសេដ្ឋកិច្ច សង្គមប្រកបដោយចីរភាព នៅក្នុងដែនសមត្ថកិច្ចរបស់ពួកគេ គឺពឹងផ្អែកលើកម្រិតធនធានរបស់រដ្ឋបាលថ្នាក់មូលដ្ឋាន។ គោលបំណង គឺដើម្បីគាំទ្រនូវសមត្ថភាពឃុំ/សង្កាត់ដើម្បីរៀបចំ និងអនុវត្តន៍ផែនការអភិវឌ្ឍសហគមន៍ និងផែនការវិនិយោគលើសហគមន៍របស់ពួកគេដែលនឹងត្រូវបានរួមបញ្ចូលគ្នាទៅក្នុងផែនការអភិវឌ្ឍថ្នាក់ខេត្តរយៈពេលវែង សម្រាប់គាំទ្រការសម្របសម្រួលពីរដ្ឋាភិបាលថ្នាក់កំពូល វិស័យឯកជន ដៃគូអភិវឌ្ឍន៍នានា និងអង្គការក្រៅរដ្ឋាភិបាល (NGO)។

### ១.៤.៣ ទិសដៅក្នុងការអភិវឌ្ឍសហគមន៍

ទិសដៅអភិវឌ្ឍសហគមន៍ គឺជាទិសដៅដែលមានលក្ខណៈបរិយាប័ន្ន និងសុវត្ថិភាពក្នុងការតាំងទីលំនៅថ្មីសម្រាប់ប្រជាជនដែលរស់នៅក្នុងសហគមន៍ឱ្យមានភាពធន់ ធ្វើឱ្យប្រសើរឡើងនូវលំនៅដ្ឋាន ការដឹកជញ្ជូន កន្លែងសាធារណៈ និងបរិស្ថានសហគមន៍ ព្រមទាំងពង្រឹងភាពធន់ទៅនឹងគ្រោះមហន្តរាយការប្រែប្រួលអាកាសធាតុជាដើម។

**១.៤.៣.១ ទិសដៅបញ្ចប់ភាពខ្វះខាត**

– លុបបំបាត់ភាពក្រីក្រធ្ងន់ធ្ងរសម្រាប់ប្រជាជនគ្រប់រូបនៅក្នុងសហគមន៍ជនបទ និងវាស់វែងប្រជាជនដែលរស់នៅក្នុងកម្រិត ១,៩០ដុល្លាក្នុងមួយថ្ងៃ។

– កាត់បន្ថយសមាមាត្រនៃបុរសស្ត្រី និងកុមារ ដែលរស់នៅក្នុងភាពក្រីក្រគ្រប់សមាសភាព។

– ផ្តល់សិទ្ធដល់ប្រជាជនគ្រប់រូបមិនថាជាបុរស ឬស្ត្រីដែលងាយរងគ្រោះបានទទួលការប្រើប្រាស់ធនធានសេដ្ឋកិច្ច សេវាមូលដ្ឋាន ភាពជាម្ចាស់ គ្រប់គ្រងដីធ្លី និងកម្មសិទ្ធផ្សេងៗទៀត។

– គាំពារប្រជាជនក្រីក្រ និងប្រជាជនដែលរស់នៅក្នុងស្ថានភាពងាយរងគ្រោះ ដោយធ្វើការកាត់បន្ថយពីភាពងាយរងគ្រោះថ្នាក់ និងភាពងាយរងគ្រោះពីព្រឹត្តិការណ៍ធំៗ ពាក់ព័ន្ធនឹងអាកាសធាតុ ការភ័យតក់ស្លុតផ្សេងទៀតដោយសារសង្គមកិច្ច សេដ្ឋកិច្ច បរិស្ថាន និងគ្រោះមហន្តរាយផ្សេងៗទៀត។

– បង្កើតក្របខណ្ឌគោលនយោបាយសមស្របនៅកម្រិតសហគមន៍ ដោយផ្អែកលើយុទ្ធសាស្ត្រគាំទ្រប្រជាជនក្រីក្រ និងមានលក្ខណៈយេនឌ័រសម្រាប់គាំទ្រដល់ការពន្លឿនការវិនិយោគក្នុងផ្នែកលុបបំបាត់ភាពក្រីក្រ។

– លើកស្ទួយកម្រិតជីវភាពរស់នៅរបស់ប្រជាពលរដ្ឋដែលរស់នៅតាមជនបទឱ្យមានស្វ័យភាពសេដ្ឋកិច្ចគ្រប់គ្រាន់ និងឈានឡើងប្រហាក់ប្រហែលនឹងបណ្តាលប្រទេសក្នុងតំបន់។

– លើកទឹកចិត្តដល់ចលនាប្រជារាស្ត្រជនបទ ក្នុងការចូលរួមក្នុងដំណាក់កាលនៃគម្រោងអភិវឌ្ឍន៍សហគមន៍ដើម្បីធានានៅប្រសិទ្ធភាពការងារ និងភាពស្ថិតស្ថេរទៅថ្ងៃអនាគត។

– ជម្រុញឱ្យចលនាប្រជាជនមានការចូលរួមកិច្ចការពារនីតិសម្បទា ធនធានធម្មជាតិ និងបរិស្ថាននៅតំបន់ជុំវិញសហគមន៍ ដើម្បីបង្កលក្ខណៈឱ្យការរស់នៅមានតុល្យភាពជាមួយធម្មជាតិ។

– រៀបចំកម្មវិធីឱ្យបានសមស្របទៅតាមលទ្ធភាព និងជំនាញសង្គមជនបទ ណែនាំប្រជាកសិករឱ្យចូលរួមចំណែកក្នុងការកែលម្អផលិតផលកសិកម្ម។

**១.៤.៣.២ ទិសដៅលើកកម្ពស់កម្រិតជីវភាពរស់នៅ និងសុខុមាលភាព**

ទិសដៅនៃការលើកកម្ពស់កម្រិតជីវភាពរស់នៅ និងសុខុមាលភាពប្រជាពលរដ្ឋនៅក្នុងសហគមន៍មានដូចជា៖

– កាត់បន្ថយអត្រាមរណៈភាពនៃមាតា

– បញ្ចប់ការរីករាលដាលមេរោគអេដស៍ ជម្ងឺរបេង គ្រុនចាញ់ ជម្ងឺមិនត្រូវបានយកចិត្តទុកដាក់តាមតំបន់ជនបទ ជម្ងឺថ្លើម ជម្ងឺឆ្លងតាមទឹក និងជម្ងឺផ្សេងៗទៀត។

– កាត់បន្ថយឱ្យបានមួយភាគបីនៃមរណៈភាពមុនអាយុកាលរំពឹងទុកពីជម្ងឺមិនឆ្លងតាមរយៈការការពារ និងការព្យាបាល ព្រមទាំងលើកកម្ពស់សុខភាពផ្លូវចិត្ត និងសុខុមាលភាព។

– ពង្រឹងការបង្ការ និងការព្យាបាល ការសេពគ្រឿងញៀន ព្រមទាំងការប្រើប្រាស់ជាតិសុរាដែលនាំអោយគ្រោះថ្នាក់។

– កាត់បន្ថយចំនួនអ្នកស្លាប់ដោយសារគ្រោះថ្នាក់ចរាចរណ៍។

**១.៤.៣.៣ ទិសដៅលើកកម្ពស់ការអប់រំ**

ទិសដៅលើកកម្ពស់នូវការផ្តល់ការអប់រំពេញលេញទៅដល់កុមារា កុមារីគ្រប់រូបប្រកបដោយសមធម៌ និងគុណភាពនៅកម្រិតមត្តេយ្យ កម្រិតបឋម និងមធ្យមសិក្សាដោយមិនមានការបង់ថ្លៃឈ្នួល។

– លុបបំបាត់គម្លាតយេនឌ័រនៅក្នុងវិស័យអប់រំ និងធានាបានភាពស្មើគ្នាក្នុងការអប់រំគ្រប់កម្រិត។

– ផ្តល់សិទ្ធដល់ប្រជាពលរដ្ឋក្នុងការទទួលយកនូវចំណេះដឹង និងជំនាញដែលត្រូវការដើម្បីជម្រុញការអភិវឌ្ឍ ការសិក្សា មានសិទ្ធមនុស្ស មានសមភាពយេនឌ័រ លើកកម្ពស់វប្បធម៌ សន្តិភាព និងគ្មានអំពើហិង្សា។

## ១.៥ ចំណុចសំខាន់ៗក្នុងការអភិវឌ្ឍសហគមន៍

### ១.៥.១ ការអភិវឌ្ឍសង្គមកិច្ចក្នុងសហគមន៍

ការអភិវឌ្ឍសង្គមកិច្ចក្នុងសហគមន៍បង្ហាញឱ្យឃើញពីបញ្ហាសង្គមយ៉ាងជ្រាលជ្រៅជាពិសេស គឺភាពក្រីក្រ និងការមិនរាប់បញ្ចូលផ្នែកសង្គមផ្សេងទៀត ក៏ដូចជាស្វែងរកការកំណត់នូវភាពក្រីក្រចំពោះវិសាលគមនៃឧបសគ្គនានា។

ប្រទេសកម្ពុជាសម្រេចបាននូវគោលដៅសហស្សវត្សរ៍របស់ខ្លួនមួយចំនួន ដូចជាការកាត់បន្ថយអត្រាមរណៈភាពទារក និងមាតា។ មិនតែប៉ុណ្ណោះ កម្រិតប្រាក់ចំណូលបានកើនឡើង ហើយកម្រិតនៃភាពក្រីក្របានធ្លាក់ចុះ រីឯវិស័យសុខាភិបាល វិស័យអប់រំ វិស័យរដ្ឋបាល និងការអភិវឌ្ឍធនធានមនុស្សបានកើនឡើង។

**១.៥.១.១ ការអភិវឌ្ឍធនធានមនុស្ស**

**អ្វីទៅជាការអភិវឌ្ឍធនធានមនុស្ស**

ការអភិវឌ្ឍធនធានមនុស្សពុំមែនជាការងាយស្រួល ឬសាមញ្ញនោះទេ ប៉ុន្តែវាគឺជាបញ្ហាចម្បង និងស្មុគស្មាញបំផុតក្នុងការទាមទារឱ្យមានការវិភាគ ការពិចារណាអោយបានច្បាស់លាស់អំពីតម្រូវការ និងការផ្គត់ផ្គង់ដែលទាមទារឱ្យមានពេលវេលាវែងមួយដែលប្រកបដោយភាពសុក្រិត ទើបប្រភពធនធានដែលទទួលបានពោរពេញទៅដោយការធានាគុណភាព និរន្តរភាព ដែលធ្វើឱ្យពលកម្មនោះប្រកបដោយទិន្នផលខ្ពស់។ ការអភិវឌ្ឍធនធានមនុស្ស គឺសំដៅទៅលើការបង្កើន ពង្រឹង និងពង្រីកសមត្ថភាពប្រជាពលរដ្ឋ

គ្រប់រូបឱ្យមានទាំងចំណេះដឹង ចំណេះធ្វើ និងមានជំនាញវិទ្យាសាស្ត្របច្ចេកទេសរៀងៗខ្លួនប្រកបដោយសីលធម៌ និងគុណធម៌សង្គម។ ការអភិវឌ្ឍធនធានមនុស្ស ពិតជាកត្តាមួយយ៉ាងសម្ខាន់ក្នុងការអភិវឌ្ឍព្រោះការអភិវឌ្ឍស្ថិតក្នុងគោលបំណងដើម្បីមនុស្ស និងសង្គមមនុស្ស។ ការដែលមនុស្សមានគំនិតច្រើនទាក់ទងទៅនឹងការអភិវឌ្ឍជាហេតុនាំឱ្យមនុស្សមានតម្រូវការច្រើន ដូច្នេះនៅពេលមនុស្សមានតម្រូវការច្រើនផលិតកម្មក៏បានបង្កើតឡើងផងដែរ ដើម្បីបំពេញសេចក្តីត្រូវការរបស់មនុស្ស។

**១.៥.១.២ ការអភិវឌ្ឍវិស័យអប់រំ**

- **និយមន័យនៃការអប់រំ**

ការអប់រំ គឺជាដំណើរការនៃការសម្របសម្រួលការរៀនសូត្រ ឬការទទួលបាននូវចំណេះដឹងជំនាញ គុណតម្លៃ ជំនឿ និងទម្លាប់។ វិធីសាស្ត្រអប់រំរួមមានការបណ្តុះបណ្តាល ការនិទានរឿង ការពិភាក្សា និងការស្រាវជ្រាវដោយផ្ទាល់។ ការអប់រំកើតចេញជាញឹកញាប់ក្រោមការណែនាំរបស់អ្នកអប់រំ ប៉ុន្តែទោះជាយ៉ាងណាអ្នកសិក្សាក៏អាចអប់រំខ្លួនឯងបានដែរ។ ការអប់រំអាចកើតឡើងជាផ្លូវការ និងក្រៅផ្លូវការ ក៏ជាបទពិសោធន៍ណាមួយដែលមានឥទ្ធិពលវិជ្ជមាន ឬសកម្មភាពដែលអាចចាត់ទុកបានថាជាការអប់រំ។ សិទ្ធទទួលបានការអប់រំត្រូវទទួលស្គាល់ដោយរដ្ឋាភិបាលមួយចំនួន និងអង្គការសហប្រជាជាតិ។ នៅតាមតំបន់ ឬសហគមន៍ភាគច្រើន ការអប់រំមានកាតព្វកិច្ចរហូតដល់អាយុជាក់លាក់។

ដើម្បីអភិវឌ្ឍសហគមន៍អោយកាន់តែរឹងមាំ និងរីកចម្រើនទៅមុខ វិស័យអប់រំពិតជាដើរតួនាទីយ៉ាងសម្ខាន់ណាស់ក្នុងការរួមចំណែកចាក់គ្រឹះជាមូលដ្ឋាន និងរុញច្រានកំណើនសេដ្ឋកិច្ចជាតិផងដែរ។ ជាក់ស្តែងរយៈពេលកន្លងមកនេះវិស័យអប់រំក្នុងប្រទេសកម្ពុជាមានភាពប្រសើរឡើងគួរឱ្យកត់សម្គាល់។ ក្រសួងអប់រំ យុវជន និងកីឡាកាន់តែឈានខិតជិតដល់ការសម្រេចបាននូវការផ្តល់សេវាសកល នៃការអប់រំថ្នាក់បឋមសិក្សាតាមរយៈការទទួលបាននូវអត្រាសិស្សចុះឈ្មោះចូលរៀនចំនួន ៩៧,៧% នៅក្នុងឆ្នាំ២០១៦។ មិនតែប៉ុណ្ណោះរាជរដ្ឋាភិបាលបានអនុម័តថវិកាជាតិចំនួន១៨,៣១% សម្រាប់វិស័យអប់រំ និងកំពុងអនុវត្តន៍នូវកំណែទម្រង់លើវិស័យអប់រំដោយផ្តោតលើប្រាំចំណុចរួមមាន ៖ ការអនុវត្តផែនការសកម្មនៃគោលនយោបាយគ្រូបង្រៀន ការពិនិត្យឡើងវិញនូវកម្មវិធីសិក្សា និងសៀវភៅសិក្សា ព្រមទាំងការធ្វើឱ្យប្រសើរឡើងនូវបរិស្ថានសាលារៀន ការធ្វើអធិការកិច្ច ការពង្រឹង ការវាយតម្លៃការសិក្សា ការធ្វើកំណែទម្រង់ការសិក្សាថ្នាក់វិទ្យាល័យ។

ការអភិវឌ្ឍវិស័យអប់រំ ពិតជាមានសារៈសម្ខាន់ណាស់ក្នុងការជម្រុញឱ្យមានការអភិវឌ្ឍសហគមន៍ទៅរកការធ្វើទំនើបកម្មដើម្បីសុខភាព និងសុខុមាលភាពរបស់ប្រជាពលរដ្ឋក្នុងតំបន់ ព្រមទាំងរួមចំណែកកសាង និងការពារសហគមន៍របស់ពួកគេ។ វិស័យអប់រំបានក្លាយជាមធ្យោបាយអភិវឌ្ឍន៍ជនបទតាមរយៈការលើកកម្ពស់គុណភាពសមត្ថភាព និងកសាងគុណផលឱ្យមានកម្រិតខ្ពស់។

### ១.៥.១.៣ ការអភិវឌ្ឍវិស័យសុខាភិបាល

ការអភិវឌ្ឍវិស័យសុខាភិបាល គឺជាការទទួលបាននូវអត្ថប្រយោជន៍ប្រកបដោយសមធម៌ពីកញ្ចប់សេវាសុខភាពប្រកបដោយគុណភាព សំដៅលើការលើកកម្ពស់កម្រិតសុខភាពរបស់ប្រជាពលរដ្ឋដែលរស់នៅតាមជនបទក្នុងសហគមន៍ឱ្យមានសុខភាពល្អ និងសេចក្តីថ្លៃថ្នូរ។ ការកែលម្អកត្តាសង្គមដែលមានផលប៉ះពាល់លើសុខភាព ជាពិសេសកំណើនសេដ្ឋកិច្ច និងការធ្លាក់ចុះនៃភាពក្រីក្របានដើរតួនាទីយ៉ាងសម្ខាន់ក្នុងការបង្កើនអាយុកាលរស់នៅរំពឹងទុក និងលើកកម្ពស់គុណភាពនៃជីវិតរស់នៅរបស់ប្រជាពលរដ្ឋ។ ការអភិវឌ្ឍវិស័យសុខាភិបាលរួមមានគោលបំណងដូចខាងក្រោមៈ

- លើកកម្ពស់ជរាភាពប្រកបដោយសុខភាពល្អផ្អែកលើវិធីសាស្ត្រខ្សែជីវិតរួមអន្តរវិស័យដែលមានការបង្កា ការថែទាំ និងសេវាគាំទ្រសមរម្យ។
- បង្កើតប្រព័ន្ធសុខាភិបាលមួយដែលអាចប្រើបាន និងឆ្លើយតបទៅនឹងតម្រូវការដែលធានាកញ្ចប់សេវាថែទាំសុខភាពរួមបញ្ចូលទាំងមនុស្សចាស់ ដែលរួមមានការបង្ការ ការព្យាបាល ការស្តារលទ្ធភាពពលកម្ម និងសេវាថែទាំ។
- លើកកម្ពស់ការយល់ដឹងអំពីវិធានការជាមូលដ្ឋានសម្រាប់ប្រជាពលរដ្ឋប្រកបដោយសុខភាពល្អក្នុងចំណោមប្រជាជនទាំងអស់ និងជាពិសេសសម្រាប់មនុស្សចាស់ដោយផ្តល់ឱ្យមានអ្នកថែទាំ និងអ្នកផ្តល់សេវាប្រឹក្សាយោបល់។

### ១.៥.១.៤ ការអភិវឌ្ឍវិស័យរដ្ឋបាល

ការអភិវឌ្ឍវិស័យរដ្ឋបាល គឺធ្វើយ៉ាងណាដើម្បីឱ្យចេញជារូបរាងដូចខាងក្រោមៈ

- រៀបចំកាលវិភាគការងារ កិច្ចប្រជុំ ពិធីការ និងទំនាក់ទំងសាធារណៈ
- ទទួលបន្ទុកលើការងារដែលទាក់ទងនឹងបុគ្គលិក និងបេសសកម្មនៅក្នុងសហគមន៍
- គ្រប់គ្រង ចាត់ចែងមន្ត្រីជាប់កិច្ចសន្យា និងបុគ្គលិកអណ្តែតដែលបម្រើការងារនៅក្នុងសហគមន៍
- ទទួលការងាររៀបចំ លិខិតស្នាម ការបោះពុម្ព និងថតចម្លងឯកសារ
- ទទួល និងតាមដានលិខិតចេញចូល
- សហការរៀបចំ និងអនុវត្តន៍ផែនការសកម្មភាព និងថវិការរបស់សហគមន៍
- រៀបចំផែនការអំពីតម្រូវការមធ្យោបាយ សម្ភារៈ
- គ្រប់គ្រង និងថែរក្សាសុវត្ថិភាពយានយន្ត សង្ហារឹម សម្ភារៈ និងបរិក្ខាផ្សេងៗរបស់សហគមន៍
- បូកសរុបរបាយការណ៍របស់សហគមន៍តាមគោលការណ៍កំណត់
- បំពេញភារកិច្ចផ្សេងៗទៀតដែលថ្នាក់ដឹកនាំសហគមន៍ប្រគល់ឱ្យ។

### ១.៥.២ ការអភិវឌ្ឍសេដ្ឋកិច្ចសហគមន៍

ការអភិវឌ្ឍសេដ្ឋកិច្ចសហគមន៍រួមមាន ការអភិវឌ្ឍវិស័យកសិកម្ម វិស័យធនធានទឹក វិស័យទំនាក់ទំនង វិស័យសាធារណៈការ និងដឹកជញ្ជូន។

#### ១.៥.២.១ ការអភិវឌ្ឍវិស័យកសិកម្ម

- **និយមន័យកសិកម្ម**

កសិកម្ម គឺជាវិទ្យាសាស្ត្រ និងសិល្បៈនៃការដាំដុះរុក្ខជាតិ និងបសុសត្វ។ វារួមបញ្ចូលទាំងការរៀបចំផលិតផលរុក្ខជាតិ និងសត្វសម្រាប់ប្រជាជនប្រើប្រាស់ព្រមទាំងចែកចាយទៅកាន់ទីផ្សារ។ អស់រយៈពេលជាច្រើនទស្សវត្សរ៍មកហើយការរីកចម្រើននៃវិស័យកសិកម្មបានរួមចំណែកដល់ការកើនឡើងនៃអរិយធម៌។ មុនពេលកសិកម្មមានការរីករាលដាល ប្រជាជនបានចំណាយពេលស្ទើរតែទាំងស្រុងក្នុងការរុករកចំណីអាហារប្រមាញ់សត្វព្រៃ និងប្រមូលរុក្ខជាតិព្រៃយកមកធ្វើជាអាហារ។ វិស័យកសិកម្មនៅតែបន្តដើរតួនាទីយ៉ាងសម្ខាន់ក្នុងសេដ្ឋកិច្ចប្រទេសកម្ពុជា ប៉ុន្តែនាពេលបច្ចុប្បន្ននេះ វិស័យនេះផ្តល់នូវជីវភាពរស់នៅដល់ប្រជាជនក្នុងទំហំសមាមាត្រតូចជាងពីអតីតកាល។

ការអភិវឌ្ឍវិស័យកសិកម្ម គឺជាការផ្តល់ជំនួយដល់អ្នកផលិតដំណាំដោយមានជំនួយពីធនធានកសិកម្មផ្សេងៗ។ ការការពារ និងជួយក្នុងវិស័យស្រាវជ្រាវ ក៏ដូចជាប្រើប្រាស់បច្ចេកទេសថ្មីៗ ការគ្រប់គ្រងសត្វល្អិតនិងសម្របសម្រួលភាពចម្រុះទាំងអស់ស្ថិតនៅក្នុងទិដ្ឋភាពនៃការអភិវឌ្ឍកសិកម្ម។

**ក.មធ្យោបាយដឹកជញ្ជូន** ៖ ដើម្បីបង្កលក្ខណៈងាយស្រួលដល់ប្រជាកសិករក្នុងការផលិតនូវកសិផលថ្មី និងអាចឱ្យពួកគេលក់ផលិតផលរបស់ពួកគេនៅតាមទីផ្សារសហគមន៍នានា គួរតែផ្សារភ្ជាប់ជាមួយនឹងកាតព្វកិច្ចដែលអាចជួយបង្កើនដល់ប្រាក់ចំណូលរបស់ពួកគេ និងជម្រុញកសិករឱ្យទទួលយកបច្ចេកទេសកសិកម្មល្អជាងមុន។

**ខ.ធារាសាស្ត្រ** ៖ ផលិតភាពដំណាំមិនត្រឹមតែអាស្រ័យលើគុណភាពតែប៉ុណ្ណោះទេ ប៉ុន្តែវាក៏អាស្រ័យលើមូលដ្ឋានធារាសាស្ត្រផងដែរ។ ដូច្នេះប្រឡាយ ឬអណ្តូងគួរតែត្រូវបានសាងសង់ដើម្បីផ្តល់នូវប្រព័ន្ធធារាសាស្ត្រល្អប្រសើរសម្រាប់សុវត្ថិភាពដំណាំ។

**គ.ឥណទានស្ថាប័ន** ៖ ដើម្បីជួយសង្គ្រោះដល់ប្រជាពលរដ្ឋក្នុងសហគមន៍ដែលមានភាពខ្វះខាតអ្នកផ្តល់ឥណទានគ្រប់រូប គួរតែផ្តល់ជូនក្នុងអត្រាការប្រាក់ទាបសមរម្យនៅតាមតំបន់ជនបទ។

**ឃ.មធ្យោបាយទីផ្សារ** ៖ ហេដ្ឋារចនាសម្ព័ន្ធទីផ្សារគួរតែត្រូវបានពង្រីក និងពង្រឹងដើម្បីជួយកសិករលក់ផលិតផលរបស់ពួកគេក្នុងតម្លៃកាន់តែប្រសើរ។ ជាពិសេសគួរតែមានការរៀបចំឱ្យបានត្រឹមត្រូវសម្រាប់

ការផ្ទុកផលិតផលនៅលើទីផ្សារ។ ក្រៅពីនេះគោលនយោបាយគាំទ្រតម្លៃត្រូវតែអនុម័តឡើង ចំណែកឯតម្លៃអប្បរមាគួរតែផ្តល់ការធានាជូនប្រជាកសិករ។

**ង.ការអប់រំផ្នែកកសិកម្ម** ៖ ដើម្បីណែនាំដល់កសិករទាក់ទងទៅនឹងការអនុម័ត ការរៀបចំបច្ចេកវិទ្យាថ្មីៗគួរតែត្រូវបានធ្វើឡើងសម្រាប់ការអប់រំផ្នែកកសិកម្ម និងសេវាផ្សព្វផ្សាយជូនដល់ប្រជាពលរដ្ឋឱ្យយកចិត្តទុកដាក់ថែរក្សាដំណាំឱ្យបានត្រឹមត្រូវ និងទទួលបានទិន្នផលដំណាំច្រើន។

#### ១.៥.២.២ ការអភិវឌ្ឍវិស័យទំនាក់ទំនង

ការអភិវឌ្ឍវិស័យទំនាក់ទំនង គឺជាផ្នែកសម្ខាន់បំផុតដែលផ្សារភ្ជាប់លើការវិភាគស្ថានភាព និងការផ្លាស់ប្តូរអាកប្បកិរិយាសង្គម។ ការអភិវឌ្ឍវិស័យទំនាក់ទំនងប្រកបដោយប្រសិទ្ធភាព គឺជាការរៀបចំ និងអនុវត្តន៍សកម្មភាពទំនាក់ទំនងដែលលើកទឹកចិត្តដល់ការផ្លាស់ប្តូរសហគមន៍ និងការផ្លាស់ប្តូរឥរិយាបទប្រកបដោយចីរភាព។ ការអភិវឌ្ឍវិស័យទំនាក់ទំនងរួមមាន ការធ្វើការទំនាក់ទំនងពីសហគមន៍មួយទៅសហគមន៍មួយ ការទំនាក់ទំនងពីសហគមន៍មួយ ទៅតាមបណ្តាលខេត្តក្រុងផ្សេងទៀត និងការទំនាក់ទំនងពីសហគមន៍មួយទៅកាន់បណ្តាលប្រទេសដទៃទៀត។

## ១.៦ កត្តាដែលជម្រុញឱ្យមានការអភិវឌ្ឍសហគមន៍

ធាតុផ្សំរបស់សហគមន៍ គឺជាទិដ្ឋភាពសម្ខាន់មួយនៃការអភិវឌ្ឍសហគមន៍។ សហគមន៍ពឹងផ្អែកលើមនុស្សដែលបង្កើតឡើង គឺមានន័យថាបើគ្មានពួកគេនោះទេសហគមន៍នឹងមិនកើតមានឡើងដូចគ្នា។ គ្មានអ្វីប្លែកទេដែលការធ្វើការទំនាក់ទំនងជាមួយនឹងប្រជាជនអាចមានឥទ្ធិពលខ្លាំងលើការអភិវឌ្ឍសហគមន៍។

បើយោងតាមការសិក្សាស្រាវជ្រាវទៅលើទស្សនៈវិទូជាច្រើនបានយល់ឃើញថា កត្តាធនធានមនុស្ស និងមូលធនពិតជាស្នូលដែលជម្រុញឱ្យមានការអភិវឌ្ឍ។ លើសពីនេះទៅទៀតកត្តាសង្គម បរិស្ថាន ភូមិសាស្ត្រ សេវាកម្ម រដ្ឋបាល និងសន្តិសុខ ក៏ជាកត្តាដែលចូលរួមចំណែក និងមិនអាចខ្វះបានក្នុងការអភិវឌ្ឍសហគមន៍ផងដែរ។

### ១.៦.១ កត្តាធនធានមនុស្ស

កត្តាធនធានមនុស្ស ជាកត្តាសម្ខាន់មួយក្នុងការអភិវឌ្ឍព្រោះការអភិវឌ្ឍស្ថិតក្នុងគោលបំណងដើម្បីមនុស្ស និងសង្គម។ កត្តាធនធានមនុស្សរួមមាន ៖ ការចូលរួមរបស់ប្រជាពលរដ្ឋក្នុងការអភិវឌ្ឍសហគមន៍ ចំណង់ចំណូលចិត្តក្នុងការចូលរួមអភិវឌ្ឍសហគមន៍ ភាពជាអ្នកដឹកនាំអភិវឌ្ឍសហគមន៍ និងឥរិយាបទក្នុងការអភិវឌ្ឍសហគមន៍។

### ១.៦.១.១ ការចូលរួមរបស់ប្រជាពលរដ្ឋក្នុងការអភិវឌ្ឍសហគមន៍

ការចូលរួមរបស់ប្រជាពលរដ្ឋ គឺជាកត្តាមួយដែលត្រូវបានលើកឡើងម្តងហើយម្តងទៀត ជាពិសេសវាពិតជាដើរតួនាទីយ៉ាងសម្ខាន់ទាក់ទងទៅនឹងការអភិវឌ្ឍសហគមន៍របស់ពួកគេ។ ធាតុផ្សំនៃការអភិវឌ្ឍសហគមន៍មានន័យថា គឺការចូលរួមពីសំណាក់ប្រជាពលរដ្ឋដើម្បីអនុវត្តន៍នូវផែនការសហគមន៍របស់ពួកគេ។ ប៉ុន្តែការចូលរួមនេះ មិនមែនមានន័យថាជាការចូលរួមដែលត្រូវបានបង្ខិតបង្ខំដោយសហគមន៍ឬសមាជិកនៅជុំវិញខ្លួននោះទេ វាគឺការចូលរួមរបស់ប្រជាពលរដ្ឋក្នុងការអភិវឌ្ឍសហគមន៍ គឺជាការចូលរួមដោយស្ម័គ្រចិត្ត និងរួមចំណែកដល់ការអភិវឌ្ឍដែលប្រកបដោយលទ្ធផលវិជ្ជមាន ព្រមទាំងធ្វើឱ្យប្រសើរឡើងនូវកិច្ចខិតខំប្រឹងប្រែងដែលកំពុងធ្វើឡើងរួមគ្នា។

### ១.៦.១.២ ចំណង់ចំណូលចិត្តក្នុងការចូលរួមអភិវឌ្ឍសហគមន៍

ចំណង់ចំណូលចិត្តក្នុងការចូលរួមអភិវឌ្ឍសហគមន៍ គឺជាការរៀបចំឱ្យទទួលបានភាពជោគជ័យនៃផែនការអភិវឌ្ឍដោយផ្តោតលើថា តើប្រជាជនបានយកចិត្តទុកដាក់ទៅលើសហគមន៍ដែលពួកគេកំពុងរស់នៅដែរឬទេ? នៅពេលដែលមានចំណង់ចំណូលចិត្តកាន់តែខ្លាំង នោះសមាជិកក្នុងសហគមន៍នឹងមានឆន្ទៈក្នុងការធ្វើឱ្យមានការអភិវឌ្ឍ ឬធ្វើឱ្យមានការប្រសើរឡើងជាងមុននូវកម្រិតជីវភាព និងអត្រាចំណូលរបស់ខ្លួនក៏ដូចជាសហគមន៍ទាំងមូល។

### ១.៦.១.៣ ភាពជាអ្នកដឹកនាំក្នុងសហគមន៍

ភាពជាអ្នកដឹកនាំសហគមន៍ គឺជាការដឹកនាំតាមរយៈអ្វីៗដែលអាចធ្វើទៅបានក្នុងគោលបំណងឆ្ពោះទៅរកភាពរីកចម្រើន ភាពជឿនលឿន និងភាពល្អប្រសើរនៅក្នុងសហគមន៍។ សកម្មភាពរបស់អ្នកដឹកនាំ និងសមត្ថភាពរបស់ពួកគេអាចកំណត់លទ្ធផលបាននៅក្នុងដំណើរការអភិវឌ្ឍសហគមន៍ ដោយមានប្រសិទ្ធភាព ផ្តល់ការជឿជាក់ និងបង្កើនការប្រាស្រ័យទាក់ទងជាមួយប្រជាពលរដ្ឋក្នុងសហគមន៍របស់ខ្លួនដោយមិនធ្វើឱ្យមានផលប៉ះពាល់ ភាពអន្តរាយ ការបំផ្លាញដល់ទំនុកចិត្តជាមួយនឹងសមាជិកណាម្នាក់ក្នុងសហគមន៍ឡើយ។

### ១.៦.១.៤ ឥរិយាបថក្នុងការអភិវឌ្ឍសហគមន៍

ឥរិយាបថក្នុងការអភិវឌ្ឍសហគមន៍ គឺជាការស្តែងចេញនូវឆន្ទៈចូលរួម និងចំណាប់អារម្មណ៍ពិតប្រាកដក្នុងការអភិវឌ្ឍសហគមន៍របស់ពួកគ ដោយមិនធ្វើឱ្យមានផលប៉ះពាល់ ឬជះឥទ្ធិពលដល់ប្រសិទ្ធភាពនៃកិច្ចខិតខំប្រឹងប្រែងដែលបានធ្វើនៅក្នុងការអភិវឌ្ឍសហគមន៍។

### ១.៦.២ កត្តាសង្គម

កត្តាសង្គមរួមមាន វប្បធម៌ ជំនឿ និងសាសនាជាដើម។

ក.វប្បធម៌ ៖ គឺជាផ្នែកមួយដែលចាំបាច់ត្រូវតែមាននៅក្នុងសហគមន៍។ សមាជិកសហគមន៍ទាំងអស់អាចមាននូវជំនឿផ្ទាល់ខ្លួនរបស់ពួកគេដែលប្រកបទៅដោយក្រមសីលធម៌ ការរំពឹងទុក ហើយឥរិយាបថរបស់ពួកគេត្រូវបានលាយបញ្ចូលជាមួយនឹងវប្បធម៌ ដែលជាផ្នែកមួយចាំបាច់ត្រូវតែមាននៅក្នុងសហគមន៍។ បើទោះបីជាពួកគេមាននូវជំនឿផ្ទាល់ខ្លួនលើក្រមសីលធម៌ ការរំពឹងទុក ប៉ុន្តែឥរិយាបថរបស់ពួកគេបានលាយបញ្ចូលគ្នាជាមួយនឹងកម្រិតខុសៗពីគ្នា។

ខ.ជំនឿ និងសាសនា ៖ គឺជាផ្នែកមួយដែលបានរួមចំណែកក្នុងសហគមន៍ និងកើតមានឡើងមកជាច្រើនសតវត្សរ៍មកហើយ។ ជំនឿ និងសាសនាជាកាតាលីករដ៏មានឥទ្ធិពលសម្រាប់ការផ្លាស់ប្តូរ និងជាដៃគូប្រកួតប្រជែងដែលមានឥទ្ធិពលបំផុតផងដែរ។

### ១.៦.៣ កត្តាធនធានធម្មជាតិ

ធនធានធម្មជាតិមានប្រភពមកពីបួនកន្លែងផ្សេងៗពីគ្នាគឺ នៅក្នុងទឹក ក្រោមដី នៅលើដី និងនៅលើអាកាស។ ធនធានធម្មជាតិត្រូវបានគេចាត់ទុកថាជាវត្ថុមានតម្លៃបំផុតនៅលើពិភពលោកយើងនេះ ដោយសារតែធនធានធម្មជាតិត្រូវបានគេយកមកកែច្នៃដើម្បីផលិតចេញនូវផលិតផលសម្រេចនានា ក្នុងការផ្គត់ផ្គង់ដល់ការរស់នៅរបស់ប្រជាជនក្នុងសហគមន៍។ ធនធានធម្មជាតិបានដើរតួនាទីយ៉ាងសម្ខាន់ផងដែរសម្រាប់ការអភិវឌ្ឍនិងធានានូវចីរភាពដើម្បីឆ្លើយតបទៅតាមតម្រូវការនៃមនុស្សក្នុងពេលបច្ចុប្បន្នដោយមិនធ្វើឱ្យមានការខ្វះខាតទៅដល់មនុស្សជំនាន់ក្រោយ។

### ១.៦.៤ កត្តាមូលធន

កត្តាមូលធនក៏ជាកត្តាមួយយ៉ាងសម្ខាន់ផងដែរ បន្ទាប់ពីកត្តាធម្មជាតិ និងកត្តាសង្គម ព្រោះមូលធន គឺជាប្រភពដែលនាំឱ្យមានឧបករណ៍ទំនើបៗអាចបង្កើនកត្តាផលិតកម្មឱ្យកាន់តែខ្ពស់ និងប្រកបដោយគុណភាពល្អថែមទៀតផង។ មូលធន គឺជាប្រភពចាំបាច់មួយសម្រាប់ការចាប់ផ្តើមនូវការអភិវឌ្ឍដោយសារត្រូវបានគេចាត់ទុកថាជាឧបករណ៍ស្នូលសម្រាប់ចចារដោះដូរនូវរាល់ទំនិញនានា ដែលទាំងនេះហើយទើបធ្វើឱ្យមូលធនក្លាយទៅជាប្រភពនៃតម្រូវការចាំបាច់មួយសម្រាប់មនុស្សផ្ទាល់តែម្តង។

### ១.៦.៥ កត្តាសេវាកម្មរដ្ឋបាល និងសន្តិសុខ

កត្តាសេវាកម្មរដ្ឋបាល និងសន្តិសុខ គឺជាកត្តាចម្បងផងដែរ ក្នុងការអភិវឌ្ឍសហគមន៍។

ក.ការងាររដ្ឋបាល ៖ ត្រូវធ្វើការស្រាវជ្រាវ ដើម្បីផ្តល់យោបល់ជូនក្រុមប្រឹក្សាសហគមន៍អំពីកិច្ចការនានាដែលពាក់ព័ន្ធនឹងអំណាចបញ្ញត្តិ និងអំណាចប្រតិបត្តិរបស់ក្រុមប្រឹក្សាសហគមន៍។ ក្រុមប្រឹក្សាអាចធ្វើការពិភាក្សា និងការអនុម័តក្នុងកិច្ចប្រជុំសាមញ្ញ ឬវិសាមញ្ញទាក់ទងនឹង៖

– ការពិនិត្យមុខងារភារកិច្ច និងធនធានទាំងអស់ដែលបានប្រគល់ ឬបានផ្ទេរមកឱ្យក្រុមប្រឹក្សាសហគមន៍ និងអំពីរបៀបរបប បែបបទ នីតិវិធីនៃការអនុវត្តមុខងារ ភារកិច្ច និងការចាត់ចែងធនធានទាំងនោះ។

– ការរៀបចំរចនាសម្ព័ន្ធប្រព័ន្ធ និងធនធានដើម្បីទទួលយកមុខងារ ភារកិច្ច និងធនធានដែលបាន

– ប្រគល់ ឬបានផ្ទេរមកឱ្យដោយស្របតាមច្បាប់ស្តីពីការគ្រប់គ្រងរដ្ឋបាលថ្នាក់ស្រុក។

– គម្រោងថវិកាប្រចាំឆ្នាំ

– ការងារហិរញ្ញវត្ថុ និងទ្រព្យសម្បត្តិរបស់សហគមន៍

– ការរៀបចំតួនាទី ភារកិច្ច និងលក្ខខណ្ឌការងាររបស់បុគ្គលិក

– វិធានការចាំបាច់ដើម្បីធ្វើឱ្យប្រសើរឡើងនូវការអនុវត្តការងាររបស់ក្រុមប្រឹក្សាសហគមន៍

– វិធានចាំបាច់ដើម្បីលើកកម្ពស់សមភាពយេនឌ័រ

– ការដោះស្រាយសំណើរ សំណូមពរ និងបញ្ហាប្រឈមនានារបស់សហគមន៍

ខ. ការងារសន្តិសុខ ៖ ថែរក្សាសន្តិសុខ សណ្តាប់ធ្នាប់ របៀបរៀបរយសាធារណៈ លើកកម្ពស់ការយល់ដឹងរបស់ប្រជាពលរដ្ឋក្នុងសហគមន៍អំពីច្បាប់ និងធានាឱ្យមានការអនុវត្តច្បាប់ ព្រមទាំងធានាឱ្យមានការការពារ និងគោរពសិទ្ធមនុស្សចំពោះប្រជាពលរដ្ឋទាំងអស់ក្នុងសហគមន៍។

## ១.៧ កត្តាដែលជាផលវិបាកក្នុងការអភិវឌ្ឍសហគមន៍

ថ្វីត្បិតតែមានកត្តាជាច្រើនដែលបានជម្រុញក្នុងការអភិវឌ្ឍសហគមន៍ក៏ពិតមែន ប៉ុន្តែជាក់ស្តែងក៏មានកត្តាមួយចំនួនដែលជាផលវិបាកក្នុងការអភិវឌ្ឍសហគមន៍ផងដែរ។ តើកត្តាអ្វីខ្លះជាផលវិបាកក្នុងការអភិវឌ្ឍសហគមន៍?

### ១.៧.១ បញ្ហាបច្ចេកវិទ្យា

សព្វថ្ងៃនេះអ្នកជំនាញរបស់រដ្ឋាភិបាល និងអ្នកអនុវត្តន៍ការងារក្នុងតំបន់បានអំពាវនាវឱ្យតំបន់ដាច់ស្រយាលត្រូវបង្កើនការប្រើប្រាស់នូវបច្ចេកវិទ្យាឱ្យបានច្រើន។ ដោយមើលឃើញថា សព្វថ្ងៃនេះបច្ចេកវិទ្យាទំនើបមានការរីកដុះដាលយ៉ាងខ្លាំង និងកំពុងត្រូវបានទាក់ទាញទៅក្នុងការអភិវឌ្ឍសហគមន៍ផងដែរ។ ខាងក្រោមនេះជាផលវិបាកចំពោះបញ្ហាបច្ចេកវិទ្យាក្នុងការអភិវឌ្ឍសហគមន៍៖

– សហគមន៍មិនមានការប្រើប្រាស់បច្ចេកវិទ្យាដើម្បីស្នើសុំការចូលរួមពីសារធារណៈជនសម្រាប់ធ្វើការផ្សព្វផ្សាយនូវគោលដៅអភិវឌ្ឍន៍តាមផែនការដែលមានប្រសិទ្ធភាព។

– សហគមន៍ពុំមានការប្រើប្រាស់បច្ចេកវិទ្យាក្នុងការជួយតាមដាន និងវាស់ស្ទង់រាល់ការអនុវត្តការងារដើម្បីកំណត់ថាតើគោលដៅនោះទទួលបានជោគជ័យ ឬមិនបានជោគជ័យ។

– សហគមន៍ពុំមានការប្រើប្រាស់បច្ចេកវិទ្យាដើម្បីធ្វើការផ្សព្វផ្សាយពាណិជ្ជកម្មអំពីផលិតផល ឬសេវាកម្មថ្មីៗដែលមាននៅក្នុងសហគមន៍។

**១.៧.២ បញ្ហាអក្ខរកម្ម**

ខណៈពេលដែលសេដ្ឋកិច្ចកម្ពុជាកំពុងត្រូវការធនធានមនុស្សប្រកបដោយចំណេះដឹង ចំណេះធ្វើ អក្ខរកម្មបានក្លាយជាសមាសភាគមួយក្នុងចំណោមសមាសភាគសម្ខាន់ៗនៃបំណិនជីវិត ដែលនាំឱ្យមនុស្សគ្រប់រូបចាំបាច់ត្រូវតែរៀនយ៉ាងហោចណាស់នូវចំណេះអក្ខរកម្ម។ ដូចនេះអក្ខរកម្ម គឺជាកត្តាមួយដែលបង្ករភាពរាំងស្ទះទៅដល់ការអភិវឌ្ឍសហគមន៍ ព្រោះអក្ខរកម្មមានសារៈសម្ខាន់ណាស់ក្នុងការកាត់បន្ថយភាពក្រីក្រសមភាពយេនឌ័រ បរិយាប័ន្ន និងសង្គម។ អក្ខរកម្ម គឺមិនមែនគ្រាន់តែសមត្ថភាពក្នុងការអានសរសេរ និងការគិតលេខបែបងាយៗនោះទេ ប៉ុន្តែវាជាការប្រើប្រាស់នូវរាល់សមត្ថភាពទាំងអស់ក្នុងការធ្វើឱ្យមានភាពប្រសើរឡើងនូវគុណភាពជីវិតរបស់ខ្លួនឯង គ្រួសារ សហគមន៍ និងសង្គមទាំងមូលផងដែរ។ បញ្ហាអក្ខរកម្ម គឺជាផលវិបាកមួយក្នុងការអភិវឌ្ឍសហគមន៍ ដោយហេតុថាវាអាចធ្វើឱ្យយើងយល់មិនច្បាស់អំពីការធ្វើទំនាក់ទំនងដែលប្រកបដោយប្រសិទ្ធភាព និងការរស់នៅមានសុខសន្តិភាពជាមួយមនុស្សជុំវិញខ្លួន និងចូលរួមចំណែកក្នុងការអភិវឌ្ឍសហគមន៍ និងសង្គមជាតិជាដើម។

**១.៧.៣ បញ្ហានិកម្មភាព និងការធ្វើចំណាកស្រុក**

បញ្ហានេះកើតឡើងនៅតាមបណ្ដាលប្រទេសដែលកំពុងអភិវឌ្ឍន៍ភាគច្រើន ប្រទេសនេះមានមនុស្សធ្វើចំណាកស្រុកដើម្បីស្វែងរកការងារធ្វើនៅក្នុងទីក្រុងដែលបណ្ដាលឱ្យមានមនុស្សច្រើនកុះករមករស់នៅផ្ដុំគ្នា។

**១.៧.៣.១ បញ្ហានិកម្មភាព**

និកម្មភាព គឺជាបាតុភូតសេដ្ឋកិច្ចនៅក្នុងសង្គមដែលប្រជាពលរដ្ឋមួយចំនួនមានសមត្ថភាពការងារ ប៉ុន្តែស្ថិតនៅក្នុងសភាពមិនអាចរកការងារបានធ្វើ។

**ក.កត្តានាំអោយមានបញ្ហានិកម្មភាព**

– វិទ្យាសាស្ត្ររីកចម្រើន ៖ បដិវត្តឧស្សាហកម្ម បានជំនួសឱ្យការងារសិប្បកម្ម ហត្ថកម្ម....។

– បច្ចេកទេសទំនើប ៖ ទាមទារអ្នកដែលមានសមត្ថភាពខ្ពស់ ដើម្បីបញ្ជាម៉ាស៊ីន។

– សមត្ថភាពរបស់ប្រជាពលរដ្ឋមិនទាន់ឆ្លើយតបទៅបាននឹងតម្រូវការប្រទេស។

– អ្នកមានសមត្ថភាពផ្ដុំតែលើផ្នែក ឬជំនាញណាមួយដែលលើសតម្រូវការ។

**ខ. ផែនការកាត់បន្ថយបុគ្គលិក**

- ឱ្យបុគ្គលិកចូលនិវត្តន៍
- បណ្តេញបុគ្គលិកចេញពីការងារ
- ក្រុមហ៊ុន សហគ្រាស រោងចក្រត្រូវបានបិទទ្វារ

**១.៧.៣.២ បញ្ហាចំណាកស្រុក**

បញ្ហាចំណាកស្រុកពីជនបទ ឬសហគមន៍ក្នុងជនបទមកកាន់ទីក្រុង គឺបណ្តាលមកពីនិកម្មភាពនៅទីក្រុងមានកម្រិតទាប និងនៅតាមជនបទដាច់ស្រយាលមិនសូវមានការងារធ្វើ។ មិនតែប៉ុណ្ណោះការអភិវឌ្ឍរវាងទីក្រុង និងសហគមន៍ជនបទមានភាពមិនស្មើគ្នា ព្រមទាំងមានការធ្វើអន្តោប្រវេសន៍របស់ជនបរទេសផងនោះជាហេតុដែលធ្វើឱ្យបញ្ហាចំណាកស្រុកមានការកើនឡើងកាន់តែច្រើន។

**១.៧.៤ គម្លាតរវាងអ្នកមាន និងអ្នកក្រ**

គម្លាតរវាងអ្នកមាន និងអ្នកក្រ គឺជាបញ្ហាសង្គមយ៉ាងធ្ងន់ធ្ងរដែលនាំឱ្យមានការរំលោភបំពានដល់ជីវភាពរស់នៅប្រចាំថ្ងៃ និងជាផលវិបាកក្នុងការអភិវឌ្ឍសហគន៍ដោយទំនាក់ទំនងសាមគ្គីភាព ភាពជាសមាជិកសហគមន៍ពុំសូវមានប្រសិទ្ធភាព។ យើងឃើញថាមានបញ្ហាសម្ខាន់ៗចំនួនបីដែលអាចកើតចេញពីគម្លាតខ្លាំងរវាងអ្នកមាន និងអ្នកក្រដែលអាចបង្ករឱ្យមានផលវិបាកក្នុងការអភិវឌ្ឍសហគមន៍ដូចខាងក្រោមៈ

- ការមើលងាយពីសំណាក់អ្នកមានមួយចំនួនទៅលើអ្នកក្រ ឬអ្នកដែលមានជីវភាពខ្វះខាតជាខ្លួន
- កម្រិតជីវភាពខុសឆ្ងាយពីគ្នាខ្លាំងពេកទើប ធ្វើឱ្យមានគម្លាតកាន់តែឆ្ងាយទៅៗរវាងសមាជិកក្នុងសហគមន៍
- អ្នកមានទ្រព្យសម្បត្តិមធ្យម បានប្រើប្រាស់ជីវិតបែបស៊ីវិល័យ ក្នុងខណៈដែលអ្នកក្រភាគច្រើននៅ ក្នុងសង្គម កំពុងរស់នៅក្រោមបន្ទាត់នៃភាពក្រីក្រ។

**១.៧.៥ កំណើនប្រជាជន**

កំណើនប្រជាជន នៅតែជាបញ្ហាចម្បងសម្រាប់ប្រទេសដែលកំពុងអភិវឌ្ឍន៍ក្នុងនោះអត្រាចំនួនប្រជាជនបានកើនឡើងពីមួយឆ្នាំទៅមួយឆ្នាំ ជាហេតុនាំឱ្យរាំងស្ទះដល់ការអភិវឌ្ឍសហគមន៍ ក៏ដូចជាសង្គមទាំងមូលផងដែរ។ ចំពោះការកើនឡើងនូវកំណើនប្រជាជនធ្វើឱ្យមានការកើនឡើងនូវតម្រូវការប្រើប្រាស់សម្ភារៈដែលទាញយកប្រភពធនធានជាច្រើនទើបនាំឱ្យមានផលប៉ះពាល់ទៅដល់ការសន្សំប្រាក់ចំណូល និងការផ្គត់ផ្គង់មិនទាន់ទៅតាមតម្រូវការប្រើប្រាស់។ ទំហំគ្រួសារកាន់តែធំ ការចំណាយក៏កាន់តែច្រើនដោយកាត់បន្ថយនូវអត្រាសន្សំ ព្រមទាំងដាក់កំហិតលើសេដ្ឋកិច្ចគ្រួសារបង្កើតឱ្យមានភាពខ្វះខាត និងបង្កើនភាពក្រីក្រ។ កំណើនប្រជាជនផ្តល់ផលវិបាកដល់ការអភិវឌ្ឍរួមមាន ខ្វះទឹកស្អាតសម្រាប់ប្រើប្រាស់ ខ្វះថាមពលឱ្យ

មានបញ្ហាបរិស្ថានធ្ងន់ធ្ងរ កើនកម្តៅលើភពផែនដី បាត់បង់ធនធានធម្មជាតិ កើនឡើងនូវភាពក្រីក្ររបស់ប្រជាជន និងកើនឡើងនូវអំពើអបាយមុខផ្សេងៗដូចជា លួច ប្លន់ ចាប់ជំរិត គ្រឿងញៀនក្នុងសហគមន៍ជាដើម។

# ជំពូកទី២

# លក្ខណៈទូទៅ និងស្ថានភាពជុំវិញការអភិវឌ្ឍសហគមន៍កសិកម្មសំបូរមានជ័យ នៅភូមិសំបូរ ឃុំសូតាស ស្រុកស្ទឹងត្រង់ ខេត្តកំពង់ចាម

## ២.១ លក្ខណៈទូទៅ

សហគមន៍កសិកម្ម គឺជានីតិបុគ្គលឯកជនដែលមានលក្ខណៈជាសហគ្រាសសេដ្ឋកិច្ចកសិកម្មដែលបង្កើតឡើងដោយរូបវន្តបុគ្គលមួយក្រុមតាមការស្ម័គ្រចិត្តរួមគ្នាបង្កើតដើមទុន រួមគ្នាធ្វើជាម្ចាស់ និងរួមគ្នាគ្រប់គ្រងតាមលក្ខណៈប្រជាធិបតេយ្យដើម្បីពង្រីកសមត្ថភាព ផលិតផលកសិកម្ម កសិឧស្សាហកម្ម កសិ-ពាណិជ្ជកម្ម ឬសេវាកម្មពាក់ព័ន្ធ។ ផលិតផលកសិកម្មសំដៅទៅលើការលើកកម្ពស់សេដ្ឋកិច្ច សង្គម និងវប្បធម៌របស់សមាជិក ព្រមទាំងរួមចំណែកក្នុងការអភិវឌ្ឍសេដ្ឋកិច្ចជាតិ។

### ២.១.១ ប្រវត្តិនៃការអភិវឌ្ឍសហគមន៍កសិកម្មនៅក្នុងប្រទេសកម្ពុជា

សហគមន៍កសិកម្មបង្កើតឡើងនៅក្នុងប្រទេសកម្ពុជាជាលើកដំបូងក្នុងឆ្នាំ ២០០៣ នៅខេត្តសៀមរាប ដោយផ្អែកទៅតាមព្រះរាជក្រឹត្យស្តីពីការបង្កើត ការប្រព្រឹត្តទៅនៃសហគមន៍អភិវឌ្ឍន៍កសិកម្ម សហភាពសហគមន៍អភិវឌ្ឍន៍កសិកម្ម និងបុរសហគមន៍អភិវឌ្ឍន៍កសិកម្ម។ រហូតមកដល់ពាក់កណ្តាលឆ្នាំ ២០១៥ សហគមន៍កសិកម្មទូទាំងប្រទេសមានប្រមាណ ៦០០ សហគមន៍ដែលបានរៀបចំបង្កើតឡើងដោយប្រជាកសិករនៅក្នុងព្រះរាជាណាចក្រកម្ពុជា។

ប្រទេសកម្ពុជា ជាប្រទេសមួយដែលពឹងផ្អែកទៅលើកសិកម្មជាសម្ខាន់ ព្រោះប្រជាជនប្រមាណ ៨០% ទៅ ៨៥% ជាកសិករ ហើយកសិកម្មផ្តល់នូវផលិតផលជាតិសរុបប្រមាណ ៥០%។ ផលិតផលកសិកម្មរួមមានដំណាំរួមផ្សំ ៦៣% ការចិញ្ចឹមសត្វ ២៤% ការនេសាទ ១០% និងព្រៃឈើ ៣%។ ហេតុដូចនេះហើយទើបរាជរដ្ឋាភិបាលបានយកចិត្តទុកដាក់លើផលិតផលកសិកម្ម និងសហគមន៍កសិកម្មដែលយើងឃើញថារហូតមកដល់សព្វថ្ងៃនេះសហគមន៍កសិកម្មមានការរីកចម្រើនយ៉ាងខ្លាំងទាំងមុខរបរឥណទាន មុខរបរផ្គត់ផ្គង់ មុខរបរទីផ្សារ មុខរបរសេវាកម្ម និងមុខរបរផ្សេងៗទៀត។

### ២.១.២ ការអភិវឌ្ឍសហគមន៍កសិកម្ម

ការអភិវឌ្ឍសហគមន៍កសិកម្ម នៅតែដើរតួនាទីយ៉ាងសម្ខាន់ក្នុងការជម្រុញការអភិវឌ្ឍសេដ្ឋកិច្ច សង្គម និងការអភិវឌ្ឍជនបទ ជាពិសេសបានចូលរួមចំណែកកាត់បន្ថយភាពក្រីក្រនៅកម្ពុជា។ ដោយសារកំណើននៃផលិតកម្ម ការអភិវឌ្ឍលើសហគមន៍កសិកម្មត្រូវបានកំណត់ចេញជាពីរគឺ៖

ទី១ ៖ ត្រូវបង្កើនផលិតភាព ពិពិធកម្មកសិកម្ម ការប្រកួតប្រជែងក្នុងសហគមន៍ដើម្បីឆ្ពោះទៅរកការជម្រុញផលិតផលកសិកម្មតាមលក្ខណៈទំនើប និងយន្តូបនីយកម្មជំនួសឱ្យការថយចុះនៃកម្លាំងពលកម្មកសិកម្មលក្ខណៈសន្សំសំចៃ ធ្វើឱ្យថ្លៃដើមផលិតទាប ធ្វើពិពិធកម្មឆ្ពោះទៅរកមុខដំណែងដែលមានសក្តានុពលខ្ពស់ ផ្តល់ប្រាក់ចំណេញដល់កសិករ សហគមន៍កសិកម្មផ្ទាល់ ដែលនឹងនាំឱ្យមានការប្រកួតប្រជែងខ្ពស់។

ទី២ ៖ ត្រូវបង្កើនប្រសិទ្ធភាពនៃការគ្រប់គ្រង និងអភិវឌ្ឍន៍ធនធានដីនៅក្នុងសហគមន៍ ។

## ២.១.៣ គោលបំណងនៃការអភិវឌ្ឍសហគមន៍កសិកម្ម

គោលបំណងនៃការអភិវឌ្ឍសហគមន៍កសិកម្ម គឺសំដៅទៅលើការលើកកម្ពស់សេដ្ឋកិច្ច សង្គម និងវប្បធម៌របស់សមាជិកព្រមទាំងរួមចំណែកក្នុងការអភិវឌ្ឍសេដ្ឋកិច្ចជាតិ។ គោលបំណងនៃការអភិវឌ្ឍសហគមន៍កសិកម្មរួមមាន ៖

- លើកកម្ពស់សេដ្ឋកិច្ចរបស់សមាជិក ៖ ធ្វើឱ្យសមាជិកមានជីវភាពធូរធារ តាមរយៈការបង្កើនប្រាក់ចំណូលក្នុងគ្រួសារពីអាជីវកម្មកសិកម្ម។
- លើកកម្ពស់សង្គម ៖ បង្កើនសាមគ្គីភាព ធានានូវសមភាព សមធម៌ និងការជួយគ្នាទៅវិញទៅមកក្នុងសហគមន៍កសិកម្ម។
- លើកកម្ពស់វប្បធម៌ ៖ ចូលរួមគាំទ្រដល់កិច្ចការវប្បធម៌ ដូចជាការថែរក្សាប្រពៃណីរបស់ប្រជាកសិករ។
- ជម្រុញ និងបង្កើនប្រាក់ចំណូលរបស់ប្រជាជនអោយខ្ពស់ជាងបន្ទាត់នៃភាពក្រីក្រ
- កាត់បន្ថយភាពខ្វះខាត នៅក្នុងគោលដៅអភិវឌ្ឍន៍សហស្សវត្សរ៍
- បង្កើតក្រុមជួយខ្លួនឯង តាមរយៈការចងក្រងជាក្រុមសន្សំ សាមគ្គីភាព ការជួយគ្នា និងបណ្តុះបណ្តាលនៅតាមមូលដ្ឋានសហគមន៍ដោយមានការចូលរួមពីថ្នាក់ដឹកនាំសហគមន៍។

### ២.១.៣.១ លក្ខន្តិកៈរបស់សហគមន៍កសិកម្ម

លក្ខន្តិកៈរបស់សហគមន៍កសិកម្មត្រូវបានអនុម័តដោយសមាជិកតាមការស្ម័គ្រចិត្ត។ វាប្រៀបដូចជាមគ្គុទេសក្នុងការគ្រប់គ្រងសម្រាប់មន្ត្រីទាំងអស់នៅក្នុងសហគមន៍កសិកម្ម។ លក្ខន្តិកៈគំរូថតចម្លងមួយច្បាប់ត្រូវបានប្រគល់ជូនអ្នកបង្កើតសហគមន៍ដោយអង្គភាពចុះបញ្ជីសហគមន៍កសិកម្ម។

សមាជិកអាចធ្វើការផ្លាស់ប្តូរ និងអនុម័តលក្ខន្តិកៈទៅតាមស្ថានភាពជាក់ស្តែងរបស់ខ្លួន។ បន្ទាប់មកត្រូវបានចុះបញ្ជីដោយអង្គភាពចុះបញ្ជី។ វាផ្តល់ភាពស្របច្បាប់ទៅដល់ឯកសារ និងសហគមន៍កសិកម្ម។ មហាសន្និបាតមានសិទ្ធក្នុងការផ្លាស់ប្តូរ (កែប្រែ) បទបញ្ញត្តិនៅក្នុងលក្ខន្តិកៈដែលត្រូវបានរៀបរាប់នៅក្នុងច្បាប់ស្តីពីសហគមន៍កសិកម្មឆ្នាំ២០១៣ របស់ប្រទេសកម្ពុជា មានដូចខាងក្រោម៖

- នាមករណ៍
- ស្លាកសញ្ញា ទីស្នាក់ការ និងអាស័យដ្ឋាន
- ដើមទុនដែលបានមកពីភាគហ៊ុន តម្លៃភាគហ៊ុន និងលក្ខខណ្ឌនៃការបង់ភាគហ៊ុន
- លក្ខខណ្ឌនៃការគ្រប់គ្រងហិរញ្ញវត្ថុ
- របៀបរបបនៃការចុះបញ្ជីគណនេយ្យ និងការគ្រប់គ្រងឯកសារនានា
- ការទទួលខុសត្រូវផ្នែកហិរញ្ញវត្ថុរបស់សមាជិកចំពោះបំណុលរបស់សហគមន៍កសិកម្ម
- សិទ្ធ និងកាតព្វកិច្ចរបស់សមាជិក
- លក្ខខណ្ឌនៃការសុំចូលជាសមាជិក
- លក្ខខណ្ឌនៃការលាឈប់ និងការបណ្តេញចេញពីសមាជិកភាពសហគមន៍កសិកម្ម
- ការប្រព្រឹត្តទៅរបស់មហាសន្និបាត និងមហាសន្និបាតតំណាង
- សមាសភាពក្រុមប្រឹក្សាភិបាល និងគណៈកម្មាធិការត្រួតពិនិត្យ
- លក្ខខណ្ឌនៃការកោះប្រជុំក្រុមប្រឹក្សាភិបាល និងគណៈកម្មាធិការត្រួតពិនិត្យ
- លក្ខខណ្ឌនៃការបញ្ចូលគ្នារបស់សហគមន៍កសិកម្ម
- នីតិវិធីដោះស្រាយវិវាទនៅក្នុងសហគមន៍កសិកម្ម

### ២.១.៣.២ លក្ខណៈវិនិច្ឆ័យនៃការជ្រើសរើសទីតាំងគម្រោង

ក្របខ័ណ្ឌគ្រប់គ្រងបរិស្ថាន និងសង្គម (ដែលហៅថា ESMF) នេះត្រូវបានរៀបចំឡើងដោយក្រុមការងាររៀបចំគម្រោងនៃក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទដោយមានធាតុចូលពីក្រសួងអភិវឌ្ឍន៍ជនបទ ក្រសួងធនធានទឹក និងឧតុនិយម បានពិភាក្សាគ្នាយ៉ាងយកចិត្តទុកដាក់លើគម្រោងពិពិធកម្មវិស័យកសិកម្មនៅកម្ពុជា។ ដោយគម្រោងនេះនឹងអនុវត្តន៍ក្នុងខេត្តចំនួន ១២ បូករួមទាំងទីក្រុងភ្នំពេញ។ ខេត្តទាំងនេះត្រូវបានជ្រើសរើសដោយសារស្ថានភាពបរិស្ថានសមស្របសម្រាប់ផលិតផលដែលមានតម្លៃខ្ពស់។

តារាងទី១ ៖ បង្ហាញពីប្រភេទ និងលក្ខណៈវិនិច្ឆ័យនៃការជ្រើសរើសទីតាំងគម្រោង

| ប្រភេទ | លក្ខណៈវិនិច្ឆ័យ |
|---|---|
| ទីតាំងភូមិ | ១. ទីតាំងភូមិសាស្ត្រ<br>២.ចំនួនគ្រួសារ<br>៣.ចំនួនប្រជាជនសរុប |
| ស្ថានភាពហេដ្ឋារចនាសម្ព័ន្ធ | ៤. ហេដ្ឋារចនាសម្ព័ន្ធ<br>៥. ឧបករណ៍ប្រើប្រាស់ក្នុងការរស់នៅ<br>៦. ប្រភពទឹក |
| ស្ថានភាពប្រាក់ចំណូល /<br>កសិកម្មរបស់សមាជិកសហគមន៍ | ៧. កម្រិតប្រាក់ចំណូល<br>៨. ស្ថានភាពកសិកម្ម<br>៩. គុណភាពដី |
| ការចូលរួមរបស់សមាជិកសហគមន៍ | ១០. ក្រុមកសិករ<br>១១. កម្រិតនៃការចូលរួម<br>១២. ចំណាប់អារម្មណ៍របស់សមាជិក |
| កត្តាផ្សេងៗ | ១៣. រយៈពេលនៃទឹកជំនន់<br>១៤. កម្លាំងពលកម្ម<br>១៥. គម្រោងអភិវឌ្ឍន៍ផ្សេងៗ |

ប្រភព ៖ នាយកដ្ឋានអភិវឌ្ឍសហគមន៍ ឆ្នាំ ២០១៥

ដោយយោងតាមលក្ខណៈវិនិច្ឆ័យទាំងអស់នេះក្រសួងភិវឌ្ឍន៍ជនបទនឹងអនុវត្តន៍ក្នុងខេត្តចំនួន ១២ បូករួមទាំងរាជធានីភ្នំពេញ។ មុននឹងធ្វើការជ្រើសរើសខេត្ត-ក្រុងទាំង ១២ ខេត្តនេះត្រូវធ្វើការដាក់ពាក្យស្នើសុំដើម្បីទទួលបានគម្រោងអភិវឌ្ឍសហគមន៍។

**២.១.៣.៣ នីតិវិធីស្នើសុំ និងការជ្រើសរើសគម្រោង**

នីតិវិធីស្នើសុំគម្រោង គឺមានលក្ខណៈពីក្រោមឡើងទៅលើដើម្បីធ្វើការសិក្សា និងពិភាក្សាអំពីតម្រូវការរបស់ប្រជាពលរដ្ឋនៅក្នុងសហគមន៍ផ្ទាល់ រួចហើយបានធ្វើរបាយការណ៍បញ្ជូនទៅកាន់គណៈកម្មាធិការអភិវឌ្ឍន៍ភូមិ (គ.អ.ភ) រួចបញ្ជូនទៅកាន់ក្រុមប្រឹក្សាឃុំ-សង្កាត់ ហើយបន្ទាប់មកទៀតបញ្ជូនទៅកាន់ការិយាល័យអភិវឌ្ឍន៍ជនបទ និងបន្តទៅដល់មន្ទីរអភិវឌ្ឍន៍ជនបទខេត្ត រួចចំណុចចុងក្រោយត្រូវបញ្ជូនទៅ

ដល់គណៈកម្មការគ្រប់គ្រង និងដឹកនាំឱ្យធ្វើការត្រួតពិនិត្យលើគម្រោងដែលដាក់មកដើម្បីធ្វើការសម្រេចចិត្ត និងអនុញ្ញាតឱ្យថ្នាក់ក្រោមធ្វើការអនុវត្តគម្រោងដែលស្នើសុំនោះ។

ប្រសិនបើគណៈកម្មការគ្រប់គ្រង និងដឹកនាំគម្រោងពិនិត្យរួចហើយ ក្នុងករណីឃើញថាគម្រោងនេះមិនដូចនឹងធាតុពិតជាក់ស្តែងនៅក្នុងសហគមន៍គណៈកម្មការគ្រប់គ្រងនឹងដឹកនាំគម្រោងធ្វើការបដិសេធចោលចំពោះពាក្យស្នើសុំនោះដោយមិនមានការអនុញ្ញាតអោយអនុវត្តន៍គម្រោងនោះឡើយ។ ម្យ៉ាងទៀត របាយការណ៍នេះនឹងបញ្ជូនទៅថ្នាក់មូលដ្ឋានវិញ ដើម្បីឱ្យពួកគេធ្វើការវិនិច្ឆ័យម្តងទៀតក្នុងការជ្រើសរើសគម្រោងស្នើសុំអភិវឌ្ឍន៍សហគមន៍របស់ពួកគេ។

មុននឹងធ្វើរបាយការណ៍ស្នើរសុំ អ្នកដឹកនាំសហគមន៍ (ប្រធានសហគមន៍) ត្រូវធ្វើការជួបប្រជុំជាមួយនឹងសមាជិកម្នាក់ៗ ដើម្បីធ្វើការពិភាក្សាអំពីតម្រូវការចាំបាច់របស់សមាជិកម្នាក់ៗដែលបានលើកយកជាបញ្ហានៅក្នុងជីវភាពរស់នៅ។ រាល់គម្រោងដែលប្រជាពលរដ្ឋបានស្នើសុំ ឬលើកឡើង ប្រធានសហគមន៍ និងសមាជិកទាំងអស់ត្រូវធ្វើការជ្រើសរើសគម្រោងទាំងនោះដោយសន្មត់ថាគម្រោងទាំងនេះមានភាពចាំបាច់បំផុតសម្រាប់ប្រជាពលរដ្ឋនៅក្នុងសហគមន៍។ ប្រធានសហគមន៍ត្រូវធ្វើការជ្រើសរើសគម្រោងមួយចំនួនដែលមានសារៈសម្ខាន់បំផុត (គម្រោងនោះត្រូវបានត្រួតពិនិត្យ ហើយវិនិច្ឆ័យដោយគណៈកម្មការគ្រប់គ្រងនិងដឹកនាំគម្រោង) នៅក្នុងចំណោមគម្រោងផ្សេងទៀតរបស់សមាជិកសហគមន៍។

បន្ទាប់មកមេដឹកនាំសហគមន៍និងសមាជិកសហគមន៍បានធ្វើរបាយការណ៍ពីគម្រោងនេះ រួចប្រធានសហគមន៍ត្រូវបញ្ជូនដូចដែលបានរៀបរាប់នៅចំណុចខាងលើនេះ នឹងដូចរចនាសម្ព័ន្ធខាងក្រោមនេះ៖

រូបភាពទី២៖ បង្ហាញពីនីតិវិធីស្នើសុំ និងការជ្រើសរើសគម្រោង



### ២.១.៣.៤ ចំណាត់ថ្នាក់នៃប្រភេទគម្រោង

ប្រភេទនៃគម្រោងនេះ គឺជាកម្រិតនៃការសាកល្បងក្នុងការអភិវឌ្ឍសហគមន៍ក្នុងខេត្តទាំង ១២ និងទីក្រុងភ្នំពេញ។ នៅក្នុងចំណាត់ថ្នាក់នៃប្រភេទគម្រោងនេះអ្នកទទួលផលផ្ទាល់រួមមានកសិករខ្នាតតូច និងខ្នាតមធ្យមដែលត្រូវបានចងក្រងជាសហគមន៍ឬក្រុមអ្នកផលិត និងបង្ហាញពីសក្តានុពលក៏ដូចជាចំណាប់អារម្មណ៍ចង់អភិវឌ្ឍន៍អាជីវកម្មកសិកម្មរបស់ពួកគេ ជាមួយនឹងការសហការដោយផ្ទាល់ជាមួយកសិករដើម្បីរួមគ្នាអភិវឌ្ឍន៍អាជីវកម្មកសិកម្ម។ ចំណាត់ថ្នាក់នៃប្រភេទគម្រោងចែកចេញជាបីប្រភេទរួមមាន ៖ គម្រោងកែលម្អបរិស្ថានរស់នៅ គម្រោងបង្កើនប្រាក់ចំណូល (បង្កើនដើមទុន) គម្រោងពង្រឹងសមត្ថភាព និងសកម្មភាពសហគមន៍។

ក. គម្រោងកែលម្អបរិស្ថានរស់នៅ ៖ ផ្តោតសម្ខាន់ទៅលើហេរដ្ឋារចនាសម្ព័ន្ធរស់នៅរបស់ប្រជាពលរដ្ឋក្នុងនោះរួមមាន ការស្តារប្រឡាយ ការជួសជុលផ្លូវក្នុងតំបន់ កសាងសាលារៀន មន្ទីរពេទ្យ និងប្រព័ន្ធផ្គត់ផ្គង់ទឹកជាដើម។

ខ. គម្រោងបង្កើតប្រាក់ចំណូល (បង្កើនដើមទុន) ៖ ផ្តោតសម្ខាន់ទៅលើហេដ្ឋារចនាសម្ព័ន្ធផលិតកម្មក្នុងនោះរួមមាន ជំនួញកសិកម្ម ការបណ្តុះបណ្តាលលើបច្ចេកទេសកសិកម្ម ទីផ្សារកសិកម្ម ឥណទានកសិកម្ម និងសេវាផ្តល់ដំបូន្មានកសិកម្មរបស់សហគមន៍កសិកម្ម។

គ. គម្រោងពង្រឹងសមត្ថភាព និងសកម្មភាពសហគមន៍ ៖ ផ្តោតសម្ខាន់ទៅលើការអភិវឌ្ឍសហគមន៍កសិកម្មរួមមាន ភាពជាអ្នកដឹកនាំ អ្នកសម្របសម្រួល ការបណ្តុះបណ្តាល បច្ចេកទេសកសិកម្ម ការចងក្រងក្រុមកសិករ និងមុខរបររបស់សហគមន៍កសិកម្ម។

### ២.១.៣.៥ ផែនការថវិកា

ការអភិវឌ្ឍសហគមន៍កសិកម្មដែលមានដំណើរការរយៈពេល ៤ឆ្នាំដោយមានការគាំទ្រពីក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ។ ចំណាត់ថ្នាក់ប្រភេទសហគមន៍ទាំងនេះចែកចេញជាប្រាំប្រភេទរួមមាន៖ សហគមន៍កសិកម្មល្អប្រសើរ សហគមន៍កសិកម្មល្អណាស់ សហគមន៍កសិកម្មល្អ សហគមន៍កសិកម្មល្អបង្គួរ និងសហគមន៍កសិកម្មល្អមធ្យម ៖

– ចំពោះសហគមន៍កសិកម្មដែលទទួលបានចំណាត់ថ្នាក់ល្អប្រសើរនឹងទទួលបានថវិការចំនួន១៦លានរៀល (ដប់ប្រាំមួយលានរៀល)

– ហើយសហគមន៍កសិកម្មដែលទទួលបានចំណាត់ថ្នាក់ល្អណាស់នឹងទទួលបានថវិការចំនួន១០លានរៀល (ដប់លានរៀល)

– បន្ទាប់មកសហគមន៍កសិកម្មដែលទទួលបានចំណាត់ថ្នាក់ល្អនឹងទទួលបានថវិការចំនួន ៨ លានរៀល (ប្រាំបីលានរៀល)

– បន្ទាប់មកទៀតសហគមន៍កសិកម្មដែលទទួលបានចំណាត់ថ្នាក់ល្អបង្គួរនឹងទទួលបានថវិការចំនួន ៦ លានរៀល (ប្រាំមួយលានរៀល)

– ជាចុងក្រោយសហគមន៍កសិកម្មដែលទទួលបានចំណាត់ថ្នាក់ល្អមធ្យមនឹងទទួលបានថវិការចំនួន ៤ លានរៀល (បួនលានរៀល)។

### ២.១.៣.៦ គណៈកម្មការវាយតម្លៃគម្រោង

ការចាត់ចំណាត់ថ្នាក់ចំពោះសហគមន៍កសិកម្ម និងការផ្តល់ថវិកាទៅតាមកម្រិតនៃការវាយតម្លៃសហគមន៍នីមួយៗត្រូវបានធ្វើឡើងដោយគណៈកម្មការវាយតម្លៃគម្រោងមានដូចជា ៖ អ្នកដឹកនាំមកពីក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទជាមួយសមាជិកនៃសហព័ន្ធសហករណ៍រ៉ៃអែសិនអាល្លឺម៉ង់ (DGRV) នៅក្នុងការវាយតម្លៃគណៈកម្មការមានភារកិច្ចសម្ខាន់ក្នុងការត្រួតពិនិត្យដូចជា៖

– ថ្នាក់ដឹកនាំសហគមន៍ក្នុងការខិតខំបំពេញភារកិច្ច និងតួនាទីឱ្យបានល្អដើម្បីបម្រើផលប្រយោជន៍ជូនដល់សមាជិក (ដោយធ្វើឱ្យមានការរីកចម្រើនដល់សហគមន៍កសិកម្ម)។

– ត្រូវពង្រឹងសមត្ថភាពស្ថាប័ន ការធ្វើសវនកម្មផ្ទៃក្រៅឱ្យបានទៀងទាត់ដើម្បីដំណើរការបានរលូនប្រកបដោយតម្លាភាព គណនេយ្យភាព និរន្តភាព និងការស្វែងរកដៃគូជំនួញដើម្បីធ្វើកិច្ចសន្យាផលិតកម្មកសិកម្ម។

– ត្រូវខិតខំពង្រឹងរចនាសម្ព័ន្ធ និងធុរកិច្ចឱ្យក្លាយជាសហគ្រាសកសិកម្មទំនើបតាមរយៈការបង្កើតយន្តការគ្រប់គ្រងតាមរយៈការបន្តធ្វើទំនាក់ទំនងជាមួយធនាគារអភិវឌ្ឍន៍ជនបទ និងគ្រឹះស្ថាននានាក្នុងការផ្តល់ឥណទាន។

– ស្នើសុំដៃគូរអភិវឌ្ឍន៍បន្តជួយអភិវឌ្ឍសហគមន៍កសិកម្មបន្ថែមទៀតដោយយកពួកគេធ្វើជាតួអង្គសម្ខាន់ក្នុងគម្រោងដើម្បីជួយដល់កសិករ តាមរយៈការផ្ទេរបច្ចេកទេសផ្សារភ្ជាប់ទំនាក់ទំនងជាមួយគ្រប់ភាគីពាក់ព័ន្ធ។

### ២.១.៣.៧ ការផ្តល់ជំនួយ

ការផ្តល់ជំនួយ (ជំនួយគូសាណូណិ) សម្រាប់ការអភិវឌ្ឍសហគមន៍ដែលមានការគាំទ្រថវិការពីរដ្ឋាភិបាលជប៉ុនក្នុងឆ្នាំ២០២០ នេះ នូវចំនួនទឹកប្រាក់សរុប ១៧៩,៣០៨ដុល្លាអាមេរិក ដោយផ្តោតសម្ខាន់ទៅលើខេត្តកំពង់ចាមផ្ទាល់តែម្តង។ ចំណាត់ថ្នាក់នៃប្រភេទគម្រោងនេះចែកចេញជាពីរគឺ៖

ក.ចំពោះការពង្រឹងទៅលើសហគមន៍កសិកម្ម (ថវិការចំនួន៨៩,៨០០ដុល្លាអាមេរិក) ៖ ប្រជាកសិករប្រមាណជា៤៥០នាក់ដែលជាសមាជិកសហគម៍កសិកម្មនឹងទទួលបានអត្ថប្រយោជន៍ពីការកែលម្អគុណភាពផលិតផលកសិកម្មរបស់ពួកគេ និងបន្ថែមខ្សែសង្វាក់តម្លៃឱ្យកាន់តែស៊ីជម្រៅក្នុងអាជីវកម្មរបស់សហគមន៍កសិកម្ម។ <u>អង្គភាពទទួលជំនួយ ៖ មន្ទីរកសិកម្ម រុក្ខាប្រមាញ់ និងនេសាទខេត្តត្បូងឃ្មុំ</u>

ខ.ចំពោះការស្តារឡើងវិញនូវប្រព័ន្ធធារាសាស្ត្រ (ថវិការចំនួន ៨៩,៥០៨ដុល្លាអាមេរិក) ៖ គម្រោងនេះនឹងធានាបាននូវការផ្គត់ផ្គង់ទឹកប្រកបដោយប្រសិទ្ធភាពសម្រាប់វាលស្រែ និងពង្រីកដីស្រោចស្រពកសិកម្ម។ គម្រោងនេះត្រូវបានគេរំពឹងថានឹងផ្តល់ផលប្រយោជន៍ដល់ប្រជាជនក្នុងតំបន់ជាង ៥,០០០នាក់ក្នុងការបង្កើនផលិតកម្ម ដំណាំស្រូវ តាមរយៈការស្តារឡើងវិញនូវទំនប់ទឹក ដោយប្រើប្រាស់ជាផ្លូវដើម្បីដឹកជញ្ជូនដំណាំកសិកម្មឱ្យមានភាពងាយស្រួល។ <u>អង្គភាពទទួលជំនួយ៖មន្ទីរធនធានទឹក និងឧតុនិយមខេត្តកំពង់ចាម</u>

#### ២.១.៣.៨ សមិទ្ធផលនៃការអភិវឌ្ឍសហគមន៍កសិកម្ម

បន្ទាប់ពីទទួលបានជំនួយពី គូសាណ្ហណិ និងការគាំទ្ររបស់ DGRV ក្នុងការអភិវឌ្ឍសហគមន៍កសិកម្មនេះបានផ្តល់នូវសមិទ្ធផលយ៉ាងច្រើនទៅដល់ប្រជាពលរដ្ឋដែលបានរស់នៅក្នុងសហគមន៍នាខេត្តទាំង១២ និងក្រុងភ្នំពេញ។ សមិទ្ធផលទាំងអស់ដែលសហគមន៍សម្រេចបានរួមមានការចូលរួមចំណែកអភិវឌ្ឍន៍សហគមន៍កសិកម្ម បង្កើនប្រាក់ចំណូលគ្រួសារតាមរយៈការជម្រុញផលិតភាព ផលិតកម្មកសិកម្ម ផលិតនូវផលិតផលប្រកបដោយគុណភាព សុវត្ថិភាព ព្រមទាំងមានលទ្ធភាពក្នុងការប្រកួតប្រជែងទីផ្សារខ្ពស់ និងជាពិសេសបង្កើនប្រព័ន្ធធារាសាស្ត្រ បង្កើនប្រាក់ចំណូលគ្រួសារ កាត់បន្ថយភាពក្រីក្រឆ្លើយតបទៅតាមចក្ខុវិស័យរបស់រាជរដ្ឋាភិបាល។ បន្ថែមពីនេះទៅទៀត គឺការអភិវឌ្ឍសហគមន៍កសិកម្មដោយផ្តោតជាសម្ខាន់លើការលើកកម្ពស់ផលិតភាពផលិតកម្មកសិកម្ម ការប្រើបច្ចេកវិទ្យា និងធាតុចូលកសិកម្មសមស្រប ក៏ដូចជាបំពេញតម្រូវការនៃទីផ្សារទាំងក្នុងនិងក្រៅតំបន់ផងដែរ។

## ២.២ ស្ថានភាពនៃការអភិវឌ្ឍសហគមន៍កសិកម្មសំបូរមានជ័យនៅក្នុងភូមិសំបូរ ឃុំសូភាស ស្រុកស្ទឹងត្រង់ ខេត្តកំពង់ចាម

### ២.២.១ ប្រវត្តិនៃការបង្កើតសហគមន៍កសិកម្មសំបូរមានជ័យ

សហគមន៍កសិកម្មសំបូរមានជ័យបង្កើតឡើងនៅថ្ងៃទី ១០ ខែធ្នូ ឆ្នាំ២០១០។ ក្រោយពីបានសិក្សាលើភាពចាំបាច់ក្នុងតំបន់ដោយមានភាពខ្វះខាតលើទុនសម្រាប់ផលិតផលកសិកម្ម និងបច្ចេកទេសកសិកម្មឯកឧត្តម **តេង ឡៅ** រដ្ឋលេខាក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ ព្រមទាំងក្រុមការងារ មន្ទីរកសិកម្ម

និងសាលាជាតិកសិកម្មខេត្តកំពង់ចាមបានរៀបចំសហគមន៍មួយនេះឡើងដោយមានសមាជិកសរុប ៥៦ នាក់ មានហ៊ុនសរុបចំនួន ៣,៣៣៦ហ៊ុន និងបានចុះបញ្ជីទទួលស្គាល់ដោយមន្ទីរកសិកម្ម រុក្ខាប្រមាញ់ និងនេសាទខេត្តកំពង់ចាម នៅថ្ងៃទី ២០ ខែធ្នូ ឆ្នាំ២០១០។

### ២.២.២ ទីតាំងភូមិសាស្ត្រសហគមន៍កសិកម្មសំបូរមានជ័យ

សហគមន៍កសិកម្មសំបូរមានជ័យមានទីតាំងស្ថិតនៅក្នុងភូមិសំបូរ ឃុំសូភាស ស្រុកស្ទឹងត្រង់ ខេត្តកំពង់ចាម។ សហគមន៍នេះមានព្រំប្រទល់ខាងកើតជាប់ភូមិប៉ប្រក់ ខាងជើងជាប់ភូមិទួលសែន និងខាងលិចជាប់ភូមិទួលប្រាក់។

រូបភាពទី៣ ៖ បង្ហាញអំពីផែនទីស្រុកស្ទឹងត្រង់ ខេត្តកំពង់ចាម




### ២.២.៣ ស្ថានភាពបច្ចុប្បន្នរបស់សហគមន៍កសិកម្មសំបូរមានជ័យ

យោងតាមសេចក្តីថ្លែងការរបស់លោក **ឆេង ចុង** ប្រធានសហគមន៍កសិកម្មសំបូរមានជ័យកាលពីថ្ងៃទី ០១ ខែមិថុនា ឆ្នាំ២០២០ បានឱ្យដឹងថានៅក្នុងឆ្នាំ២០១៩ សហគមន៍មានសមាជិកសរុបចំនួន ៥៩៧ នាក់

ក្នុងនោះស្ត្រីមានចំនួន ៣៩៩នាក់ និងបុរសចំនួន ២៤៨នាក់។ នៅក្នុងនោះផងដែរ ប្រជាជនដែលធ្វើការប្រកបរបរកសិកម្មមានចំនួន ៩៨,៩%។ ស្ថានភាពនេះបានបញ្ជាក់ឱ្យឃើញថាប្រជាជនដែលរស់នៅក្នុងភូមិសំបូរមានមុខរបរចម្បងគឺ វិស័យកសិកម្ម។ ដោយហេតុថាសហគមន៍កសិកម្មនេះជាតំបន់ដែលមានអាកាសធាតុការប្រែប្រួលក្នុងកម្រិតសីតុណ្ហភាពជាមធ្យមមានចាប់ពី ២៦.៧ ទៅ ៣៤ អង្សាសេ។ ទឹកភ្លៀងប្រចាំឆ្នាំជាមធ្យម ៣២% និងសំណើម ៦៨% ជាមួយនឹងកំរិតខ្យល់បក់ ៦ គីឡូម៉ែត្រក្នុងមួយម៉ោងផងដែរ។

### ២.២.៤ មុខរបររបស់សហគមន៍កសិកម្មសំបូរមានជ័យ

រូបភាពទី៤ ៖ បង្ហាញពីមុខរបររបស់សហគមន៍កសិកម្មសំបូរមានជ័យ




ប្រភព ៖ នាយកដ្ឋានអភិវឌ្ឍសហគមន៍ ឆ្នាំ ២០១៥

យោងទៅតាមការប្រតិបត្តិការមុខរបរសហគមន៍កសិកម្មសំបូរមានជ័យ អាចពង្រីកមុខរបររបស់ខ្លួនដល់សមាជិកបាន។ បច្ចុប្បន្នសហគមន៍បានផ្តល់ឧបករណ៍កសិកម្ម ការសង់ឃ្លាំង ការផ្តល់ទីផ្សារ ការផ្តល់ឧបករណ៍ដឹកជញ្ជូន និងសេវាផ្តល់ដំបូន្មានគ្រប់ប្រភេទដល់សមាជិក។

## ២.២.៥ ការអភិវឌ្ឍសហគមន៍កសិកម្មសំបូរមានជ័យ

### ២.២.៥.១ រចនាសម្ព័ន្ធសហគមន៍កសិកម្មសំបូរមានជ័យ

រូបភាពទី៥ ៖ បង្ហាញពីរចនាសម្ព័ន្ធរបស់សហគមន៍កសិកម្មសំបូរមានជ័យ



### ២.២.៥.២ ការបែងចែកភារកិច្ច និងតួនាទីរបស់ថ្នាក់ដឹកនាំសហគមន៍

#### ក. តួនាទីប្រធានគណៈកម្មការសហគមន៍កសិកម្ម

ប្រធានគណៈកម្មការសហគមន៍កសិកម្មមានតួនាទីដូចខាងក្រោម៖

- ដឹកនាំ និងទទួលខុសត្រូវចំពោះការអនុវត្តការងារក្នុងសហគមន៍
- ត្រួតពិនិត្យ និងតាមដានការអនុវត្តការងារក្នុងសហគមន៍
- សម្របសម្រួល ដោះស្រាយបញ្ហាផ្សេងៗដែលកើតមានក្នុងសហគមន៍
- ធ្វើការទំនាក់ទំនងជាមួយអង្គការនានា ដើម្បីស្វែងរកជំនួយទ្រទ្រង់សហគមន៍
- ធ្វើការស្វែងរកទីផ្សារក្នុងការនាំចេញទិន្នផលកសិកម្មរបស់សហគមន៍
- ដឹកនាំរាល់ការប្រជុំ និងការរៀបចំផែនការការងារក្នុងសហគមន៍កសិកម្ម

#### ខ. តួនាទីអនុប្រធានគណៈកម្មការសហគមន៍កសិកម្ម

អនុប្រធានគណៈកម្មការសហគមន៍កសិកម្មសំបូរមានជ័យមានតួនាទីដូចខាងក្រោម៖

- ផ្តល់ព័ត៌មានឥណទាន
- ចូលរួមអនុវត្តន៍ការងារជាមួយប្រធានគណៈកម្មការសហគមន៍
- ជំនួសមុខឱ្យប្រធាននៅក្នុងករណីដែលប្រធានអវត្តមាន
- ដឹកនាំទទួលខុសត្រូវចំពោះការអនុវត្តការងារឥណទាន និងផលិតផលស្រូវពូជ
- ទទួលភារកិច្ចផ្សេងទៀតដែលប្រធានគណៈកម្មការសហគមន៍បានប្រគល់ជូន

#### គ. តួនាទីលេខា

លេខាមានតួនាទីដូចខាងក្រោម៖

- ធ្វើការកត់ត្រារាល់សកម្មភាព និងរក្សាទុករាល់ឯកសារទាំងអស់របស់សហគមន៍
- ធ្វើការគ្រប់គ្រងរាល់សម្ភារៈទាំងអស់របស់សហគមន៍
- រៀបចំលិខិតអញ្ជើញ និងរៀបចំទីតាំងប្រជុំ
- រៀបចំបែបបទ និងលិខិតស្នាមផ្សេងៗដែលទាក់ទងនឹងការគ្រប់គ្រងសហគមន៍
- រៀបចំរបាយការណ៍ការងារ និងលទ្ធផលរបស់សហគមន៍
- ទទួលខុសត្រូវចំពោះការងារសេវាកម្មរបស់សហគមន៍

#### ឃ. តួនាទីគណនី

គណនីមានតួនាទីដូចខាងក្រោម៖

– គ្រប់គ្រងបញ្ជីភាគហ៊ុន និងការសន្សំប្រាក់របស់សហគមន៍

– រៀបចំបញ្ជីប្រាក់សន្សំរបស់សមាជិកសហគមន៍

**២.២.៥.៣ ផែនការអភិវឌ្ឍសហគមន៍ឆ្នាំទី១**

ផែនការសកម្មសម្រាប់លើកទី១ មានបីរួមមាន៖

**ក.ការបង្កើនប្រាក់ចំណូល**

– គម្រោងអនុវត្តន៍ការកម្ចីប្រាក់ដោយឥតគិតការប្រាក់រយៈពេល ១៥ថ្ងៃដល់សមាជិកក្នុងករណីសមាជិកក្នុងសហគមន៍ជួបបញ្ហាបន្ទាន់

– គម្រោងបង្កើតផ្សារសហគមន៍កសិកម្មនៅទីតាំងសហគមន៍ផ្ទាល់ ក្នុងការលក់ដូរផលិតផលកសិកម្ម (បន្លែ ត្រី សាច់ អង្ករ គ្រាប់ពូជ)

– ផ្សព្វផ្សាយ និងបញ្ជូនផលិតផលសហគមន៍ទៅទីផ្សារតាមរយៈបញ្ញើរលក់ផ្តល់សេវាដល់ដេប៉ូ និងហាងទំនិញ

– បង្កើនផលិតកម្មដំណាំស្លឹកគ្រៃ ដំណាំល្ហុង ផ្គត់ផ្គង់ទីផ្សារនៅភ្នំពេញ និងហាងលក់ម្ហូរ

**ខ.ការពង្រឹងស្មារតី និងសកម្មភាពសហគមន៍**

– ពង្រឹងសមត្ថភាពសមាជិក និងធានាគុណភាពផលិតផល ការវេចខ្ចប់ផលិតផល

– ការទទួលស្គាល់គុណភាពគ្រាប់ពូជពីមន្ទីរកសិកម្ម គម្រោង (TSSD) និងការបណ្តុះបណ្តាលពីវិទ្យាស្ថានស្រាវជ្រាវ និងអភិវឌ្ឍន៍កសិកម្មកម្ពុជា (CARDI)

– បណ្តុះបណ្តាលភាពជាអ្នកដឹកនាំ

– បណ្តុះបណ្តាលការគ្រប់គ្រងឥណទាន

– បណ្តុះបណ្តាលការលើកកម្ពស់អនាម័យ

**គ.ការកែលម្អបរិស្ថាន**

– គម្រោងជួសជុលផ្លូវប្រវែង ១០ គីឡូម៉ែត្រ

– គម្រោងសាងសង់បង្គន់អនាម័យចំនួនពីរកន្លែងគឺ ក្នុងបរិវេនការិយាល័យសហគមន៍កសិកម្ម និងក្នុងការដ្ឋានចិញ្ចឹមមាន់។

**២.២.៥.៤ ផែនការអភិវឌ្ឍសហគមន៍ឆ្នាំទី២**

ផែនការសកម្មសម្រាប់ឆ្នាំទី២ មានបីរួមមាន៖

**ក. ការបង្កើនប្រាក់ចំណូល**

- បង្កើតកន្លែងផលិតជីកំប៉ុសលក់
- បង្កើតឱ្យមានការកែច្នៃគ្រាប់ស្វាយចន្ទីលក់
- រៀបចំកន្លែងកសិដ្ឋានឱ្យក្លាយទៅជាតំបន់កសិទេសចរណ៍

**ខ. ពង្រឹងស្មារតី និងសកម្មភាពសហគមន៍**

- ទស្សនកិច្ចសិក្សានៅរាជធានីភ្នំពេញ
- គម្រោងទិញឡានដឹកទំនិញទម្ងន់ ២តោនកន្លះ
- រៀបចំប្រព័ន្ធផ្គត់ផ្គង់ទឹក និងជីកអណ្តូងទឹកចំនួនបីកន្លែងជុំវិញចម្ការឪឡឹក

**គ. ការបង្កើនផ្នែករដ្ឋបាល**

- ពង្រឹងសន្តិសុខ និងសុវត្ថិភាព

**២.២.៥.៥ លក្ខន្តិកៈសម្រាប់គម្រោងនីមួយៗ**

**ក.ការបង្កើតផ្សារសហគមន៍**

ការរៀបចំ និងការប្រព្រឹត្តទៅនៃការបង្កើតផ្សារសហគមន៍កសិកម្មជាលក្ខណៈគ្រួសារទៅតាមគោលការណ៍ធម្មជាតិដើម្បីឱ្យការចរាចរណ៍ផលិតផលកសិកម្ម (បន្លែ ត្រី សាច់ អង្ករ) ប្រកបដោយផលិតផលដែលមានគុណភាពល្អ និងប្រសិទ្ធភាពខ្ពស់គ្មានសារជាតិគីមីដែលធ្វើឱ្យប៉ះពាល់ទៅដល់សុខភាពរបស់បងប្អូនប្រជាពលរដ្ឋ។ គណៈកម្មការសហគមន៍កសិកម្មសំបូរមានជ័យបានដាក់ចេញនូវគោលការណ៍ដែលមានលក្ខខណ្ឌដូចខាងក្រោម៖

- រៀបចំចងក្រងជាក្រុមដើម្បីឱ្យសមាជិកដែលជាអាជីវករទទួលបានបទពិសោធន៍ល្អៗពីគ្នាទៅវិញទៅមកក្នុងការនាំយកនូវផលិតផលកសិកម្មដែលមានគុណភាពមកធ្វើអាជីវកម្ម
- រាល់ផលិតផលដែលដាក់លក់លើទៅផ្សារសហគមន៍ទាំងអស់ត្រូវត្រួតពិនិត្យដោយគណៈកម្មការធ្វើផែនការ និងពិនិត្យទូទៅ គឺលោកស្រី **ម៉ម គឹមហុង** និងលោក **ហ៊ាង ជ្រឹន** អនុប្រធានគណៈកម្មការត្រួតពិនិត្យទូទៅ
- អាជីវករត្រូវចូលរួមបដិភាគលើគម្រោងដែលបានផ្តល់សម្ភារៈ និងកម្លាំងពលកម្ម
- អាជីវករអាចទទួលបានប្រាក់កម្ចីដោយឥតការប្រាក់ក្នុងរយៈពេល១៥ថ្ងៃ។

**ខ.ការបង្កើតកន្លែងផលិតជីកំប៉ុស**

គណៈកម្មការសហគមន៍កសិកម្មសំបូរមានជ័យបានដាក់ចេញនូវគោលការណ៍ស្នើសុំ និងអនុវត្តន៍គម្រោងដូចខាងក្រោម៖

– គោលការណ៍ស្នើសុំ

• ស្នើសុំដល់ម្ចាស់គម្រោងអ៊ីរីកុន (ERECON) ជួយជាឡជីកំប៉ុសចំនួន ២០ ប្រឡោះដែលមានទំហំ (៥ x ៥ម) សរុបជាទឹកប្រាក់ ៨,០០០ ដុល្លាអាមេរិក

• ស្នើសុំដល់ក្រសួងអង្គការ និងស្ថាប័នដែលពាក់ព័ន្ធនានាជួយគាំទ្រដល់កន្លែងបង្កើតជីកំប៉ុស។

– ការអនុវត្តគម្រោង

• គណៈកម្មការគម្រោង ការគ្រប់គ្រង និងត្រួតពិនិត្យលើការងារសាងសង់គម្រោង

• សហគមន៍ផ្តល់ទីតាំងដី អាចម៍ដី និងសម្ភារៈមួយចំនួនសម្រាប់ធ្វើដំណើរការសាងសង់ និងកន្លែងស្តុកជី

• គណៈកម្មការគម្រោងបង្កើតកន្លែងផលិតជីកំប៉ុសជាអ្នកផ្តល់សេវា ទិញ-លក់

**គ. ប្រព័ន្ធផ្គត់ផ្គង់ទឹក**

គណៈកម្មការអភិវឌ្ឍសហគមន៍កសិកម្មសំបូរមានជ័យបានដាក់ចេញនូវគោលការណ៍ដែលមានដូចខាងក្រោម៖

– បង្កើតគណៈកម្មការគ្រប់គ្រងប្រព័ន្ធផ្គត់ផ្គង់ទឹក ដើម្បីដឹកនាំ និងអនុវត្តន៍គម្រោង

– សហគមន៍ផ្តល់ទីតាំងដី សម្ភារៈ ដូចជា ទុយោទឹក សុង កែង ក្បាលរ៉ូម៉ាណេ ការបិទទុយោ (សម្រាប់នាឡិកាទឹកតាមផ្ទះជាបន្ទុករបស់សមាជិកសហគមន៍)

– ធ្វើការកំណត់ថ្លៃទឹក ដោយគិតជាម៉ែត្រគូបស្មើនឹងថវិការចំនួន ១,២០០រៀល។

**២.២.៥.៦ ការអនុវត្តផែនការសហគមន៍**

**ក.ការអនុវត្តផែនការសហគមន៍សម្រាប់ឆ្នាំទី១** ៖ សហគមន៍បានអនុវត្តផែនការចំនួនបីគឺ

– ការបង្កើនប្រាក់ចំណូល តាមរយៈតាមផ្តល់ប្រាក់កម្ចីដល់សមាជិកដោយឥតការប្រាក់រយៈពេល១៥ថ្ងៃ និងការនាំចេញកសិផលផ្គត់ផ្គង់ទីផ្សារនៅរាជធានីភ្នំពេញ

– ការកែលម្អបរិស្ថាន តាមរយៈការសាងសង់បង្គន់អនាម័យក្នុងបរិវេនសហគមន៍

– ពង្រឹងស្មារតី និងសកម្មភាពសហគមន៍ តាមរយៈធ្វើការបណ្តុះបណ្តាល ត្រួតពិនិត្យមើលលើផលិតផលកសិកម្មអំពីគុណភាព

ខ.ការអនុវត្តផែនការសហគមន៍សម្រាប់ឆ្នាំទី២ ៖ សហគមន៍បានអនុវត្តផែនការចំនួនពីរគឺ

– ការបង្កើនប្រាក់ចំណូល តាមរយៈការរៀបចំដាំបន្លែចម្រុះ និងកសិដ្ឋានចិញ្ចឹមមាន់ក្នុងផ្ទៃដី១០ហិកតាអោយក្លាយជាតំបន់កសិទេសចរណ៍

– ការបង្កើនផ្នែករដ្ឋបាល តាមរយៈការពង្រឹងសន្តិសុខ សុវត្ថិភាព។

**២.២.៥.៧ ការត្រួតពិនិត្យ**

ផលិតករ អាជីវករ និងប្រតិបត្តិករត្រូវចុះឈ្មោះជាសមាជិកនៅក្នុងសហគមន៍កសិកម្មសំបូរមានជ័យដែលមានទីតាំងដូចដែលបានបញ្ជាក់ក្នុងចំណុច ២.២.២ និងត្រូវបានទទួលស្គាល់ដោយស្របទៅតាមយថាប្រភេទ។ រាល់ផលិតករទាំងអស់ត្រូវប្រកាសនូវផ្ទៃដីដាំដុះដែលខ្លួនចង់ផលិតកសិកម្ម។ គណៈកម្មការសហគមន៍នឹងចុះទៅត្រួតពិនិត្យមើលភាពត្រូវគ្នាជាមួយនឹងតម្រូវការផលិតផលដែលមានទីតាំងចម្ការ ស្ថិតនៅភូមិសំបូរ ឃុំសូភាស ស្រុកស្ទឹងត្រង់ ខេត្តកំពង់ចាម។

រាល់ផលិតករ កសិករ អាជីវករទាំងអស់ត្រូវរក្សាឯកសារមួយចំនួននៅផ្ទះរបស់ខ្លួនដូចជា លក្ខន្តិកៈសហគមន៍ កិច្ចសន្យា និងបញ្ជីគណនេយ្យផលិតផលកសិកម្ម។

## ២.៣ ទិសដៅក្នុងការអភិវឌ្ឍសហគមន៍កសិកម្មសំបូរមានជ័យ

សហគមន៍កសិកម្មសំបូរមានជ័យ បានធ្វើការបង្កើតឡើងក្នុងទិសដៅដោះស្រាយបញ្ហាខ្វះខាតដើមទុនរបស់សមាជិកសហគមន៍ក្នុងការប្រកបរបរកសិកម្ម និងការពារផលប្រយោជន៍សមាជិកសហគមន៍ក្នុងពេលដែលកសិករម្នាក់មិនអាចដោះស្រាយបាន។ ដើម្បីសម្រេចបានទិសដៅខាងលើសហគមន៍បានដាក់ចេញនូវទិសដៅបួនសំខាន់ៗក្នុងការអនុវត្តរួមមាន៖

**ក.សន្សំប្រាក់** ៖ ក្នុងការសន្សំប្រាក់នេះផងដែរ សហគមន៍កសិកម្មសំបូរមានជ័យបានឱ្យសមាជិកនៅក្នុងសហគមន៍ទាំងអស់ត្រូវដាក់ប្រាក់សន្សំ ២០០០រៀល (ក្នុងមួយថ្ងៃ)សម្រាប់សមាជិកម្នាក់ ដើម្បីទ្រទ្រង់ដល់ការអភិវឌ្ឍសហគមន៍ ក៏ដូចជាសម្រាប់ដោះស្រាយបញ្ហាដែលកើតមានឡើងដោយការមិនបានត្រៀមទុកជាមុន (ដូចជានៅពេលសមាជិកមានជម្ងឺហើយពុំមានថវិការសម្រាប់ព្យាបាលទាន់ពេលវេលា)។

**ខ.ឥណទាន** ៖ ការដាក់ឥណទាន ដើម្បីសម្រួលទៅដល់សមាជិក និងប្រជាជនក្នុងតំបន់នោះដោយអាចធ្វើការកម្ចីសាច់ប្រាក់បាន ដើម្បីពន្លឿនការធ្វើកសិកម្មទាន់ពេលវេលា។

**គ.ផ្គត់ផ្គង់សម្ភារៈកសិកម្ម** ៖ ដោយមានការផលិតស្រូវពូជ សម្រាប់លក់ទៅកាន់ទីផ្សារ ការផ្គត់ផ្គង់ធាតុចូលកសិកម្ម ការធ្វើទីផ្សារបន្លែសុវត្ថិភាពរួមមាន ស្លឹកគ្រៃ បន្លែ ឈើហូបផ្លែ ដាំបន្លែសុវត្ថិភាព ចិញ្ចឹមមាន់ នៅក្នុងផ្ទះសំណាញ់ និងការកែច្នៃប្រេងស្លឹកគ្រៃសម្រាប់លក់ទៅកាន់ទីផ្សារ។

**ឃ.សេវាកម្ម និងទីផ្សារ** ៖ សហគមន៍បានស្វែងរកទីផ្សារផលិតផលដែលសមាជិកផលិតបានទៅតាមទីផ្សារនានា នៅក្នុងស្រុក និងកំពុងស្វែងរកដៃគូរទីផ្សារក្រៅស្រុកបន្ថែមទៀតផងដែរ។

### ២.៣.១ ចក្ខុវិស័យអភិវឌ្ឍន៍សហគមន៍

ដោយមើលឃើញថាតំបន់នៅជុំវិញសហគមន៍មានលក្ខណៈអំណោយផលល្អពីធម្មជាតិ និងមានផ្ទៃដីដាំដុះធំទូលាយផងនោះទើបគណៈកម្មាធិការ ក៏ដូចជាថ្នាក់ដឹកនាំសហគមន៍មួយចំនួនបានបង្កើតនូវចក្ខុវិស័យក្នុងការបង្កើនការដាំដុះឱ្យបានច្រើនដងក្នុងមួយឆ្នាំ។ បន្ទាប់ពីប្រជាកសិករបានបន្សល់ទុកដីឱ្យនៅទំនេរចោលមិនមានការធ្វើកសិកម្ម និងយល់ឃើញថាប្រជាពលរដ្ឋក្នុងតំបន់នោះមានពេលវេលានៅសេសសល់ច្រើនក្រោយពីការធ្វើស្រែតែម្ដងក្នុងមួយឆ្នាំ។ ហេតុដូចនេះហើយទើបសហគមន៍បានជម្រុញឱ្យមានការបង្កើនការដាំដុះអោយបានច្រើនដងក្នុងមួយឆ្នាំ។ ជាក់ស្តែងបច្ចុប្បន្នផ្ទៃដីទំនេរទាំងអស់នោះបានប្រែក្លាយទីជាផ្ទៃដីដាំដំណាំស្លឹកគ្រៃ និងដំណាំផ្សេងៗទៀត ដើម្បីបង្កើនប្រាក់ចំណូលបន្ថែមមួយកម្រិតទៀត។

### ២.៣.២ គោលបំណងអភិវឌ្ឍន៍សហគមន៍

លោក **ឆេង ថុង** ប្រធានសហគមន៍កសិកម្មសំបូរមានជ័យបានលើកឡើងថាសហគមន៍នេះបានបង្កើតឡើងក្នុងគោលបំណងដោះស្រាយបញ្ហា និងការពារផលប្រយោជន៍សមាជិកក្នុងសហគមន៍ដែលកសិករម្នាក់មិនអាចដោះស្រាយបាន ពង្រឹងសិទ្ធិអំណាច ចរចាថ្លៃកសិផលជាមួយឈ្មួញកណ្ដាល ក្រុមហ៊ុន បង្កើនដើមទុនរបស់សមាជិកក្នុងការប្រកបរបរកសិកម្មព្រមទាំងជួយលើកកម្ពស់កម្រិតជីវភាពរបស់សមាជិក និងសង្គមតាមរយៈផលិតផលកសិកម្ម។

#### ២.៣.២.១ គោលបំណងផ្នែកសេដ្ឋកិច្ច

ដោយមើលឃើញពីការបញ្ចាទិញរបស់ឈ្មួញកណ្ដាល ទៅលើផលិតផលដំណាំកសិកម្មរបស់ប្រជាកសិករដែលផលិតបាន មិនសមស្របទៅតាមតម្លៃទីផ្សារ (ធ្វើការបញ្ចាទិញតាមតែមាត់) ដូចនេះហើយទើបសហគមន៍បង្កើតឡើងក្នុងគោលបំណងរកទីផ្សារឱ្យសមាជិក បង្កើនជំនាញកសិកម្មដល់សមាជិកយុទ្ធសាស្ត្រលើការដាំដុះ វិធីថែទាំដើម្បីទទួលបានទិន្នផលច្រើន និងបង្កើនប្រាក់ចំណូលក្នុងគ្រួសារនីមួយៗ។

#### ២.៣.២.២ គោលបំណងផ្នែកសង្គមកិច្ច

មុនឆ្នាំ ២០១៥ ស្ថានភាពនៅតំបន់នេះ គឺមានការលំបាកខ្លាំងលើបញ្ហាផ្លូវ ប្រព័ន្ធធារាស្ត្រ ការធ្វើដំណើរក្នុងការនាំចេញផលិតផលកសិកម្មទៅលក់លើទីផ្សារ។ គោលបំណងអភិវឌ្ឍន៍ផ្នែកសង្គម ដោយការមើល

ឃើញពីភាពលំបាកក្នុងសហគមន៍ទាំងអស់នេះហើយទើបសហគមន៍មានបំណងកសាងផ្លូវថ្នល់ ប្រព័ន្ធធារាសាស្ត្របង្កើតការងារឱ្យប្រជាជនដើម្បីឱ្យមានភាពងាយស្រួលក្នុងការនាំចេញផលិតផលកសិកម្ម និងបង្កើនទិន្នផលច្រើនជាងមុន។

**២.៣.២.៣ គោលបំណងផ្នែករដ្ឋបាល**

គោលបំណងផ្នែករដ្ឋបាល គឺជម្រុញឱ្យមានសាមគ្គីភាព ការចូលរួម សន្តិភាព សុវត្ថិភាព ការពារសន្តិសុខនិងការរៀបចំឱ្យមានសណ្តាប់ធ្នាប់សង្គមតាមរយៈការចូលរួមដោយផ្ទាល់ពីសមាជិកក្នុងសហគមន៍ ព្រមទាំងប្រជាពលរដ្ឋក្នុងតំបន់នោះទាំងមូល។

**២.៣.២.៤ គោលបំណងផ្នែកយេនឌ័រ**

សហគមន៍កសិកម្មសំបូរមានជ័យមានគោលបំណងបង្កើនផ្នែកយេនឌ័រ តាមរយៈការរៀបចំយន្តការមួយចំនួនលើការរ៉ាបរង់ជាពិសេស គឺបានផ្តល់ឱកាសដល់ស្ត្រីជាអាទិភាពក្នុងការចូលរួម ការសំណូមពរជាច្រើនដែលស្ត្រីចង់លើកឡើង ព្រមទាំងការបញ្ចេញមតិយោបល់ក្នុងការស្ថាបនាសហគមន៍ និងជម្រុញឱ្យស្ត្រីមានភារកិច្ច និងតួនាទីនៅក្នុងសហគមន៍កសិកម្មទាំងមូលផងដែរ។

**២.៣.៣ គោលដៅអភិវឌ្ឍន៍សហគមន៍**

គោលដៅអភិវឌ្ឍន៍សហគមន៍កសិកម្មសំបូរមានជ័យ គឺដើម្បីលើកកម្ពស់សុខភាពប្រជាពលរដ្ឋ បង្កើនសមភាពយេនឌ័រ និងបង្កើនប្រាក់ចំណូលរបស់សមាជិកតាមរយៈការផ្តល់ចំណេះដឹងលើបច្ចេកទេសកសិកម្ម ការស្វែងរកដៃគូទីផ្សារ ការនាំចេញផលិតផលកសិកម្មទៅលើទីផ្សារ ការបង្កើតប្រព័ន្ធធារាសាស្ត្រ ការបង្កើនគុណភាពដី ព្រមទាំងការជ្រើសរើសពូជស្រូវក្នុងការដាំដុះឱ្យទទួលបានទិន្នផលខ្ពស់។

## ២.៤ សកម្មភាពរបស់ថ្នាក់ដឹកនាំ និងសកម្មភាពរបស់ប្រជាជនក្នុងការអភិវឌ្ឍសហគមន៍កសិកម្មសំបូរមានជ័យ

ឯកឧត្តម **អ៊ុន ចាន់ដា** អភិបាលខេត្តកំពង់ចាម ក៏បានជម្រុញដល់ប្រជាកសិករក្នុងសហគមន៍ទាំងអស់ត្រូវយកចិត្តទុកដាក់បន្ថែមទៀតក្នុងការពង្រីកការដាំដុះដំណាំកសិកម្មដែលជាតម្រូវការទីផ្សារ ហើយត្រូវធានាឱ្យបាននូវគុណភាព និងមិនត្រូវសម្លាប់ទីផ្សារខ្លួនឯងនោះទេ។ លើសពីនោះលោកក៏បានកោតសរសើរដល់សហគមន៍ដែលបានចូលរួមការងារសង្គមដូចជាការនាំយកថវិការមកជួសជុលក្នុងមូលដ្ឋានផ្លូវថ្នល់ដើម្បីមានភាពងាយស្រួលក្នុងការដឹកនាំជញ្ជូនកសិផលទៅកាន់ទីផ្សារ និងបានចូលរួមចំណែកក្នុងការកាត់បន្ថយភាពក្រីក្រផងដែរ។

#### ២.៤.១ ការចូលរួមអនុវត្តន៍ផ្ទាល់របស់មន្ត្រីថ្នាក់ខេត្ត និងមន្ត្រីថ្នាក់ឃុំ

ឯកឧត្តមរដ្ឋមន្ត្រី **វេង សាខុន** បានពិនិត្យសកម្មភាពនៃដំណើរការធ្វើអាជីវកម្មរបស់សហគមន៍គួរឱ្យកោដសរសើរ។ ឯកឧត្តមបានសម្តែងនូវទឹកចិត្តសប្បាយរីករាយ និងចូលរួមអបអរចំពោះភាពជោគជ័យដែលសហគមន៍ទាំងមូលសម្រេចបានហើយបានជួយលើកទឹកចិត្តឱ្យបន្តខិតខំថែមទៀតដោយត្រូវឈរលើគោលការណ៍បច្ចេកទេសត្រឹមត្រូវ ទាំងការដាំដុះ ការផលិត ការប្រមូលផល វេចខ្ចប់ ស្តុកទុក និងដឹកជញ្ជូនទៅកាន់ទីផ្សារប្រកបដោយគុណភាព និងអនាម័យ ទើបធ្វើឱ្យផលិតផលបន្លែ ផ្លែឈើនៅស្រស់ល្អឆ្លើយតបតាមតម្រូវការទីផ្សារ និងមានតម្លៃខ្ពស់។ លោកក៏បានណែនាំឱ្យអគ្គនាយកដ្ឋានកសិកម្មសហការជាមួយមន្ទីរដើម្បីជួយធ្វើការបណ្តុះបណ្តាលអំពីកម្មវិធីគណទាន ទីផ្សារ កិច្ចសន្យាកសិកម្ម និងបច្ចេកទេសកសិកម្មប្រមូលផល ឃ្លាំងស្តុក កែច្នៃ ដោយផ្តោតជាសម្ខាន់លើការប្រើប្រាស់ផ្ទះសំណាញ់ និងប្រព័ន្ធស្រោចស្រពបន្លែ ការអនុវត្តកម្មវិធីកសិកម្មល្អ (GAP) ធ្វើយ៉ាងណាបង្កើនការជឿទុកចិត្តពីអតិថិជនតាមរយៈគុណភាព និងសុវត្ថិភាពនៃផលិតផល។

#### ២.៤.២ ការចូលរួមអនុវត្តន៍របស់ប្រជាពលរដ្ឋ

ក្នុងការចូលរួមអនុវត្តន៍របស់សមាជិកមានការសហការជាមួយសហគមន៍ និងសមាជិកដទៃទៀតបានយ៉ាងល្អដោយសមាជិកបានចូលរួមអនុវត្តន៍ទៅលើការដាំដុះ ការធ្វើកសិកម្មស្របទិសវិជ្ជមាននៃផែនការសហគមន៍ដែលមានកម្រិត និងបរិមាណច្បាស់លាស់ដើម្បីធ្វើការផ្គត់ផ្គង់ទៅលើទីផ្សារ ឬមានទិន្នផលគ្រប់គ្រាន់ក្នុងការឆ្លើយតបទៅកាន់ការបញ្ជាទិញពីបណ្តាលក្រុមហ៊ុន និងទីផ្សារក្រៅតំបន់នានា។

### ២.៥ សកម្មភាពសម្ខាន់ៗរបស់សហគមន៍កសិកម្មសំបូរមានជ័យ

#### ២.៥.១ ការប្រជុំក្រុមប្រឹក្សាភិបាល និងគណៈកម្មាធិការប្រតិបត្តិ

សហគមន៍កសិកម្មសំបូរមានជ័យបានរៀបចំកិច្ចប្រជុំគណៈកម្មាធិការចំនួន ១២លើក និងប្រជុំក្រុមប្រឹក្សាភិបាលចំនួន ០៦ លើកតាមផែនការសកម្មភាពដែលបានគ្រោងក្នុងឆ្នាំ ២០១៨។

#### ២.៥.២ ការប្រជុំផ្សព្វផ្សាយជាមួយសមាជិក

សហគមន៍បានរៀបចំកិច្ចប្រជុំផ្សព្វផ្សាយជាមួយសមាជិកចំនួន ២លើកក្នុងឆ្នាំ២០១៩ ដោយលើកទីមួយធ្វើឡើងក្នុងដើមខែមករា និងលើកទីពីរធ្វើឡើងក្នុងដើមខែមិថុនា ស្របតាមផែនការដែលបានកំណត់ក្នុងផែនការសកម្មរបស់សហគមន៍នាឆ្នាំ២០១៨ កន្លងទៅ។

### ២.៥.៣ ការចុះឈ្មោះសមាជិក និងការរៀបចំរបាយការណ៍ត្រួតពិនិត្យកសិកម្ម

សហគមន៍បានចាប់ផ្តើមទទួលពាក្យសុំចូលជាសមាជិកថ្មីជារៀងរាល់ថ្ងៃ និងចាប់ផ្តើមពិនិត្យមើលលើកសិកម្មនៅចុងខែធ្នូជារៀងរាល់ឆ្នាំ។ នៅក្នុងឆ្នាំ២០១៩មានសមាជិកដែលបានដាក់ពាក្យចូលជាសមាជិកថ្មីមានចំនួន ១៩២ នាក់ ក្នុងនោះស្ត្រីចំនួន ១០៩ នាក់។ ជាលទ្ធផលសមាជិកទាំងអស់ត្រូវបានអនុញ្ញាតឱ្យចូលជាសមាជិកថ្មីនៅចុងឆ្នាំ ២០១៩។

### ២.៥.៤ ការត្រួតពិនិត្យមើលលើដំណាំកសិកម្ម

ការត្រួតពិនិត្យលើដំណាំកសិកម្មរបស់សហគមន៍កសិកម្មសំបូរមានជ័យមានពីររបៀប គឺការត្រួតពិនិត្យផ្ទៃក្នុង និងក្រៅ។ ផលិតក រកសិករ អាជីវករ និងប្រតិបត្តិករមិនអាចបដិសេធការត្រួតពិនិត្យរបស់អ្នកត្រួតពិនិត្យផ្ទៃខាងក្នុង និងខាងក្រៅ ឬទៅលើមធ្យោបាយរបស់វាបាននោះទេ។ ពួកគាត់មិនអាចបដិសេធច្រើនជាងមួយលើកចំពោះកម្មវិធីនៃការត្រួតពិនិត្យឡើយ។

ក.ការត្រួតពិនិត្យផ្ទៃខាងក្នុង ៖ ដើម្បីធានាឱ្យបានថាគ្រប់សមាជិកទាំងអស់បានអនុវត្តទៅតាមផែនការ គណៈកម្មការសហគមន៍បានរៀបចំការត្រួតពិនិត្យផ្ទៃក្នុងលើសមាជិកចំនួនពីរលើកដូចខាងក្រោម៖

- លើកទីមួយ ៖ ការត្រួតពិនិត្យធ្វើឡើង ១០០ភាគរយ លើសមាជិកផលិតករដោយធ្វើឡើងក្នុងកំឡុងរដូវកាលប្រមូលផល។
- លើកទីពីរ ៖ ការត្រួតពិនិត្យធ្វើឡើង ២០ភាគរយ លើសមាជិកផលិតករដោយធ្វើឡើងកំឡុងពេលបញ្ចប់ការប្រមូលផលកសិកម្ម និងតាមដានពីការដាក់ជីរបស់ផលិតករ។

ខ. ការត្រួតពិនិត្យផ្ទៃខាងក្រៅ ៖ ដើម្បីទទួលបាននូវវិញ្ញាបនបត្របញ្ជាក់ពីគុណភាពផលិតផលកសិកម្ម សហគមន៍កសិកម្មសំបូរមានជ័យបានសហការជាមួយសាលាកសិកម្មខេត្តកំពង់ចាម និងមន្ទីរកសិកម្មមកធ្វើការត្រួតពិនិត្យដើម្បីបញ្ជាក់ពីគុណភាពមុនពេលធ្វើការនាំចេញទៅកាន់ផ្សារម៉ាក្រូ និងទីផ្សារសួនសត្វសាហ្វារីវើល ( SAFARY WORLD)។

### ២.៥.៥ ការបណ្តុះបណ្តាលអ្នកត្រួតពិនិត្យផ្ទៃខាងក្នុង

សហគមន៍បានបែងចែកជាពីរក្រុមក្នុងការត្រួតពិនិត្យផ្ទៃក្នុង ដែលក្រុមទីមួយដឹកនាំដោយប្រធានគណៈកម្មការត្រួតពិនិត្យ និងធ្វើផែនការ គឺលោកស្រី **ម៉ម គឹមហុង** និងមួយក្រុមទៀតដឹកនាំដោយអនុប្រធានគណៈកម្មាការត្រួតពិនិត្យទូទៅ គឺលោក **ហ៊ាង ជ្រឹន** ។ ការបណ្តុះបណ្តាលនេះត្រូវធ្វើឡើងកំឡុងមុនរដូវកាលប្រមូលផលកសិកម្ម ដោយផ្តោតទៅលើការត្រួតពិនិត្យលើផលិតករ ក្នុងគោលបំណងដើម្បីតាមដានសមាជិករបស់សហគមន៍កសិកម្មសំបូរមានជ័យ ថាតើបានអនុវត្តន៍ទៅតាមផែនការរបស់ខ្លួនដែរឺទេ។

### ២.៥.៦ ការផ្សព្វផ្សាយពីកសិកម្មក្នុងសហគមន៍កសិកម្មសំបូរមានជ័យ

ដើម្បីផ្សព្វផ្សាយពីផលិតផលកសិកម្មសហគមន៍បានចូលរួមចូលរួមទស្សនៈកិច្ចសិក្សាដកស្រង់ផ្លាស់ប្តូរបទពិសោធន៍ស្តីពីការគ្រប់គ្រង និងដំណើរការមុខរបររបស់សហគមន៍កសិកម្មខេត្តកំពង់ចាមនាថ្ងៃទី១០ ដល់ថ្ងៃទី១២ ខែសីហា ឆ្នាំ២០១៦ ដែលមានសហគមន៍នាំមុខផ្សេងទៀតចំនួនបួនចូលរួមផ្សព្វផ្សាយ។ មិនតែប៉ុណ្ណោះសហគមន៍បានចូលរួមតាំងពិពរណ៍ថ្នាក់ជាតិនៅកោះពេជ្រ និងតាមបណ្តាលខេត្តនានាផងដែរ។

# ជំពូកទី៣

# ការសិក្សាលើលទ្ធផលស្រាវជ្រាវ និងការវិភាគទិន្នន័យ

## ៣.១ ការសិក្សាលើលទ្ធផលស្រាវជ្រាវ

### ៣.១.១ ស្ថានភាពអភិវឌ្ឍសហគមន៍កសិកម្មសំបូរមានជ័យពីឆ្នាំ២០១៥ ដល់ ឆ្នាំ២០១៩

ក្រាហ្វិកទី១ ៖ បង្ហាញពីកំណើនសមាជិកពីឆ្នាំ២០១៥ ដល់ឆ្នាំ ២០១៩




ប្រភពទិន្នន័យ សហគមន៍កសិកម្មសំបូរមានជ័យឆ្នាំ២០១៩

យោងទៅតាមក្រាហ្វិកទី១ បានបញ្ជាក់ឱ្យដឹងថាសហគមន៍កសិកម្មសំបូរមានជ័យមានការកើនឡើងនូវចំនួនសមាជិកជាលំដាប់ចាប់ពីឆ្នាំ២០១៥ ដល់ ឆ្នាំ២០១៩។ នៅក្នុងឆ្នាំ២០១៥សហគមន៍មានសមាជិកសរុបចំនួន៨៨នាក់ នៅក្នុងឆ្នាំ២០១៦ សហគមន៍មានសមាជិកសរុបចំនួន ១២៨នាក់ នៅក្នុងឆ្នាំ២០១៧ សហគមន៍មានសមាជិកសរុបចំនួន ២៩៤នាក់ នៅក្នុងឆ្នាំ២០១៨ សហគមន៍មានសមាជិកសរុបចំនួន ៤០៥នាក់ និងនៅក្នុងឆ្នាំ២០១៩ សហគមន៍មានសមាជិកសរុបចំនួន ៥៩៧នាក់។

តារាងទី២ ៖ បង្ហាញពីកំណើនសមាជិកក្នុងប្រភេទមុខរបរកសិកម្ម ចិញ្ចឹមសត្វ និងមុខរបរដាំដុះផ្សេងៗទៀត ពី ឆ្នាំ២០១៥ ដល់ ឆ្នាំ២០១៩

| ឆ្នាំ | ប្រភេទមុខរបរ | ចំនួនសមាជិក | ភាគរយ |
|---|---|---|---|
| ២០១៥ | កសិកម្ម | ៥៦ | ៦៣,៦៤ |
| | ចិញ្ចឹមសត្វ | ១៨ | ២០,៤៥ |
| | ផ្សេងៗទៀត | ១៤ | ១៥,៩១ |
| ២០១៦ | កសិកម្ម | ៩៧ | ៧៥,៧៨ |
| | ចិញ្ចឹមសត្វ | ២២ | ១៧,១៩ |
| | ផ្សេងៗទៀត | ៩ | ៧,០៣ |
| ២០១៧ | កសិកម្ម | ២៤១ | ៨១,៩៧ |
| | ចិញ្ចឹមសត្វ | ៣២ | ១០,៨៨ |
| | ផ្សេងៗទៀត | ២១ | ៧,១៥ |
| ២០១៨ | កសិកម្ម | ៣២៧ | ៨០,៧៤ |
| | ចិញ្ចឹមសត្វ | ៥០ | ១២,៣៥ |
| | ផ្សេងៗទៀត | ២៨ | ៦,៩១ |
| ២០១៩ | កសិកម្ម | ៥១១ | ៨៥,៥៩ |
| | ចិញ្ចឹមសត្វ | ៦១ | ១០,២២ |
| | ផ្សេងៗទៀត | ២៥ | ៤,១៩ |

ប្រភពទិន្នន័យ សហគមន៍កសិកម្មសំបូរមានជ័យឆ្នាំ២០១៩

យោងតាមតារាងទី២ បានបង្ហាញឱ្យដឹងថា នៅក្នុងឆ្នាំ២០១៥ សហគមន៍មានសមាជិកសរុបចំនួន ៨៨ នាក់ ដែលក្នុងនោះមានសមាជិកចំនួន ៥៦នាក់ (៦៣,៦៤%) បានធ្វើការប្រកបរបរកសិកម្ម ហើយមាន សមាជិកចំនួន ១៨នាក់ (២០,៤៥%) បានធ្វើការប្រកបរបរចិញ្ចឹមសត្វ និងមានសមាជិកចំនួន ១៤នាក់

(១៥,៩១%) បានធ្វើការប្រកបរបរផ្សេងៗទៀត។ នៅក្នុងឆ្នាំ២០១៦ សហគមន៍មានសមាជិកសរុបចំនួន ១២៨នាក់ ដែលក្នុងនោះមានសមាជិកចំនួន ៩៧នាក់ (៧៥,៧៨%) បានធ្វើការប្រកបរបរកសិកម្ម ហើយមានសមាជិកចំនួន ២២នាក់ (១៧,១៩%) បានធ្វើការប្រកបរបរចិញ្ចឹមសត្វ និងមានសមាជិកចំនួន ៩នាក់ (៧,០៣%) បានធ្វើការប្រកបរបរផ្សេងៗទៀត។ នៅក្នុងឆ្នាំ២០១៧ សហគមន៍មានសមាជិកសរុបចំនួន ២៩៤នាក់ ដែលក្នុងនោះមានសមាជិកចំនួន ២៤១នាក់ (៨១,៩៧%) បានធ្វើការប្រកបរបរកសិកម្ម ហើយមានសមាជិកចំនួន ៣២នាក់ (១០,៨៨%) បានធ្វើការប្រកបរបរចិញ្ចឹមសត្វ និងមានសមាជិកចំនួន ២១នាក់ (៧,១៥%) បានធ្វើការប្រកបរបរផ្សេងៗទៀត។ នៅក្នុងឆ្នាំ២០១៨ សហគមន៍មានសមាជិកសរុបចំនួន ៤០៥ នាក់ ដែលក្នុងនោះមានសមាជិកចំនួន ៣២៧នាក់ (៨០,៧៤%) បានធ្វើការប្រកបរបរកសិកម្ម ហើយមានសមាជិកចំនួន ៥០នាក់ (១២,៣៥%) បានធ្វើការប្រកបរបរចិញ្ចឹមសត្វ និងមានសមាជិកចំនួន ២៨នាក់ (៦,៩១%) បានធ្វើការប្រកបរបរផ្សេងៗទៀត។ នៅក្នុងឆ្នាំ ២០១៩ សហគមន៍មានសមាជិកសរុបចំនួន ៥៩៧នាក់ ដែលក្នុងនោះមានសមាជិកចំនួន ៥១១នាក់ (៨៥,៥៩%) បានធ្វើការប្រកបរបរកសិកម្ម ហើយមានសមាជិកចំនួន ៦១នាក់ (១០,២២%) បានធ្វើការប្រកបរបរចិញ្ចឹមសត្វ និងមានសមាជិកចំនួន ២៥នាក់ (៤,១៩%) បានធ្វើការប្រកបរបរផ្សេងៗទៀត។

តារាងទី ៣ ៖ បង្ហាញពីប្រភេទឧបករណ៍ដែលសមាជិកក្នុងសហគមន៍ប្រើប្រាស់ក្នុងការប្រកបមុខរបរកសិកម្ម ពីឆ្នាំ២០១៥ ដល់ ឆ្នាំ២០១៩

| ឆ្នាំ | ប្រភេទឧបករណ៍ | ចំនួនសមាជិក | ភាគរយ |
|---|---|---|---|
| ២០១៥ | ឧបករណ៍បែបបុរាណ | ៥២ | ៩២,៨៦ |
| | គ្រឿងយន្តតិចតួច | ៤ | ៧,១៤ |
| ២០១៦ | ឧបករណ៍បែបបុរាណ | ៨៣ | ៨៥,៥៧ |
| | គ្រឿងយន្តតិចតួច | ១៤ | ១៤,៤៣ |
| ២០១៧ | ឧបករណ៍បែបបុរាណ | ២០៩ | ៨៦,៧២ |
| | គ្រឿងយន្តតិចតួច | ៣២ | ១៣,២៨ |
| ២០១៨ | ឧបករណ៍បែបបុរាណ | ២៥៦ | ៧៨,២៩ |
| | គ្រឿងយន្តតិចតួច | ៧១ | ២១,៧១ |
| ២០១៩ | ឧបករណ៍បែបបុរាណ | ៤២៣ | ៨២,៧៨ |
| | គ្រឿងយន្តតិចតួច | ៨៨ | ១៧,២២ |

ប្រភពទិន្នន័យ សហគមន៍កសិកម្មសំបូរមានជ័យឆ្នាំ២០១៩

យោងទៅតាមតារាងទី៣ បានបង្ហាញឱ្យដឹងថានៅក្នុងឆ្នាំ២០១៥ សហគមន៍មានសមាជិកសរុបចំនួន ៥៦នាក់ធ្វើការដាំដុះដំណាំកសិកម្ម ដែលក្នុងនោះមានសមាជិកចំនួន ៥២នាក់ (៩២,៨៦%) បានប្រើប្រាស់ឧបករណ៍បែបបុរាណក្នុងការធ្វើកសិកម្ម និងមានសមាជិកចំនួន ៤នាក់ (៧,១៤%) មានគ្រឿងយន្តតិចតួចសម្រាប់ធ្វើកសិកម្ម។ នៅក្នុងឆ្នាំ២០១៦ សហគមន៍មានសមាជិកសរុបចំនួន ៩៧នាក់ធ្វើការដាំដុះដំណាំកសិកម្ម ដែលក្នុងនោះមានសមាជិកចំនួន ៨៣នាក់ (៨៥,៥៧%) បានប្រើប្រាស់ឧបករណ៍បែបបុរាណក្នុងការធ្វើកសិកម្ម និងមានសមាជិកចំនួន ១៤នាក់ (១៤,៤៣%) មានគ្រឿងយន្តតិចតួចសម្រាប់ធ្វើកសិកម្ម។ នៅក្នុងឆ្នាំ២០១៧ សហគមន៍មានសមាជិកសរុបចំនួន ២៤១នាក់ធ្វើការដាំដុះដំណាំកសិកម្មដែលក្នុងនោះមានសមាជិកចំនួន ២០៩នាក់ (៨៦,៧២%) បានប្រើប្រាស់ឧបករណ៍បែបបុរាណក្នុងការធ្វើកសិកម្ម និងមានសមាជិកចំនួន ៣២នាក់ (១៣,២៨%) មានគ្រឿងយន្តតិចតួចសម្រាប់ធ្វើកសិកម្ម។ នៅក្នុងឆ្នាំ២០១៨ សហគមន៍មានសមាជិកសរុបចំនួន ៣២៧នាក់ធ្វើការដាំដុះដំណាំកសិកម្ម ដែលក្នុងនោះមានសមាជិកចំនួន ២៥៦នាក់ (៧៨,២៩%) បានប្រើប្រាស់ឧបករណ៍បែបបុរាណក្នុងការធ្វើកសិកម្ម និងមានសមាជិកចំនួន ៧១នាក់ (២១,៧១%) មានគ្រឿងយន្តតិចតួចសម្រាប់ធ្វើ កសិកម្ម។ នៅក្នុងឆ្នាំ២០១៩សហគមន៍មានសមាជិកសរុបចំនួន ៥១១នាក់ធ្វើការដាំដុះដំណាំកសិកម្ម ដែលក្នុងនោះមានសមាជិកចំនួន ៤២៣នាក់ (៨២,៧៨%) បានប្រើប្រាស់ឧបករណ៍បែបបុរាណក្នុងការធ្វើកសិកម្ម និងមានសមាជិកចំនួន ៨៨នាក់ (១៧,២២%) មានគ្រឿងយន្តតិចតួចសម្រាប់ធ្វើកសិកម្ម។

តារាងទី៤ ៖ បង្ហាញពីប្រភពទឹកដែលសមាជិកក្នុងសហគមន៍ប្រើប្រាស់ក្នុងការស្រោចស្រពដំណាំកសិកម្មពីឆ្នាំ២០១៥ ដល់ ឆ្នាំ២០១៩

| ឆ្នាំ | ប្រភពទឹកប្រើប្រាស់ | ចំនួនសមាជិក | ភាគរយ |
|---|---|---|---|
| ២០១៥ | ទឹកអណ្តូង | ៥៦ | ១០០ |
| | ទឹកម៉ាស៊ីន | 0 | 0 |
| ២០១៦ | ទឹកអណ្តូង | ៩១ | ៩៣,៨១ |
| | ទឹកម៉ាស៊ីន | ៦ | ៦,១៩ |
| ២០១៧ | ទឹកអណ្តូង | ២០១ | ៨៣,៤០ |
| | ទឹកម៉ាស៊ីន | ៤០ | ១៦,៦០ |
| ២០១៨ | ទឹកអណ្តូង | ២៥៨ | ៧៨,៩០ |
| | ទឹកម៉ាស៊ីន | ៦៩ | ២១,១០ |
| ២០១៩ | ទឹកអណ្តូង | ៤០០ | ៧៨,២៨ |
| | ទឹកម៉ាស៊ីន | ១១១ | ២១,៧២ |

ប្រភពទិន្នន័យ សហគមន៍កសិកម្មសំបូរមានជ័យឆ្នាំ២០១៩

យោងទៅតាមតារាងទី៤ បានបង្ហាញឱ្យដឹងថានៅក្នុងឆ្នាំ២០១៥ សហគមន៍មានសមាជិកសរុបចំនួន ៥៦នាក់ធ្វើការដាំដុះដំណាំកសិកម្ម ដែលក្នុងនោះមានសមាជិកចំនួន ៥៦នាក់ (១០០%) បានប្រើប្រាស់ទឹកអណ្តូងសម្រាប់ស្រោចស្រពដំណាំកសិកម្ម និងមិនមានសមាជិកណាម្នាក់មានការប្រើទឹកម៉ាស៊ីនសម្រាប់ស្រោចស្រពដំណាំកសិកម្មនោះទេ។ នៅក្នុងឆ្នាំ២០១៦ សហគមន៍មានសមាជិកសរុបចំនួន ៩៧នាក់ធ្វើការដាំដុះដំណាំកសិកម្ម ដែលក្នុងនោះមានសមាជិកចំនួន ៩១នាក់ (៩៣,៨១%) បានប្រើប្រាស់ទឹកអណ្តូងសម្រាប់ស្រោចស្រពដំណាំកសិកម្ម និងមានសមាជិកចំនួន ៦នាក់ (៦,១៩%) បានប្រើប្រាស់ទឹកម៉ាស៊ីនសម្រាប់ស្រោចស្រពដំណាំកសិកម្ម។ នៅក្នុងឆ្នាំ២០១៧ សហគមន៍មានសមាជិកសរុបចំនួន ២៤១នាក់ធ្វើការដាំដុះដំណាំកសិកម្ម ដែលក្នុងនោះមានសមាជិកចំនួន ២០១នាក់ (៨៣,៤០%) បានប្រើប្រាស់ទឹកអណ្តូងសម្រាប់ស្រោចស្រពដំណាំកសិកម្ម និងមានសមាជិកចំនួន ៤០នាក់ (១៦,៦០%) បានប្រើប្រាស់ទឹកម៉ាស៊ីនសម្រាប់ស្រោចស្រពដំណាំកសិកម្ម។ នៅក្នុងឆ្នាំ២០១៨ សហគមន៍មានសមាជិកសរុបចំនួន ៣២៧នាក់ធ្វើការដាំដុះដំណាំកសិកម្ម ដែលក្នុងនោះមានសមាជិកចំនួន ២៥៨នាក់ (៧៨,៩០%) បានប្រើប្រាស់ទឹកអណ្តូងសម្រាប់ស្រោចស្រពដំណាំកសិកម្ម និងមានសមាជិកចំនួន ៦៩នាក់ (២១,១០%) បានប្រើប្រាស់ទឹកម៉ាស៊ីនសម្រាប់ស្រោចស្រពដំណាំកសិកម្ម។ នៅក្នុងឆ្នាំ២០១៩សហគមន៍មានសមាជិកសរុបចំនួន ៥១១នាក់ធ្វើការដាំដុះដំណាំកសិកម្ម ដែលក្នុងនោះមានសមាជិកចំនួន ៤០០នាក់ (៧៨,២៨) បានប្រើប្រាស់ទឹកអណ្តូងសម្រាប់ស្រោចស្រពដំណាំកសិកម្ម និងមានសមាជិកចំនួន ១១១នាក់ (២១,៧២%)បានប្រើប្រាស់ទឹកម៉ាស៊ីនសម្រាប់ស្រោចស្រពដំណាំកសិកម្ម។

### ៣.១.២ បង្ហាញពីស្ថានភាពដើមទុនសម្រាប់ប្រកបរបរកសិកម្មរបស់សមាជិកសហគមន៍កសិកម្មសំបូរមានជ័យពីឆ្នាំ២០១៥ ដល់ ឆ្នាំ២០១៩

តារាងទី ៥ ៖ បង្ហាញពីស្ថានភាពដើមទុនរបស់សមាជិកសហគមន៍ក្នុងការប្រកបរបរកសិកម្មពីឆ្នាំ២០១៥ ដល់ ឆ្នាំ២០១៩

| ឆ្នាំ | ចំនួនទុនសម្រាប់ប្រកបរបរកសិកម្ម | ដើមទុនសរុប (រៀល) | ចំនួនសមាជិក | ចំនួនសមាជិកសរុប | ភាគរយ |
|---|---|---|---|---|---|
| ២០១៥ | ចំនួនទុនខ្វះខាត | ៥,១២០,០០០ | ៤៧ | ៥៦ | ៨៣,៩៣ |
| | ចំនួនទុនគ្រប់គ្រាន់ | ៨,០១១,០០០ | ៩ | | ១៦,០៧ |
| ២០១៦ | ចំនួនទុនខ្វះខាត | ១២,៥៥០,០៥០ | ៧៧ | ៩៧ | ៧៩,៣៨ |
| | ចំនួនទុនគ្រប់គ្រាន់ | ៥៧,៩០០,១៥០ | ២០ | | ២០,៦២ |
| ២០១៧ | ចំនួនទុនខ្វះខាត | ២០,០៥៤,៣០០ | ១៩៤ | ២៤១ | ៨០,៥០ |
| | ចំនួនទុនគ្រប់គ្រាន់ | ៧០,៥៨០,៨០០ | ៤៧ | | ១៩,៥០ |
| ២០១៨ | ចំនួនទុនខ្វះខាត | ២៥,៦០០,៥០០ | ២៥០ | ៣២៧ | ៧៦,៤៥ |
| | ចំនួនទុនគ្រប់គ្រាន់ | ១០៥,២៣៣,២២០ | ៧៧ | | ២៣,៥៥ |
| ២០១៩ | ចំនួនទុនខ្វះខាត | ៣២,៦៥៥,៥៥០ | ៤១២ | ៥១១ | ៨០,៦៣ |
| | ចំនួនទុនគ្រប់គ្រាន់ | ១៦៦,៦៤៤,៤៥០ | ៩៩ | | ១៩,៣៧ |

យោងទៅតាមតារាងទី៥ បានបង្ហាញឱ្យដឹងថានៅក្នុងឆ្នាំ២០១៥ សហគមន៍មានសមាជិកសរុបចំនួន ៥៦នាក់ធ្វើការដាំដុះដំណាំកសិកម្ម ដែលក្នុងនោះមានសមាជិកចំនួន ៤៧នាក់ (៨៣,៩៣%) មានដើមទុនខ្វះខាតក្នុងការប្រកបរបរកសិកម្មសរុបចំនួន ៥,១២០,០០០រៀល និងមានសមាជិកចំនួន ៩នាក់ (១៦,០៧%) ដែលមានដើមទុនគ្រប់គ្រាន់ក្នុងការប្រកបរបរកសិកម្មសរុបចំនួន ៨,០១១,០០០រៀល។ នៅក្នុងឆ្នាំ២០១៦ សហគមន៍មានសមាជិកសរុបចំនួន ៩៧នាក់ធ្វើការដាំដុះដំណាំកសិកម្ម ដែលក្នុងនោះមានសមាជិកចំនួន ៧៧នាក់ (៧៩,៣៨%) មានដើមទុនខ្វះខាតក្នុងការប្រកបរបរកសិកម្មសរុបចំនួន ១២,៥៥០,០៥០រៀល និងមានសមាជិកចំនួន ២០នាក់ (២០,៦២%) ដែលមានដើមទុនគ្រប់គ្រាន់ក្នុងការប្រកបរបរកសិកម្មសរុបចំនួន ៥៧,៩០០,១៥០រៀល។ នៅក្នុងឆ្នាំ២០១៧ សហគមន៍មានសមាជិកសរុបចំនួន ២៤១នាក់ធ្វើការដាំដុះដំណាំកសិកម្ម ដែលក្នុងនោះមានសមាជិកចំនួន ១៩៤នាក់ (៨០,៥០%) មានដើមទុនខ្វះខាតក្នុងការប្រកបរបរកសិកម្មសរុបចំនួន ២០,០៥៤,៣០០រៀល និងមាន

សមាជិកចំនួន ៤៧នាក់ (១៩,៥០%) ដែលមានដើមទុនគ្រប់គ្រាន់ក្នុងការប្រកបរបរកសិកម្មសរុបចំនួន ៧០,៥៨០,៨០០រៀល។ នៅក្នុងឆ្នាំ២០១៨ សហគមន៍មានសមាជិកសរុបចំនួន ៣២៧នាក់ធ្វើការដាំដុះដំណាំកសិកម្ម ដែលក្នុងនោះមានសមាជិកចំនួន ២៥០នាក់ (៧៦,៤៥%) មានដើមទុនខ្វះខាតក្នុងការប្រកបរបរកសិកម្មសរុបចំនួន ២៥,៦០០,៥០០រៀល និងមានសមាជិកចំនួន ៧៧នាក់ (២៣,៥៥%) ដែលមានដើមទុនគ្រប់គ្រាន់ក្នុងការប្រកបរបរកសិកម្មសរុបចំនួន ១០៥,២៣៣,២២០រៀល។ នៅក្នុងឆ្នាំ ២០១៩ សហគមន៍មានសមាជិកសរុបចំនួន ៥១១នាក់ធ្វើការដាំដុះដំណាំកសិកម្ម ដែលក្នុងនោះមានសមាជិកចំនួន ៤១២នាក់ (៨០,៦៣%) មានដើមទុនខ្វះខាតក្នុងការប្រកបរបរកសិកម្មសរុបចំនួន ៣២,៦៥៥,៥៥០រៀល និងមានសមាជិកចំនួន ៩៩នាក់ (១៩,៣៧%)ដែលមានដើមទុនគ្រប់គ្រាន់ក្នុការប្រកបរបរកសិកម្មសរុបចំនួន ១៦៦,៦៤៤,៤៥០រៀល។

## ៣.២ ការវិភាគទិន្នន័យ

### ៣.២.១ ស្ថានភាពដើមទុនខ្វះខាតជាមធ្យមរបស់សមាជិកសហគមន៍កសិកម្មសំបូរមានជ័យក្នុងការប្រកបរបរកសិកម្មពីឆ្នាំ២០១៥ ដល់ ឆ្នាំ២០១៩

តារាងទី ៦ ៖ បង្ហាញពីស្ថានភាពដើមទុនខ្វះខាតរបស់សមាជិកសហគមន៍ក្នុងការប្រកបរបរកសិកម្មពីឆ្នាំ២០១៥ ដល់ ឆ្នាំ២០១៩

| ឆ្នាំ | ចំនួនសមាជិកដែលខ្វះខាតដើមទុនក្នុងការប្រកបរបរកសិកម្ម | ដើមទុនដែលខ្វះខាតសរុប(រៀល) |
|---|---|---|
| ២០១៥ | ៤៧ | ៥,១២០,០០០ |
| ២០១៦ | ៧៧ | ១២,៥៥០,០៥០ |
| ២០១៧ | ១៩៤ | ២០,០៥៤,៣០០ |
| ២០១៨ | ២៥០ | ២៥,៦០០,៥០០ |
| ២០១៩ | ៤១២ | ៣២,៦៥៥,៥៥០ |
| **សរុប** | | **៩៥,៩៨០,៤០០រៀល** |

តាង

$X_i$ : ជាចំនួនទុនដែលខ្វះខាតសរុបរបស់សមាជិកក្នុងសហគមន៍សម្រាប់ធ្វើការប្រកបរបរកសិកម្ម

$\bar{X}$ : ជាចំនួនមធ្យមនៃសមាជិកដែលខ្វះខាតដើមទុនក្នុងការប្រកបរបរកសិកម្ម

n : ជាចំនួនឆ្នាំ

យើងមាន $X_i$ = ៩៥,៩៨០,៤០០ រៀល n = ៥ ឆ្នាំ

តាមរូបមន្ត $\bar{X} = \frac{\sum_{i=1}^{n} xi}{n} = \frac{៩៥,៩៨០,៤០០}{៥}$ = ១៩,១៩៦,០៨០ រៀល

ដូចនេះ ចាប់តាំងពីឆ្នាំ២០១៥ ដល់ឆ្នាំ២០១៩ សមាជិកសហគមន៍កសិកម្មសំបូរមានជ័យមានការខ្វះខាតដើមទុនក្នុងការប្រកបរបរកសិកម្មជាមធ្យមសរុបចំនួន $\bar{X}$ = ១៩,១៩៦,០៨០រៀល ក្នុងរយៈពេល ៥ឆ្នាំមកនេះ។

តារាងទី៧៖ បង្ហាញពីភាគរយនៃដើមទុនដែលខ្វះខាតរបស់សមាជិកសហគមន៍កសិកម្មក្នុងការប្រកបរបរកសិកម្មពីឆ្នាំ ២០១៥ ដល់ ឆ្នាំ២០១៩

| ឆ្នាំ | ដើមទុនដែលសមាជិកខ្វះខាតក្នុងការប្រកបរបរកសិកម្ម | ភាគរយ |
|---|---|---|
| ២០១៥ ដល់ ២០១៦ | ដើមទុនខ្វះខាតក្នុងឆ្នាំ២០១៥ = ៥,១២០,000 រៀល | ១,៤៥% |
| | ដើមទុនខ្វះខាតក្នុងឆ្នាំ២០១៦ = ១២,៥៥០,០៥០ រៀល | |
| ២០១៦ ដល់ ២០១៧ | ដើមទុនខ្វះខាតក្នុងឆ្នាំ២០១៦ = ១២,៥៥០,០៥០ រៀល | ០,៦០% |
| | ដើមទុនខ្វះខាតក្នុងឆ្នាំ២០១៧ = ២០,០៥៤,៣០០ រៀល | |
| ២០១៧ ដល់ ២០១៨ | ដើមទុនខ្វះខាតក្នុងឆ្នាំ២០១៧ = ២០,០៥៤,៣០០ រៀល | ០,២៨% |
| | ដើមទុនខ្វះខាតក្នុងឆ្នាំ២០១៨ = ២៥,៦០០,៥០០ រៀល | |
| ២០១៨ ដល់ ២០១៩ | ដើមទុនខ្វះខាតក្នុងឆ្នាំ២០១៨ = ២៥,៦០០,៥០០ រៀល | ០,២៨% |
| | ដើមទុនខ្វះខាតក្នុងឆ្នាំ២០១៩ = ៣២,៦៥៥,៥៥០ រៀល | |

ប្រភពទិន្នន័យ សហគមន៍កសិកម្មសំបូរមានជ័យឆ្នាំ២០២០

តាង

- $Y_1$ : ជាឆ្នាំដែលសមាជិកសហគមន៍មានដើមទុនខ្វះខាតសរុបក្នុងឆ្នាំ ២០១៥
- $Y_2$ : ជាឆ្នាំដែលសមាជិកសហគមន៍មានដើមទុនខ្វះខាតសរុបក្នុងឆ្នាំ ២០១៦
- $Y_3$ : ជាឆ្នាំដែលសមាជិកសហគមន៍មានដើមទុនខ្វះខាតសរុបក្នុងឆ្នាំ ២០១៧
- $Y_4$ : ជាឆ្នាំដែលសមាជិកសហគមន៍មានដើមទុនខ្វះខាតសរុបក្នុងឆ្នាំ ២០១៨
- $Y_5$ : ជាឆ្នាំដែលសមាជិកសហគមន៍មានដើមទុនខ្វះខាតសរុបក្នុងឆ្នាំ ២០១៩

\+ យើងមាន $Y_1$ = ៥,១២០,០០០ រៀល $Y_2$ = ១២,៥៥០,០៥០ រៀល

តាមរូបមន្ត : ភាគរយនៃដើមទុនខ្វះខាតចន្លោះ $Y_{1\rightarrow2} = \frac{Y2-Y1}{Y1} = \frac{១២,៥៥០,០៥០-៥,១២០,០០០}{៥,១២០,០០០}$ = ១,៤៥%

ដូចនេះ នៅចន្លោះឆ្នាំ២០១៥ ដល់ ឆ្នាំ២០១៦ ភាគរយនៃដើមទុនខ្វះខាតរបស់សមាជិកសហគមន៍ក្នុងការប្រកបរបរកសិកម្មគឺស្មើនឹង ១,៤៥%។ ដោយសារតែនៅចន្លោះឆ្នាំ២០១៥ ដល់ឆ្នាំ២០១៦សមាជិកសហគមន៍មានការប្រើប្រាស់ឧបករណ៍ ឬគ្រឿងយន្តបែបទំនើបក្នុងការបង្ករបង្កើនផលកសិកម្មនៅក្នុងកម្រិតទាបនៅឡើយ។

\+ យើងមាន $Y_2$ = ១២,៥៥០,០៥០ រៀល $Y_3$ = ២០,០៥៤,៣០០ រៀល

តាមរូបមន្ត : ភាគរយនៃដើមទុនខ្វះខាតចន្លោះ $Y_{2\rightarrow3} = \frac{Y3-Y2}{Y2} = \frac{២០,០៥៤,៣០០-១២,៥៥០,០៥០}{១២,៥៥០,០៥០}$ = ០,៦០%

ដូចនេះ នៅចន្លោះឆ្នាំ ១០១៦ ដល់ ឆ្នាំ២០១៧ ភាគរយនៃដើមទុនខ្វះខាតរបស់សមាជិកសហគមន៍ក្នុងការប្រកបរបរកសិកម្មគឺស្មើនឹង០,៦០%។ បើធៀបទៅនឹងភាគរយនៃដើមទុនរបស់សមាជិកដែលខ្វះខាតក្នុងការប្រកបរបរកសិកម្មចន្លោះឆ្នាំ ២០១៥ ដល់ ឆ្នាំ២០១៦ គឺមានការថយចុះស្មើនឹង ០,៨៥%។ ដោយសារតែនៅក្នុងចន្លោះឆ្នាំ២០១៦ ដល់ឆ្នាំ ២០១៧ សហគមន៍មានដៃគូសហការចំនួនពីរគឺ ផ្សារម៉ាក្រូ និងសួនសត្វសាហ្សារីលើការចុះកុងត្រាបញ្ជាទិញនូវទិន្នផលកសិកម្មពីសមាជិកទាំងអស់ ដោយឱ្យតម្លៃសមស្របទៅនឹងតម្លៃ ទីផ្សារនៅក្នុងប្រទេសកម្ពុជា។

\+ យើងមាន $Y_3$ = ២០,០៥៤,៣០០ រៀល $Y_4$ = ២៥,៦០០,៥០០ រៀល

តាមរូបមន្ត : ភាគរយនៃដើមទុនខ្វះខាតចន្លោះ $Y_{3\rightarrow4} = \frac{Y4-Y3}{Y3} = \frac{២៥,៦០០,៥០០-២០,០៥៤,៣០០}{២០,០៥៤,៣០០}$ = ០,២៨%

ដូចនេះ នៅចន្លោះឆ្នាំ២០១៧ ដល់ ឆ្នាំ២០១៨ ភាគរយនៃដើមទុនខ្វះខាតរបស់សមាជិកសហគមន៍ក្នុងការប្រកបរបរកសិកម្មគឺស្មើនឹង០,២៨%។ បើបើធៀបទៅនឹងភាគរយនៃដើមទុនរបស់សមាជិកដែលខ្វះខាតក្នុងការប្រកបរបរកសិកម្មចន្លោះឆ្នាំ ២០១៦ ដល់ឆ្នាំ២០១៧ គឺមានការថយចុះស្មើនឹង ០,៣២%។

ដោយសារតែនៅចន្លោះឆ្នាំ២០១៧ ដល់ ឆ្នាំ២០១៨ សហគមន៍បានបង្កើនការដាំដុះកសិកម្មឱ្យច្រើនជាងកាលពីចន្លោះឆ្នាំ២០១៦ ដល់ ឆ្នាំ២០១៧ ដោយផ្តែកទៅលើការបង្កើនឧបករណ៍ដាំដុះដំណាំកសិកម្ម និងគ្រឿងយន្តទំនើបក្នុងការពន្លឿនទិន្នផលកសិកម្មឱ្យទាន់ទៅតាមតម្រូវការរបស់អតិថិជន និងការបញ្ជាទិញពីដៃគូសហការ។

\+ យើងមាន $Y_4$ = ២៥,៦០០,៥០០ រៀល $Y_5$ = ៣២,៦៥៥,៥៥០ រៀល

តាមរូបមន្ត : ភាគរយនៃដើមទុនខ្វះខាតចន្លោះ $Y_{4\to5} = \frac{Y5-Y4}{Y4} = \frac{៣២,៦៥៥,៥៥០-២៥,៦០០,៥០០}{២៥,៦០០,៥០០}$ = 0,២៨%

ដូចនេះ នៅចន្លោះឆ្នាំ២០១៨ ដល់ ឆ្នាំ២០១៩ ភាគរយនៃដើមទុនខ្វះខាតរបស់សមាជិកសហគមន៍ក្នុងការប្រកបរបរកសិកម្មគឺស្មើនឹង 0,២៨%។ នេះបង្ហាញឱ្យដឹងថា សហគមន៍មិនមានការប្រែប្រួលនូវភាគរយដើមទុនខ្វះខាតរបស់សមាជិកសហគមន៍ក្នុងការប្រកបរបរកសិកម្មឡើយ បើធៀបទៅនឹងចន្លោះឆ្នាំ២០១៧ ដល់ ឆ្នាំ២០១៨ គឺមានន័យថាសហគមន៍នូវតែរក្សាបាននូវបរិមាណនៃការដាំដុះដំណាំកសិកម្ម និងការនាំចេញទៅកាន់ទីផ្សារក្នុងបរិមាណដដែល ពីព្រោះសហគមន៍កសិកម្មមានគម្រោងបង្កើនការចិញ្ចឹមសត្វលើផ្ទៃដី ១០ហិកតានៅក្នុងឆ្នាំ២០២០ វិញ។

### ៣.២.២ ស្ថានភាពដើមទុនគ្រប់គ្រាន់ជាមធ្យមរបស់សមាជិកសហគមន៍កសិកម្មសំបូរមានជ័យក្នុងការប្រកបរបរកសិកម្មពីឆ្នាំ២០១៥ ដល់ ឆ្នាំ២០១៩

តារាងទី ៨ ៖ បង្ហាញពីស្ថានភាពដើមទុនគ្រប់គ្រាន់របស់សមាជិកសហគមន៍ក្នុងការប្រកបរបរកសិកម្មពីឆ្នាំ២០១៥ ដល់ ឆ្នាំ២០១៩

| ឆ្នាំ | ចំនួនសមាជិកដែលមានដើមទុនគ្រប់គ្រាន់សម្រាប់ប្រកបរបរកសិកម្ម | ដើមទុនដែលគ្រប់គ្រាន់សរុប(រៀល) |
|---|---|---|
| ២០១៥ | ៩ | ៨,០១១,000 |
| ២០១៦ | ២០ | ៥៧,៩00,១៥0 |
| ២០១៧ | ៤៧ | ៧0,៥៨0,៨00 |
| ២០១៨ | ៧៧ | ១0៥,២៣៣,២២0 |
| ២០១៩ | ៩៩ | ១៦៦,៦៤៤,៤៥0 |
| **សរុប** | | **៤០៨,៣៦៩,៦២០រៀល** |

ប្រភពទិន្នន័យ សហគមន៍កសិកម្មសំបូរមានជ័យឆ្នាំ២០១៩

តាង

$Y_i$ : ជាចំនួនដើមទុនដែលគ្រប់គ្រាន់សរុបរបស់សមាជិកសហគមន៍ក្នុងការប្រកបរបរកសិកម្ម

$\bar{Y}$ : ជាចំនួនមធ្យមនៃសមាជិកដែលមានដើមទុនគ្រប់គ្រាន់ក្នុងការប្រកបរបរកសិកម្ម

n : ជាចំនួនឆ្នាំ

+ យើងមាន $Y_i$ = ៤០៨,៣៩៦,៦២០ រៀល n = ៥ ឆ្នាំ

តាមរូបមន្ត $\bar{Y} = \frac{\sum_{i=1}^{n} yi}{n} = \frac{៤០៨,៣៩៦,៦២០}{៥} =$ ៨១,៦៧៩,៣២៤ រៀល

ដូចនេះ ចាប់តាំងពីឆ្នាំ២០១៥ ដល់ឆ្នាំ២០១៩ សមាជិកសហគមន៍កសិកម្មសំបូរមានជ័យមានដើមទុនគ្រប់គ្រាន់ក្នុងការប្រកបរបរកសិកម្មជាមធ្យមសរុបចំនួន $\bar{X}$ = ៨១,៦៧៩,៣២៤រៀល ក្នុងរយៈពេល៥ឆ្នាំមកនេះ។

តារាងទី៩៖ បង្ហាញពីភាគរយនៃដើមទុនគ្រប់គ្រាន់របស់សមាជិកសហគមន៍កសិកម្មក្នុងការប្រកបរបរកសិកម្មពីឆ្នាំ ២០១៥ ដល់ ឆ្នាំ២០១៩

| ឆ្នាំ | ដើមទុនគ្រប់គ្រាន់ដែលសមាជិកធ្វើការប្រកបរបរកសិកម្ម | ភាគរយ |
|---|---|---|
| ២០១៥ ដល់ ២០១៦ | ដើមទុនគ្រប់គ្រាន់ក្នុងឆ្នាំ២០១៥ = ៨,០១១,០០០ រៀល | ៦,២៣% |
| | ដើមទុនគ្រប់គ្រាន់ក្នុងឆ្នាំ២០១៦ = ៥៧,៩០០,១៥០ រៀល | |
| ២០១៦ ដល់ ២០១៧ | ដើមទុនគ្រប់គ្រាន់ក្នុងឆ្នាំ២០១៦ = ៥៧,៩០០,១៥០ រៀល | ០,២២% |
| | ដើមទុនគ្រប់គ្រាន់ក្នុងឆ្នាំ២០១៧ = ៧០,៥៨០,៨០០ រៀល | |
| ២០១៧ ដល់ ២០១៨ | ដើមទុនគ្រប់គ្រាន់ក្នុងឆ្នាំ២០១៧ = ៧០,៥៨០,៨០០ រៀល | ០,៤៩% |
| | ដើមទុនគ្រប់គ្រាន់ក្នុងឆ្នាំ២០១៨ = ១០៥,២៣៣,២២០ រៀល | |
| ២០១៨ ដល់ ២០១៩ | ដើមទុនគ្រប់គ្រាន់ក្នុងឆ្នាំ២០១៨ = ១០៥,២៣៣,២២០ រៀល | ០,៥៨% |
| | ដើមទុនគ្រប់គ្រាន់ក្នុងឆ្នាំ២០១៩ = ១៦៦,៦៤៤,៤៥០ រៀល | |

ប្រភពទិន្នន័យ សហគមន៍កសិកម្មសំបូរមានជ័យឆ្នាំ២០២០

តាង

- $Y_1$ : ជាឆ្នាំដែលសមាជិកសហគមន៍មានដើមទុនប្រកបរបរកសិកម្មគ្រប់គ្រាន់សរុបក្នុងឆ្នាំ ២០១៥
- $Y_2$ : ជាឆ្នាំដែលសមាជិកសហគមន៍មានដើមទុនប្រកបរបរកសិកម្មគ្រប់គ្រាន់សរុបក្នុងឆ្នាំ ២០១៦
- $Y_3$ : ជាឆ្នាំដែលសមាជិកសហគមន៍មានដើមទុនប្រកបរបរកសិកម្មគ្រប់គ្រាន់សរុបក្នុងឆ្នាំ ២០១៧
- $Y_4$ : ជាឆ្នាំដែលសមាជិកសហគមន៍មានដើមទុនប្រកបរបរកសិកម្មគ្រប់គ្រាន់សរុបក្នុងឆ្នាំ ២០១៨
- $Y_5$ : ជាឆ្នាំដែលសមាជិកសហគមន៍មានដើមទុនប្រកបរបរកសិកម្មគ្រប់គ្រាន់សរុបក្នុងឆ្នាំ ២០១៩

\+ យើងមាន $Y_1$ = ៥៨,០១១,០០០ រៀល $Y_2$= ៥៧,៩០០,១៥០រៀល

តាមរូបមន្ត : ភាគរយនៃដើមទុនគ្រប់គ្រាន់ចន្លោះ $Y_{1\to2} = \frac{Y2-Y1}{Y1} = \frac{៥៧,៩០០,១៥០-៥៨,០១១,០០០}{៥៨,០១១,០០០}$ = ៦,២៣%

ដូចនេះ នៅចន្លោះឆ្នាំ២០១៥ ដល់ ឆ្នាំ២០១៦ ភាគរយនៃដើមទុនគ្រប់គ្រាន់របស់សមាជិកសហគមន៍កសិកម្មសំបូរមានជ័យក្នុងការប្រកបរបរកសិកម្មគឺស្មើនឹង ៦,២៣% ។ ដោយសារនៅក្នុងចន្លោះឆ្នាំ ២០១៥ ដល់ឆ្នាំ២០១៦សមាជិកធ្វើការប្រកបរបរកសិកម្មក្នុងទំហំផ្ទៃដីតូចល្មមប៉ុន្តែទទួលបានទិន្នផលកសិកម្មច្រើន។

\+ យើងមាន $Y_2$ = ៥៧,៩០០,១៥០រៀល $Y_3$= ៧០,៥៨០,៨០០រៀល

តាមរូបមន្ត : ភាគរយនៃដើមទុនគ្រប់គ្រាន់ចន្លោះ $Y_{2\to3} = \frac{Y3-Y2}{Y2} = \frac{៧០,៥៨០,៨០០-៥៧,៩០០,១៥០}{៥៧,៩០០,១៥០}$ = ០,២២%

ដូចនេះ នៅចន្លោះឆ្នាំ២០១៦ ដល់ ឆ្នាំ២០១៧ ភាគរយនៃដើមទុនគ្រប់គ្រាន់របស់សមាជិកសហគមន៍កសិកម្មសំបូរមានជ័យក្នុងការប្រកបរបរកសិកម្មគឺស្មើនឹង ០,២២% ។ បើធៀបទៅនឹងភាគរយនៃដើមទុនគ្រប់គ្រាន់របស់សមាជិកក្នុងការប្រកបរបរកសិកម្មចន្លោះឆ្នាំ ២០១៥ ដល់ ឆ្នាំ២០១៦ គឺមានការថយចុះដល់ទៅ៦,០១%។ ដោយសារតែនៅក្នុងចន្លោះឆ្នាំ២០១៦ ដល់ឆ្នាំ២០១៧ សហគមន៍ចាប់ផ្តើមមានដៃគូសហការជាមួយ ផ្សារម៉ាក្រូ និងសួនសត្វសាហ្វារីដោយធ្វើការកំណត់ និងចុះកុងត្រាច្បាស់លាស់ទាក់ទងទៅនឹងតម្លៃ និងបរិមាណនៃបញ្ជាទិញទិន្នផលកសិកម្មពីខាងសហគមន៍។ នៅពេលនោះរាល់សមាជិកដែលមានដើមទុនគ្រប់គ្រាន់ បានធ្វើការពង្រីកនូវផ្ទៃដីដាំដុះកសិកម្ម ក៏ដូចជាចំណាយដើមទុនបន្ថែមទៅលើការបង្កើនឧបករណ៍ និងគ្រឿងយន្តកសិកម្មផ្សេងៗ ព្រមទាំងវត្ថុធាតុដើមជាច្រើនទៀត ដើម្បីបង្កើនការដាំដុះរបស់ខ្លួនឱ្យទទួលបានទិន្នផលច្រើន ដើម្បីបំពេញទៅតាមតម្រូវការ និងការបញ្ជាពីខាងដៃគូសហការ។ ប៉ុន្តែជាអកុសលនៅក្នុងចន្លោះឆ្នាំ២០១៦ ដល់ឆ្នាំ២០១៧ សហគមន៍បានជួបទៅនឹងគ្រោះធម្មជាតិ រាំងស្ងួត ដែលធ្វើឱ្យទិន្នផលកសិកម្មមិនមានភាពអំណោយផល និងទទួលបានទិន្នផលក្នុងបរិមាណតិច។ ទាំងនេះជាហេតុនាំឱ្យភាគរយនៃសមាជិកដែលមានដើមទុនគ្រប់គ្រាន់ក្នុងការប្រកបរបរកសិកម្មថយចុះ។

\+ យើងមាន $Y_3$ = ៧០,៥៨០,៨០០រៀល $Y_4$= ១០៥,២៣៣,២២០រៀល

តាមរូបមន្ត : ភាគរយនៃដើមទុនគ្រប់គ្រាន់ចន្លោះ$Y_{3\to4}$= $\frac{Y4-Y3}{Y3}$ = $\frac{១០៥,២៣៣,២២០-៧០,៥៨០,៨០០}{៧០,៥៨០,៨០០}$ = ០,៤៩%

ដូចនេះ នៅចន្លោះឆ្នាំ២០១៧ ដល់ ឆ្នាំ២០១៨ ភាគរយនៃដើមទុនគ្រប់គ្រាន់របស់សមាជិកសហគមន៍កសិកម្មសំបូរមានជ័យក្នុងការប្រកបរបរកសិកម្មគឺស្មើនឹង ០,៤៩% ។ បើធៀបទៅនឹងភាគរយនៃដើមទុនគ្រប់គ្រាន់របស់សមាជិកក្នុងការប្រកបរបរកសិកម្មចន្លោះឆ្នាំ ២០១៦ ដល់ឆ្នាំ២០១៧ គឺមានការកើនឡើងដល់ទៅ ០,២៧%។ ដោយសារតែនៅចន្លោះឆ្នាំ ២០១៧ ដល់ ឆ្នាំ ២០១៨ កត្តាអាកាសធាតុអំណោយផលល្អដែលនាំឱ្យសមាជិកសហគមន៍ទទួលបានទិន្នផលកសិកម្មច្រើនដែលអាចបំពេញទៅតាមតម្រូវការទីផ្សារ និងដៃគូ សហការបានពេញលេញ ជាហេតុនាំឱ្យភាគរយនៃដើមទុនគ្រប់គ្រាន់មានការកើនឡើង។

\+ យើងមាន $Y_4$= ១០៥,២៣៣,២២០រៀល $Y_5$= ១៦៦,៦៤៤,៤៥០រៀល

តាមរូបមន្ត:ភាគរយនៃដើមទុនគ្រប់គ្រាន់ចន្លោះ$Y_{4\to5}$= $\frac{Y5-Y4}{Y4}$ = $\frac{១៦៦,៦៤៤,៤៥០-១០៥,២៣៣,២២០}{១០៥,២៣៣,២២០}$= ០,៥៨%

ដូចនេះ នៅចន្លោះឆ្នាំ២០១៨ ដល់ ឆ្នាំ២០១៩ ភាគរយនៃដើមទុនគ្រប់គ្រាន់របស់សមាជិកសហគមន៍កសិកម្មសំបូរមានជ័យក្នុងការប្រកបរបរកសិកម្មគឺស្មើនឹង ០,៥៨% ។ បើធៀបទៅនឹងភាគរយនៃដើមទុនគ្រប់គ្រាន់របស់សមាជិកក្នុងការប្រកបរបរកសិកម្មចន្លោះឆ្នាំ ២០១៧ ដល់ ឆ្នាំ២០១៨ គឺមានការកើនឡើងដល់ទៅ ០,០៩%។ ដោយសារតែនៅចន្លោះឆ្នាំ ២០១៨ ដល់ ឆ្នាំ ២០១៩ សមាជិកសហគមន៍មានបទពិសោធន៍ក្នុងការធ្វើកសិកម្ម នឹងទទួលបានការបណ្តុះបណ្តាលពីសហគមន៍ផង ដែលធ្វើឱ្យទទួលបានទិន្នផលកសិកម្មច្រើន និងមានការបង្កើនការបញ្ជាទិញបន្ថែមមកលើទិន្នផលកសិកម្មរបស់សហគមន៍ពីខាងដៃគូសហការ និងទីផ្សារមួយចំនួនទៀតក្នុងរាជធានីភ្នំពេញ។

## ៣.៣. ភាពប្រែប្រួលនៅក្នុងសហគមន៍

យោងទៅតាមទិន្នន័យខាងលើបានបង្ហាញអោយដឹងថាសហគមន៍កសិកម្មសំបូរមានជ័យ គឺមានការប្រែប្រួលទាក់ទងទៅនឹងកម្រិតដើមទុនជាមធ្យមរបស់សមាជិកក្នុងការប្រកបរបរកសិកម្មហេដ្ឋារចនាសម្ព័ន្ធក្នុងសហគមន៍ដោយផ្អែកទៅលើស្ថានភាពចាប់ពីឆ្នាំ២០១៥ ដល់ឆ្នាំ២០១៩ ក៏ដូចជាស្ថានភាពក្នុងពេលបច្ចុប្បន្ននេះរួមមានចំណុចខ្លាំង និងចំណុចខ្សោយនៅក្នុងសហគមន៍ដូចខាងក្រោម៖

### ៣.៣.១ ចំណុចខ្លាំងនៅក្នុងសហគមន៍

ឆ្លងកាត់តាមការសិក្សាស្រាវជ្រាវ និងការចុះជួបសម្ភាសន៍ផ្ទាល់ជាមួយលោក **ឆេង ចុង** ប្រធានសហគមន៍កសិកម្មសំបូរមានជ័យ និងសមាជិកក្នុងសហគមន៍កាលពីថ្ងៃទី២២ ខែមិថុនា ឆ្នាំ២០២០បានឱ្យដឹងថាការអភិវឌ្ឍសហគមន៍កសិកម្មបានផ្តល់នូវចំណុចវិជ្ជមានជាច្រើនផងដែរ។

តារាងទី ១០ ៖ បង្ហាញពីអចលនទ្រព្យក្នុងសហគមន៍

| បរិយាយ | ចំនួន |
|---|---|
| ការិយាល័យ | ១ |
| ឃ្លាំងស្រូវ | ២ |
| ឡាន(ទំហំ ៣.៥ តោន) | ១ |
| រោងឡាន | ១ |
| ផ្សារ | ១ |
| អាគារឡរសម្ងួត | ១ |
| ឃ្លាំងលក់ជីកសិកម្ម | ១ |
| សរុប | ៨ |

ប្រភពទិន្នន័យ សហគមន៍កសិកម្មសំបូរមានជ័យឆ្នាំ២០២០

យោងតាមតារាង១០ បានបង្ហាញឱ្យដឹងថានៅក្នុងឆ្នាំ២០១៩ នេះសហគមន៍មានអចលនទ្រព្យសរុបជាទឹកប្រាក់ចំនួន ៧១៩,២២៥,២០០រៀល។ អចលនទ្រព្យរួមមាន ការិយាល័យចំនួន១ ឃ្លាំងស្រូវចំនួន២ ឡានដឹកទំនិញទម្ងន់ ៣.៥តោន ចំនួន ១គ្រឿង រោងសម្រាប់ដាក់ឡានចំនួន១ ផ្សារសហគមន៍ចំនួន១ អាគារឡរសម្ងួតចំនួន១ និងឃ្លាំងលក់ជីកសិកម្មចំនួន១។ មិនតែប៉ុណ្ណោះចំណុចខ្លាំងរបស់សហគមន៍កសិកម្ម សំបូរមានជ័យរួមមានដូចខាងក្រោម៖

- មានការកើនឡើងនូវចំនួនសមាជិកជារៀងរាល់ឆ្នាំ
- កម្រិតជីវភាពរបស់សមាជិកមានភាពប្រសើរឡើង
- បានកែប្រែប្រព័ន្ធធារាសាស្ត្រឱ្យមានលក្ខណៈល្អប្រសើរជាងមុន គឺមានប្រភពទឹកចំនួន២ដងក្នុង ១ ឆ្នាំសម្រាប់ការផលិតស្រូវពូជ
- ដីមានជីវជាតិល្អងាយស្រួលក្នុងការផលិតស្រូវពូជ
- គ្រាប់ស្រូវពូជដែលផលិតបានមានសម្បុរភ្លឺ ទំហំធំ ដែលខុសពីស្រូវពូជដែលផលិតនៅតំបន់ផ្សេង
- ក្រុមអ្នកផលិតស្រូវពូជមានការចុះកុងត្រាទាក់ទងទៅនឹងតម្លៃច្បាស់លាស់
- មានទីផ្សារធ្វើការកម្មង់បានមុនរដូវកាលផលិត
- សហគមន៍ទទួលបានការគាំទ្រពីសាលាកសិកម្មខេត្តកំពង់ចាម និងថ្នាក់ដឹកនាំខេត្តមួយចំនួន
- មានវិធីសាស្ត្រផ្សព្វផ្សាយផលិតផលសហគមន៍បានល្អ

- ធ្វើការស្តារប្រឡាយមួយកន្លែងប្រវែង ១,៥០០ម៉ែត្រ គិតជាទឹកប្រាក់ចំនួន ៣,២១០,០០០ រៀល
- ជួសជុលផ្លូវលំប្រវែង ៣២១ ម៉ែត្រ គិតជាទឹកប្រាក់ចំនួន ២,៣០០,០០០រៀល
- ជួសជុលទំនប់ទឹកមួយកន្លែង គិតជាទឹកប្រាក់ចំនួន ២០០,០០០រៀល
- ធ្វើការផ្តល់កម្ចីឱ្យសមាជិកដែលមានបញ្ហាបន្ទាន់ ដោយឥតមានគិតការប្រាក់
- សហគមន៍ពោរពេញទៅដោយសុខសុវត្ថិភាពល្អ

### ៣.៣.២ ចំណុចខ្សោយនៅក្នុងសហគមន៍

ស្របជាមួយនឹងចំណុចវិជ្ជមានជាច្រើននៅក្នុងការអភិវឌ្ឍសហគមន៍ ដូចដែលបានរៀបរាប់ខាងលើ យើងសង្កេតឃើញថាមានចំណុចអវិជ្ជមានផងដែរនៅក្នុងការអភិវឌ្ឍសហគមន៍កសិកម្មសំបូរមានជ័យ រួមមានដូចខាងក្រោម៖

- សមាជិកក្នុងសហគមន៍មានដើមទុនខ្វះខាតក្នុងការប្រកបរបរកសិកម្ម
- ឃ្លាំងស្តុកស្រូវពូជមានទំហំតូចចង្អៀត ជាបញ្ហាដល់ការស្តុកគ្រាប់ស្រូវពូជ
- មិនមានម៉ាស៊ីនញែកគ្រាប់ពូជស្រូវ
- ខ្វះបច្ចេកវិទ្យាក្នុងការផលិតពូជ
- ខ្វះមធ្យោបាយដឹកជញ្ជូន
- ប្រព័ន្ធស្រោចស្រពនៅមានកម្រិត ដោយសារតែសមាជិកមួយចំនួនមិនទាន់មានម៉ាស៊ីនទឹកសម្រាប់ធ្វើការប្រើប្រាស់

## ៣.៤ លទ្ធផលស្រាវជ្រាវ

តាមរយៈការសិក្សាស្រាវជ្រាវខាងលើនេះបានឆ្លុះបញ្ចាំងឱ្យឃើញថា ការអភិវឌ្ឍសហគមន៍បានជួយលើកស្ទួយទៅដល់ជីវភាពរស់របស់បងប្អូនប្រជាពលរដ្ឋមួយចំនួនដែលរួមមាន៖

- ការកែលម្អហេដ្ឋារចនាសម្ព័ន្ធ (កសាងផ្លូវឱ្យមានលក្ខណៈល្អប្រសើរជាងមុន ងាយស្រួលក្នុងការដឹកជញ្ជូនទិន្នផលកសិកម្មទៅកាន់ទីផ្សារ)
- ផ្តល់កម្ចីទៅដល់សមាជិកគ្រប់រូបដែលមានបញ្ហាបន្ទាន់ដោយឥតមានគិតការប្រាក់
- មានវិធីសាស្ត្របង្រៀន និងធ្វើការប្រជុំទៀតទាត់ដូចដែលបានកំណត់ដើម្បីឱ្យសមាជិកគ្រប់រូបទទួលបានចំណេះដឹងថ្មីៗទាក់ទងទៅនឹងកសិកម្មរបស់បងប្អូនដែលកំពុងធ្វើការបង្កបង្កើនផល
- ផ្តល់សិទ្ធជូនដល់សមាជិកឱ្យធ្វើការសម្រេច និងជួយគាំទ្រដល់សមាជិកគ្រប់រូប
- សហគមន៍មានសន្តិសុខសុវត្ថិភាពល្អ

ទន្ទឹមនឹងភាពរីកចម្រើនទាំងអស់នេះហើយ ក៏មានភាពអវិជ្ជមានមួយចំនួនផងដែរ ដោយសារតែមានការខ្វះខាតបច្ចេកវិទ្យាមួយចំនួនក្នុងការធ្វើកសិកម្ម ហើយមិនមានបច្ចេកទេសក្នុងការដាំដុះ រួមផ្សំជាមួយនឹងការយល់ដឹងរបស់បងប្អូននៅមានកម្រិត និងមានសមាជិកមួយផ្នែកទៀតខ្វះខាតដើមទុនក្នុងការប្រកបរបរកសិកម្ម ជាហេតុនាំឱ្យមានភាពយឺតយ៉ាវទៅដល់ការអភិវឌ្ឍសហគមន៍។ កត្តាទាំងអស់នេះហើយដែលធ្វើឱ្យសមាជិក និងសហគមន៍ទាំងមូលបានជួបប្រទះកំឡុងពេលសហគមន៍កំពុងធ្វើការអភិវឌ្ឍ។

# សេចក្តីសន្និដ្ឋាន និងការផ្តល់អនុសាសន៍

## ១. សេចក្តីសន្និដ្ឋាន

ក្រោយពីបានធ្វើការសិក្សាស្រាវជ្រាវយ៉ាងលម្អិត ក៏ដូចជាការចុះជួបសាកសួរព័ត៌មានផ្ទាល់ជាមួយក្រុមប្រឹក្សាភិបាល និងជាមួយសមាជិកនៅក្នុងសហគមន៍កសិកម្មសំបូរមានជ័យដែលស្ថិតនៅភូមិសំបូរ ឃុំសូតាស ស្រុកស្ទឹងត្រង់ ខេត្តកំពង់ចាមអំពីដំណើរការនៃការអភិវឌ្ឍសហគមន៍កសិកម្មរួចមក និងតាមភាពជាក់ស្តែងទៅលើប្រធានបទ **ការអភិវឌ្ឍសហគមន៍** យើងអាចសន្និដ្ឋានបានថា ការយកចិត្តទុកដាក់របស់ក្រុមប្រឹក្សាភិបាល ព្រមទាំងថ្នាក់ដឹកនាំសហគមន៍ទាំងមូល រួមផ្សំជាមួយនឹងការជួយគាំទ្រពីបណ្តាលប្រធានភូមិ មន្ត្រីថ្នាក់ដឹកនាំខេត្ត សាលាជាតិកសិកម្មខេត្តកំពង់ចាម និងមានការចូលរួមយ៉ាងសកម្មពីសំណាក់បងប្អូនប្រជាពលរដ្ឋបានបង្ហាញឱ្យដឹងថា ការអភិវឌ្ឍសហគមន៍កសិកម្មមានការប្រសើរឡើងជាលំដាប់ទាំងការស្វែងរកទីផ្សារ ការរៀបចំនូវហេដ្ឋារចនាសម្ព័ន្ធ ការរៀបចំតួនាទី ការរៀបចំផែនការ ការបណ្តុះបណ្តាលនូវវិធីសាស្ត្រដាំដុះដំណាំកសិកម្ម និងការកើនឡើងនូវកំណើនសមាជិកជាបន្តបន្ទាប់ផងដែរ។ ជាក់ស្តែងសហគមន៍មានការអភិវឌ្ឍន៍ពីមួយឆ្នាំទៅមួយឆ្នាំដែលរួមមាន៖

- ការរៀបចំហេដ្ឋារចនាសម្ព័ន្ធ ៖ ធ្វើឱ្យមានលក្ខណៈប្រសើរឡើងជាងពីមុន ដោយសារតែនៅក្នុងសហគមន៍មានការជួសជុលផ្លូវថ្នល់ប្រវែង១០គីឡូម៉ែត្រ។
- ការរៀបចំផែនការ ៖ ក្រុមប្រឹក្សាភិបាល និងថ្នាក់ដឹកនាំសហគមន៍ទាំងអស់បានធ្វើការខិតខំប្រឹងប្រែងយ៉ាងខ្លាំងក្នុងការរៀបចំផែនការស្វែងរកទីផ្សារ ដើម្បីធ្វើការនាំចេញនូវផលិតផលកសិកម្មរបស់សមាជិកគ្រប់រូបឱ្យទទួលបានក្នុងតម្លៃខ្ពស់ និងធ្វើការបង្កើតគម្រោងជាច្រើនដែលរួមមាន គម្រោងអនុវត្តប្រាក់កម្ចីដោយឥតការប្រាក់រយៈពេល ១៥ថ្ងៃ គម្រោងបង្កើតផ្សារសហគមន៍ ដើម្បីធ្វើការលក់ផលិតផលកសិកម្ម ផែនការផ្សព្វផ្សាយ និងបង្កើនផលិតផលកសិកម្មឱ្យសមាជិកគ្រប់រូបទទួលបានប្រាក់ចំណូលកើនឡើង។
- ការបណ្តុះបណ្តាល ៖ ពង្រឹកសមត្ថភាពសមាជិកគ្រប់រូបឱ្យចេះគ្រប់គ្រង់តណទានសមត្ថភាពក្នុងការដាំដុះ និងធានាបាននូវគុណភាព។
- ការកែលម្អបរិស្ថានរស់នៅ ៖ ប្រជាពលរដ្ឋទទួលបានការរស់នៅដែលល្អប្រសើរជាងមុនដោយមានប្រព័ន្ធទឹកប្រើប្រាស់បានគ្រប់គ្រាន់ មានការសាងសង់បង្គន់អនាម័យ និងផ្សារសហគមន៍ដែលនៅជិតលំនៅស្ថានរបស់ប្រជាជន។

– ការកើនឡើងការងាររបស់បងប្អូនប្រជាពលរដ្ឋ ៖ ក្រុមប្រឹក្សាភិបាល និងថ្នាក់ដឹកនាំសហគមន៍ទាំងអស់បានធ្វើការទាក់ទងជាមួយនឹងអង្គការនានាទាំងក្នុង និងក្រៅរដ្ឋាភិបាល ក្នុងការស្វែងរកនូវវិធីសាស្ត្រផ្សេងៗទាក់ទងទៅនឹងការដាំដុះដំណាំកសិកម្មដែលជាតម្រូវការរបស់ទីផ្សារទាំងក្នុង និងក្រៅតំបន់នាពេលបច្ចុប្បន្ន។

សរុបសេចក្តីមកតាមការរៀបរាប់ខាងលើនេះ បានឆ្លុះបញ្ចាំងអោយដឹងថា **ការអភិវឌ្ឍសហគមន៍** បានកែប្រែស្ថានភាពរស់នៅ បង្កើនប្រាក់ចំណូល បង្កើនការងារ បង្កើនការយល់ដឹងទាក់ទៅនឹងការដាំដុះដំណាំកសិកម្មរបស់បងប្អូនប្រជាពលរដ្ឋបានច្រើន។ លើសពីនេះទៅទៀត **ការអភិវឌ្ឍសហគមន៍** បានជួយលើកស្ទួយទៅដល់បរិស្ថាន ផ្តល់សិទ្ធជូនដល់សមាជិកគ្រប់រូបឱ្យទទួលបាននូវអ្វីដែលគួរនឹងទទួលបានដោយមិនគិតអំពីភេទ ឋានៈ និងតួនាទីឡើយ ហើយក៏បានធ្វើការផ្លាស់ប្តូរផ្នត់គំនិត ឥរិយាបថក្នុងការរស់នៅ កាត់បន្ថយគម្លាតរវាងអ្នកមាន និងអ្នកក្រ ព្រមទាំងបានលើកកម្ពស់ស្មារតីរបស់បងប្អូនប្រជាពលរដ្ឋបានផងដែរ។

## ២. ការផ្តល់អនុសាសន៍

ការអភិវឌ្ឍសហគមន៍ ពិតជាមានសារៈសម្ខាន់ណាស់ក្នុងការជម្រុញដល់សេដ្ឋកិច្ចប្រទេសកម្ពុជាដោយមិនអាចខ្វះខាតបាន ពីព្រោះថារាល់ការអភិវឌ្ឍន៍ទាំងអស់សុទ្ធតែផ្តើមចេញពីចំណុចតូចៗទៅដល់ចំណុចធំៗ។ដើម្បីជម្រុញទៅដល់ការអភិវឌ្ឍសហគមន៍ឱ្យកាន់តែមានប្រសិទ្ធភាពយើងខ្ញុំសូមធ្វើការបញ្ចេញមតិ និងយោបល់នៅក្នុងគោលបំណងចូលរួមកែលម្អត្រង់ចំណុចខ្វះខាត និងពង្រឹងការអភិវឌ្ឍសហគមន៍ឱ្យកាន់តែប្រសើរឡើងបន្ថែមទៀតដូចតទៅ៖

- ចំពោះសហគមន៍ ៖ ត្រូវផ្តល់ការបណ្តុះបណ្តាល និងពង្រឹងសមត្ថភាពគណៈកម្មការគ្រប់រូបឱ្យមានជំនាញដឹកនាំយ៉ាងពិតប្រាកដ និងធ្វើការបង្កើនការទំនាក់ទំនងជាមួយក្រសួងពាក់ព័ន្ធ ស្ថាប័ន អង្គការនានាទាំងក្នុង និងក្រៅតំបន់ឱ្យបានកាន់តែច្រើន។ ម្យ៉ាងវិញទៀតសហគមន៍គួរបង្កើតជាគម្រោងដាក់ប្រាក់សន្សំដើម្បីជួយសម្រួលទៅដល់សមាជិកដែលមានដើមទុនខ្វះខាតក្នុងការប្រកបរបរកសិកម្ម។
- ចំពោះសមាជិក ៖ ត្រូវចូលរួមក្នុងការបណ្តុះបណ្តាលនានាដែលទាក់ទងទៅនឹងការធ្វើកសិកម្មរបស់បងប្អូន ធ្វើការបញ្ចេញមតិឱ្យបានច្រើនរាល់ចំណុចណាដែលនាំឱ្យខាតបង់ដល់ប្រយោជន៍រួម និងរួបរួមសាមគ្គីគ្នាឱ្យរឹងមាំដើម្បីជម្រុញដល់ការអភិវឌ្ឍសហគមន៍របស់បងប្អូនដែលកំពុងធ្វើការរស់នៅ។
- ចំពោះអជ្ញាធរ ៖ ត្រូវបង្កើនការផ្សព្វផ្សាយ និងជួយគាំទ្រថវិការ ផ្គត់ផ្គង់សម្ភារៈបច្ចេកទេសកសិកម្មផ្សេងៗដើម្បីឱ្យការអភិវឌ្ឍសហគមន៍ប្រកបដោយប្រសិទ្ធភាពដែលមានដូចជា៖

- ជម្រុញការស្តារប្រព័ន្ធទឹកដែលមានស្រាប់ និងសិក្សាបន្ថែមអំពីការជីកប្រព័ន្ធធារាសាស្ត្រថ្មី
- ជម្រុញការផ្សព្វផ្សាយបច្ចេកទេសកសិកម្មថ្មីៗជូនដល់ប្រជាពលរដ្ឋ
- ជម្រុញការផ្សព្វផ្សាយបន្ថែមលើវិធានការទប់ស្កាត់ និងការពារសមាសភាគចង្រៃដែលបំផ្លាញដល់ដំណាំកសិកម្មនៅក្នុងសហគមន៍។

ជាចុងក្រោយការអភិវឌ្ឍសហគមន៍ គឺជាទិសដៅយ៉ាងសម្ខាន់មួយដែលរាជរដ្ឋាភិបាលបានយកចិត្តទុកដាក់ជាខ្លាំង។ទន្ទឹមនឹងនេះផងដែរការអភិវឌ្ឍសហគមន៍មិនមែនត្រឹមតែបង្កើននូវការនាំចេញទិន្នផលកសិកម្មតែមួយមុខប៉ុណ្ណោះទេ ប៉ុន្តែវាក៏បានធ្វើឱ្យមានការកើនឡើងនូវកម្រិតដើមទុនជាមធ្យមរបស់សមាជិកក្នុងសហគមន៍ ធនធានមនុស្ស សមភាពយេនឌ័រ សិទ្ធមនុស្ស សុខភាព អនាម័យ និងកម្រិតជីវភាពរបស់ប្រជាជនមានភាពប្រសើរឡើងជាងមុនផងដែរ។

# ឯកសារយោង

## ឯកសារជាភាសាខ្មែរ


- ព្រះរាជក្រឹត្យលេខ នស/រកត/០៩០៨/១០៥៥ ចុះថ្ងៃទី២៥ ខែកញ្ញា ឆ្នាំ២០០៨ ទំព័រ១១/៣៧ https://data.opendevelopmentmekong.net/dataset/91df5d42-9c26-404f-b7f7-9f5ebd78a468/resource/46217d5c-9f12-446a-81a6-1012bae56bb7/download/394.pdf
- ច្បាប់ស្តីពីសហគមន៍កសិកម្ម "https://server2.maff.gov.kh/parse/files/myAppId5hD7ypUYw61sTqML/02e2778b4da9c4fc00270bb02b98d7e5_1503051354.pdf"
- ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ ចេញផ្សាយថ្ងៃទី២៦ ខែកុម្ភៈ ឆ្នាំ២០២០ "https://web.maff.gov.kh/newsdetail/Nau8TzyVnJ"
- វិទ្យាស្ថានពុទ្ធសាសនបណ្ឌិត, វចនានុក្រមខ្មែរ, ព.ស ២៥១១, គ.ស ១៩៦៧
- សារណាបញ្ចប់ការសិក្សា ការអភិវឌ្ឍជនបទ ឃុំព្រែកជ្រៃ ស្រុកល្វាឯម ខេត្តកណ្តាល ឆ្នាំ ២០១៩
- មុខវិជ្ជា ការអភិវឌ្ឍជនបទ បង្រៀនដោយសាស្ត្រាចារ្យបណ្ឌិត ឈុន ពហុ, មេរៀនសេចក្តីផ្តើមនៃការអភិវឌ្ឍន៍ជនបទ
- យូអ៊ីនឌីភី ឆ្នាំ២០១៦។ "ការវាយតម្លៃរួមបញ្ចូលគ្នាឆាប់រហ័ស-គោលដៅអភិវឌ្ឍន៍ប្រកបដោយចីរភាពនៅកម្ពុជា"។ ចូលអានខែមីនា ឆ្នាំ២០១៨។
- អង្គការសហប្រជាជាតិឆ្នាំ ២០១៥។ "ផ្លាស់ប្តូរពិភពលោករបស់យើង ៖ របៀបវារៈ ២០៣០ សម្រាប់ការអភិវឌ្ឍប្រកបដោយចីរភាព"។
- ការអភិវឌ្ឍវិស័យអប់រំ https://www.usaid.gov/km/cambodia/education (last update August 23,2019)
- អគ្គនាយកដ្ឋានរដ្ឋបាល https://gda.interior.gov.kh/commune-sangkat-management/
- សីលធម៌ 2018-09-19 https://www.khsearch.com/qna/7833
- គម្រោងពិពិធកម្មវិស័យកសិកម្មនៅកម្ពុជា ទំព័រទី៥ (ចូលអានថ្ងៃ៣០ ខែកក្កដា ឆ្នាំ ២០១៨)
- នាយកដ្ឋានអភិវឌ្ឍសហគមន៍ ឆ្នាំ២០១៥
- ការិយាល័យអភិវឌ្ឍសហគមន៍កសិកម្ម លេខ ៣៤ ក អ ស ចុះថ្ងៃទី៨ ខែសីហា ឆ្នាំ ២០១៦
- ជប៉ុនផ្តល់ជំនួយសម្រាប់ការស្តារឡើងវិញនូវប្រព័ន្ធធារាសាស្ត្រ និងពង្រឹងសហគមន៍កសិកម្ម https://www.kh.emb-japan.go.jp/files/000560127.pdf
- លោក ឆេង ថុង, របាយការណ៍សហគមន៍កសិកម្មសំបូរមានជ័យ (ភូមិសំបូរ ឃុំសូភាស ស្រុកស្ទឹងត្រង់ ខេត្តកំពង់ចាម)

## ឯកសារជាភាសាបរទេស


- Sunday, 11 March 2018 Written by Sid Israel https://www.sid-israel.org/en/Development-Issues/What-is-Development
- Case Study in Cambodian public health fields October -November 2018 ‶Dr.Ros Chhay senior program manager Australian Agency For International Development″
- Michael P. Todaro ‶Micheal P.Todaro Economic development fifth Edition 1994″
- From Wikipedia, the free encyclopedia https://en.wikipedia.org/wiki/Rostow%27s_stages_of_growth
- Community Development Theories, Posted by Patty at 12:57 AM http://communitydevtheories.blogspot.com/
- From Wikipedia, the free encyclopedia https://en.wikipedia.org/wiki/Agriculture
- https://www.universalclass.com/articles/business/exploring-strategic-factors-of-community-development.htm

# ឧបសម្ព័ន្ធ

**ឧបសម្ព័ន្ធទី១ ៖ រចនាសម្ព័ន្ធនៃការគ្រប់គ្រងសហគមន៍កសិកម្មរបស់ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ**



**ឧបសម្ព័ន្ធទី២ ៖ រចនាសម្ព័ន្ធនៃការគ្រប់គ្រងសហគមន៍កសិកម្មសំបូរមានជ័យ**



## ឧបសម្ព័ន្ធទី៣ ៖ កម្រងសំណួរ

ជាបឋមសូមជម្រាបសួរលោកពូ អ្នកមីង និងសមាជិកសហគមន៍ទាំងអស់ យើងខ្ញុំជានិស្សិតឆ្នាំទី ៤នៃសាកលវិទ្យាល័យភូមិន្ទនីតិសាស្រ្ត និងវិទ្យាសាស្រ្តសេដ្ឋកិច្ច ដែលបានសិក្សាលើជំនាញសេដ្ឋអភិវឌ្ឍន៍នឹងត្រូវបញ្ចប់ការសិក្សាក្នុងឆ្នាំ២០២០នេះ។ ដើម្បីបញ្ចប់ការសិក្សានេះយើងខ្ញុំទាំងពីរនាក់ត្រូវចុះសិក្សាស្រាវជ្រាវ និងប្រមូលទិន្នន័យមួយចំនួនពីលោកពូអ្នកមីងទាំងអស់គ្នាដែលទាក់ទងទៅនឹងការអភិវឌ្ឍសហគមន៍ដើម្បីចងក្រងជាសារណាបញ្ចប់ការសិក្សា។ យើងខ្ញុំសូមជម្រាបថារាល់ពត៌មានដែលបានមកពីកម្រងសំណួរនេះ គឺប្រើក្នុងគោលបំណងសម្រាប់សិក្សាស្រាវជ្រាវតែប៉ុណ្ណោះ។

យើងខ្ញុំទាំងពីរនាក់សូមថ្លែងអំណរគុណយ៉ាងជ្រាវជ្រៅ ចំពោះកិច្ចសហប្រតិបត្តិការរបស់លោកពូងអ្នកមីងទាំងអស់គ្នាក្នុងការផ្តល់ឱកាសអោយរូបយើងខ្ញុំទាំងពីរនាក់។

- ➢ធ្វើឡើងនៅថ្ងៃទី................ខែ.............ឆ្នាំ២០២០
- ➢នៅក្នុងសហគមន៍កសិកម្មសំបូរមានជ័យ ដែលស្ថិតនៅភូមិសំបូរ ឃុំសូភាស ស្រុងស្ទឹងត្រង់ ខេត្តកំពង់ចាម នៃសមាជិកសរុបចំនួន ៥៩៧នាក់។
- ➢ពត៌មានរបស់អ្នកចូលរួម៖
- ➢ឈ្មោះ ..................................ភេទ....................អាយុ...........ឆ្នាំ

### ❖ ស្ថានភាពសមាជិកសហគមន៍ក្នុងការប្រកបរបរកសិកម្មកំឡុងឆ្នាំ២០១៥ ដល់ឆ្នាំ២០១៩

១. តើលោកពូ អ្នកមីងប្រកបមុខរបរអ្វី?

ធ្វើដំណាំកសិកម្ម□ ចិញ្ចឹមសត្វ□ ផ្សេងៗ□

២. តើលោកពូ អ្នកមីងមានប្រភពទឹកមកពីណាសម្រាប់ធ្វើការស្រោចស្រពដំណាំកសិកម្ម?

ទឹកអណ្តូង□ ទឹកម៉ាស៊ីន□

៣. តើលោកពូ អ្នកមីងប្រើប្រាស់ឧបករណ៍បែបណាក្នុងការប្រកបរបរកសិកម្ម?

ឧបករណ៍បែបបុរាណ□ គ្រឿងយន្តតិចតួច□

៤.តើលោកពូ អ្នកមីងធ្លាប់ជួបប្រទះនឹងបញ្ហាទីផ្សារដែររឺទេ?បញ្ហាអ្វីខ្លះ?

- ក្នុងករណីជួបបញ្ហា ៖
  មិនមានទីផ្សារសម្រាប់លក់ផលិតផលកសិកម្ម □
  តម្លៃទីផ្សារអាស្រ័យទៅតាមការបញ្ជាទិញរបស់ឈ្មួញកណ្តាល □
- ក្នុងករណីមិនជួបបញ្ហា ៖

មានទីផ្សារសម្រាប់លក់ផលិតផលកសិកម្ម □

ឈ្មួញកណ្ដាលធ្វើការបញ្ចាទិញសមស្របទៅតាមតម្លៃទីផ្សារ □

៥. តើលោកពូ អ្នកមីងមានដើមទុនគ្រប់គ្រាន់ក្នុងការប្រកបរបរកសិកម្មដែររឺទេ?

គ្រប់គ្រាន់□ ខ្វះខាត□

៦. តើចំណូលជាមធ្យមរបស់លោកពូ អ្នកមីងអាចរកបានចំនួនប៉ុន្មានដែរ?.....................................រៀល

៧. តើលោកពូ អ្នកមីងខ្វះខាតដើមទុនចំនួនប៉ុន្មានជាមធ្យមក្នុងការប្រកបរបរកសិកម្ម?......................រៀល

៨. តើលោកពូ អ្នកមីងមានដើមទុនគ្រប់គ្រាន់ចំនួនប៉ុន្មានជាមធ្យមក្នុងការប្រកបរបរកសិកម្ម?.............រៀល

- **ស្ថានភាពអភិវឌ្ឍន៍សហគមន៍កំឡុងឆ្នាំ២០១៥ ដល់ឆ្នាំ២០១៩**

២.តើសហគមន៍របស់លោកពូ អ្នកមីងមានការអភិវឌ្ឍលើផ្លូវថ្នល់ សាលារៀន មន្ទីរពេទ្យ វត្តអារាម ដែររឺទេ?

មាន □ អត់ □

៣.តើសហគមន៍របស់លោកពូ អ្នកមីងមានការជឿនលឿនផ្នែកបច្ចេកទេសសម្រាប់ធ្វើកសិកម្មដែររឺទេ?

មាន □ អត់ □

៤.តើសហគមន៍របស់លោកពូ អ្នកមានគម្លាតរវាងអ្នកមាន និងអ្នកក្រដែររឺទេ?

មាន □ អត់ □

៥.តើសហគមន៍របស់លោកពូ អ្នកមីងមានកម្មវិធីអប់រំផ្នែកកសិកម្មជូនដល់លោកពូ អ្នកមីងដែររឺទេ?

មាន □ អត់ □

៦. តើលោកពូ អ្នកមីងបានចូលរួមចំណែកក្នុងការអភិវឌ្ឍសហគមន៍ដែររឺទេ?

បាន □ មិនបាន □

៧. តើមន្ត្រីថ្នាក់ឃុំ / ថ្នាក់ខេត្តធ្លាប់បានចូលរួមអភិវឌ្ឍសហគមន៍ជាមួយលោកពូ អ្នកមីងដែររឺទេ?

បាន □ មិនបាន □

៨. តើលោកពូ អ្នកមីងបានចូលរួមប្រជុំវគ្គបណ្តុះបណ្ដាលក្នុងសហគមន៍ដែររឺទេ?

បាន □ មិនបាន □

៨. តើការប្រកបរបរកសិកម្មអាចជួយផ្គត់ផ្គង់ដល់ជីវភាពលោកពូ អ្នកមីងគ្រប់គ្រាន់ដែររឺទេ?

អាច □ មិនអាច □

៩.តើសហគមន៍លោកពូ អ្នកមីងមានសុខសុវត្ថិភាពដែរទេ?

មាន □ មិនមាន □

១០.តើសហគមន៍របស់លោកពូ អ្នកមីងបានផ្តល់ការងារទៅដល់លោកពូ អ្នកមីងដែររឺទេ?

បាន□ មិនបាន □

១១.តើសហគមន៍របស់លោកពូ អ្នកមីងមានការអភិវឌ្ឍដែររឺទេ ចាប់តាំងពីឆ្នាំ ២០១៥ មក??

មាន □ អត់ □

១២. ក្រោយពីបានធ្វើការអភិវឌ្ឍសហគមន៍កន្លងមកនេះ តើជីវភាពរស់នៅរបស់លោកពូ អ្នកមីងមានការប្រែប្រួលបែបណាខ្លះ?

.......................................................................................................................................

.......................................................................................................................................

.......................................................................................................................................

....................................................................................................................................។

# ឧបសម្ព័ន្ធទី៥ ៖ លក្ខន្តិកៈសហគមន៍កសិកម្ម

## ផ្នែកទី ២
## លក្ខន្តិកៈសហគមន៍កសិកម្ម

**មាត្រា ២៦.-**

លក្ខន្តិកៈសហគមន៍កសិកម្ម ត្រូវចែងលក្ខខណ្ឌដូចខាងក្រោម៖

- នាមករណ៍
- ស្លាកសញ្ញា ទីស្នាក់ការ និងអាសយដ្ឋាន
- ប្រភេទមុខរបរ
- ដើមទុនដែលបានមកពីភាគហ៊ុន តម្លៃភាគហ៊ុន និងលក្ខខណ្ឌនៃការបង់ភាគហ៊ុន
- លក្ខខណ្ឌនៃការគ្រប់គ្រងហិរញ្ញវត្ថុ
- លក្ខខណ្ឌនៃហិរញ្ញប្បទាននិងឥណទាន
- របៀបរបបនៃការចុះបញ្ជីគណនេយ្យនិងការគ្រប់គ្រងឯកសារនានា
- ការទទួលខុសត្រូវផ្នែកហិរញ្ញវត្ថុរបស់សមាជិកចំពោះបំណុលរបស់សហគមន៍កសិកម្ម ។ ការទទួលខុសត្រូវនេះមិនត្រូវមានកម្រិតលើសពី៤(បួន)ដងនៃចំនួនភាគហ៊ុនដែលសមាជិកម្នាក់ៗកាន់កាប់ឡើយ
- សិទ្ធិនិងភាតព្វកិច្ចរបស់សមាជិក
- លក្ខខណ្ឌនៃការសុំចូលជាសមាជិក
- លក្ខខណ្ឌនៃការលាឈប់និងការបណ្តេញចេញពីសមាជិកភាពសហគមន៍កសិកម្ម
- ការប្រព្រឹត្តទៅរបស់មហាសន្និបាតនិងមហាសន្និបាតតំណាង
- សមាសភាពក្រុមប្រឹក្សាភិបាលនិងគណៈកម្មាធិការត្រួតពិនិត្យ
- លក្ខខណ្ឌនៃការកោះប្រជុំក្រុមប្រឹក្សាភិបាលនិងគណៈកម្មាធិការត្រួតពិនិត្យ
- សិទ្ធិនិងភារកិច្ចរបស់ក្រុមប្រឹក្សាភិបាលនិងគណៈកម្មាធិការត្រួតពិនិត្យ
- លក្ខខណ្ឌនៃការបញ្ចូលគ្នារបស់សហគមន៍កសិកម្ម

ឧបសម្ព័ន្ធទី៦ ៖ ទិដ្ឋភាពទូទៅជុំវិញសហគមន៍កសិកម្មសំបូរមានជ័យ






## សហគមន៍កសិកម្មសំបូរមានជ័យ




## សកម្មភាពចូលរួមចុះឈ្មោះចូលជាសមាជិកថ្មីរបស់សហគមន៍



## សកម្មភាពចូលរួមប្រជុំរបស់សមាជិកសហគមន៍កសិកម្ម



## ការថតរូបអនុស្សាវរីយ៍ជាមួយសមាជិកសហគមន៍កសិកម្មសំបូរមានជ័យ

